# ការលក់ដូរដីធ្លីនៅកម្ពុជា

## *ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី*

ឯកសារពិភាក្សាលេខ ២២

ច័ន្ទ សុផល និង Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ខែមិថុនា ឆ្នាំ២០០២

© **រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឡើយ ។

**ISSN 1560 9812**

**ការលក់ដូរដីធ្លីនៅកម្ពុជា: *ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* ~ ឯកសារពិភាក្សាលេខ ២២ ខែមិថុនា ឆ្នាំ២០០២**

***ច័ន្ទ សុផល និង Sarthi Acharya***

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះ បណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
**ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)**
**ទូរស័ព្ទ: (៨៥៥-២៣) ៣៦៨-០៥៣/៨៨០-៧៣៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៣៦៦-០៩៤**
**អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh**

បកប្រែដោយ: ច័ន្ទ សុផល និង សូ សុវណ្ណារិទ្ធិ
កែសម្រួល និងរចនាដោយ: អ៊ុំ ចាន់ថា និងអែម សូវ៉ានី
បោះពុម្ពនៅប្រទេសកម្ពុជាដោយរោងពុម្ពពន្លឺពេជ្រ ផ្ទះលេខ៨៧$E_0$ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

# មាតិកា

សម្រង់អត្ថបទ .................... i
បញ្ជីអក្សរកាត់ .................... v
សេចក្ដីថ្លែងអំណរគុណ .................... vii

**ជំពូក១. សេចក្ដីផ្ដើម** .................... ១

**ជំពូក២. ទីផ្សារដីធ្លី វិសមភាព និងភាពគ្មានដីនៅកម្ពុជា: ការពិនិត្យឯកសារដែលមានស្រាប់** .................... ៣

២.១. ប្រវត្តិសាស្ត្រកម្ពុជាក្នុងពេលថ្មីៗទាក់ទិននឹងទីផ្សារដីធ្លី .................... ៣
២.២. ការប្រែប្រួលកម្មសិទ្ធិដីធ្លី និងភាពគ្មានដី .................... ៤

**ជំពូក៣. និន្នាការនៃការលក់ដូរដីធ្លី** .................... ៧

៣.១. វិធីសាស្ត្រនៃការវិភាគទិន្នន័យ .................... ៧
៣.២. ការទិញលក់ដីលំនៅដ្ឋាន .................... ៩
៣.៣. និន្នាការនៃការទិញលក់ដីកសិកម្ម .................... ១៩
៣.៤. ការលក់ដីធ្លីគិតតាមទំហំដី .................... ២៥

**ជំពូក៤. និន្នាការនៃថ្លៃដី** .................... ២៩

៤.១. ថ្លៃដីលំនៅដ្ឋាន .................... ៣០
៤.២. ថ្លៃដីកសិកម្ម .................... ៣៣

**ជំពូក៥. លទ្ធផលអង្កេតខ្នាតតូចដែលប្រើវិធីសិក្សាបែបគុណភាព** .................... ៣៧

៥.១. ការទិញ-លក់ដី .................... ៣៧
៥.២. ប្រភេទនៃការទិញ-លក់ដីធ្លី .................... ៣៨
៥.៣. ការទិញ-លក់ដីតាមផ្លូវការ .................... ៣៨
៥.៤. ការទិញ-លក់ដីក្រៅផ្លូវការ .................... ៣៩

៥.៥. មូលហេតុដែលធ្វើឱ្យគេមិនចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឹមត្រូវ ........ ៤០
៥.៦. ពន្ធប្រថាប់ត្រា ៤% និងឥទ្ធិពលទៅលើថ្លៃដីដែលចុះរាយការណ៍ជាផ្លូវការ ........ ៤១

**ជំពូក៦. សេចក្តីសន្និដ្ឋាន** ........ ៤៣

ឯកសារយោង ........ ៤៥
ឧបសម្ព័ន្ធ ........ ៤៧
ឯកសារពិភាក្សាបោះពុម្ពផ្សាយដោយ វិបសអ ........ ៤៩

# សេចក្តីសង្ខេប

ការស្រាវជ្រាវនេះកើតចេញពីការព្រួយបារម្ភដោយសារការផ្ទេរដីធ្លីក្នុងចំនួនច្រើនៗ និងភាពគ្មានដីធ្លីដែលផុសឡើងនៅចុងទសវត្សរ៍១៩៩០ នៅក្នុងប្រទេសកម្ពុជា ។ ការស្រាវជ្រាវសំដៅធ្វើចំណាត់ថ្នាក់ឡើងវិញនូវទិន្នន័យស្តីពីការលក់ដូរដីធ្លីដែលមាននៅក្នុង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ដើម្បីធ្វើវិភាគពីនិន្នាការ និងលំនាំនៃការលក់ដូរដីធ្លី និងស្វែងយល់ពីទិសដៅ និងមូលហេតុនៃការផ្ទេរដីធ្លី ។ ការចុះអង្កេតគំរូតាងតូចមួយត្រូវបានធ្វើឡើងដើម្បីផ្ទៀងផ្ទាត់បញ្ជាក់ពីនិន្នាការ និងលំនាំដែលបានរកឃើញតាមការសិក្សាទិន្នន័យទាំងនេះ ។

សព្វថ្ងៃមិនទាន់មាននៅឡើយទេនូវកំរងទិន្នន័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយល្អ សំរាប់ស្រាវជ្រាវពីទំហំនៃការលក់ដូរដីធ្លី និងមូលហេតុនៃវិសមភាពដែលបានផុសឡើង ។ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៅក្រោមឱវាទ MLMUPC ជាអ្នកកាន់កាប់កំណត់ត្រានៃការលក់ដូរដីធ្លី*ជាផ្លូវការ* គ្រប់ប្រភេទនៅក្នុងប្រទេសកម្ពុជា ហើយមកដល់ថ្ងៃទី៣០ មិថុនា ២០០១ នាយកដ្ឋាននេះមានសរុប ១៥.៧៩៦កំណត់ត្រា ក្នុងនេះ ៨.៩១៥កំណត់ត្រាសំរាប់ដីលំនៅដ្ឋាន និង ៦.៨៨១ កំណត់ត្រាសំរាប់ដីកសិកម្ម ដោយគិតទាំងតំបន់ជនបទ និងទីក្រុង (សំរាប់រយៈពេលពីឆ្នាំ១៩៩៥-២០០១) ។

គួរកត់សំគាល់ដែរថា កំណត់ត្រាទាំងនេះជាប់ទាក់ទងនឹងដីធ្លីមួយចំនួនតូចប្រហែល ៥១៨.០០០ប្លង់ ដែលមានចេញប័ណ្ណប្លង់ដីឱ្យ ។ ដោយហេតុថា ដីធ្លីជិតដល់ ៩០%ត្រូវបានកាន់កាប់ជាលក្ខណៈក្រៅផ្លូវការ ដូច្នេះការលក់ដូរដីធ្លីទាំងនេះគ្មានកត់ចូលក្នុងតួលេខខាងលើទេ ។

## ការលក់ដូរជាផ្លូវការ

បើគិតជាផ្ទៃក្រឡា ពីឆ្នាំ១៩៩៥-២០០១ មានដីកសិកម្ម ១៧.១៤៦ហិកតា(៦.៨៨១ប្រតិបត្តិការលក់ដូរ) និងដីលំនៅដ្ឋាន ១.៣៦២ហិកតា (៨.៩១៥ប្រតិបត្តិការ) ត្រូវបានលក់ដូរជាផ្លូវការ ។ ការលក់/ផ្ទេរដីនៅភ្នំពេញ គ្មានគិតចូលក្នុងតួលេខទាំងនេះទេពីព្រោះ MLMUPC មិនកាន់កាប់ឯកសារផ្ទេរដីនៅភ្នំពេញ ។

ការលក់/ផ្ទេរដីកសិកម្មមានចំនួនច្រើនគួរកត់សំគាល់ពីឆ្នាំ១៩៩៥-៩៧ ដោយឡើងខ្ពស់បំផុតក្នុងឆ្នាំ១៩៩៦ (មាន ២.០១០ ប្រតិបត្តិការទាក់ទិននឹងដី ៥.០៦១ហិកតា) ប៉ុន្តែបន្ទាប់មកបានធ្លាក់ចុះវិញ ។ ចំពោះដីលំនៅដ្ឋាន ក៏មាននិន្នាការប្រហែលគ្នាដែរ៖ ចំនួនប្រតិបត្តិការលក់ដូរមានច្រើនបំផុតក្នុងឆ្នាំ១៩៩៦ (១.៨៧១ប្រតិបត្តិការ) ប៉ុន្តែទំហំផ្ទៃដីលក់កើនខ្ពស់បំផុតក្នុងឆ្នាំ១៩៩៧ (៣០១ ហិកតា ធៀបនឹង ២៧៤ហិកតាក្នុងឆ្នាំ១៩៩៦) ។ ជាទូទៅ គេបានកត់សំគាល់ពីចំណងទាក់ទងយ៉ាងជិតស្និទ្ធរវាងទីផ្សារដីធ្លី និងសកម្មភាពសេដ្ឋកិច្ច ។

ភាគច្រើននៃការលក់ដូរជាផ្លូវការនូវដីកសិកម្មកើតមាននៅក្នុងខេត្ត-ក្រុងធំៗពីរគឺ កណ្តាល និងក្រុងព្រះសីហនុ ចំណែកឯដីលំនៅដ្ឋានវិញគឺនៅក្នុងខេត្តសំខាន់ៗពីរគឺ កណ្តាល និងសៀមរាប ។ ដីកសិកម្មមួយចំនួនធំត្រូវបានកែប្រែទៅជាកន្លែងសង់រោងចក្រ និងដីលំនៅដ្ឋាន ដោយទីក្រុងបានរីកធំហួសពីផ្ទៃដីក្រុងភ្នំពេញ ។ លើសពីនេះទៀត ដីមួយចំនួនធំត្រូវបានទិញទុកដោយគេរំពឹងថានឹងមានរោងចក្រ សកម្មភាពពាណិជ្ជកម្ម កើនច្រើនថែមទៀតក្នុងពេលអនាគត ។ ប៉ុន្តែនៅក្រុងព្រះសីហនុដែលជាប់មាត់សមុទ្រ សភាពការណ៍វាខុសគ្នាបន្តិច ពីព្រោះសកម្មភាពទាក់ទិននឹងពាណិជ្ជកម្មតាមផ្លូវសមុទ្របានទាមទារនូវដីធ្លីមួយចំនួន ។ នៅក្រុងនេះដែរ ដីកសិកម្មមួយចំនួនធំដែលលក់ដូរ គឺបានរានយកពីដីព្រៃដែលឥឡូវនេះបានក្លាយជា "ឧទ្យានជាតិក្បាលឆាយ" ដែលត្រូវការការពារ ។ នៅសៀមរាប គេរំពឹងថានឹងមានការលូតលាស់ដោយសារសក្តានុពលខាងទេសចរ ហើយដីលំនៅដ្ឋានជាច្រើនបានផ្លាស់ប្តូរម្ចាស់ សំរាប់យកទៅសាងសង់សណ្ឋាគារ និងភោជនីយដ្ឋាន ។ នៅក្នុងខេត្តមានទីក្រុងតូចៗ គេមិនឃើញមានការប្រមូលផ្តុំដីធ្លីបែបនេះទេ ។

តាមការសិក្សាគំរូតាងតូចៗ នៅបាត់ដំបងមានការលក់ដូរដីស្រែច្រើនណាស់ក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ប៉ុន្តែកំរងទិន្នន័យផ្លូវការមិនបានឆ្លុះបញ្ចាំងពីរឿងនេះទេ ពីព្រោះពីឆ្នាំ១៩៩៥-២០០១ គេឃើញមានតែ ១១៤ប្រតិបត្តិការលក់ដីកសិកម្មដែលមានទំហំសរុប ១២៨ហិកតាប៉ុណ្ណោះ ហើយតួលេខនេះតំណាងឱ្យតែ ១,៦%នៃការលក់ដីកសិកម្មជាផ្លូវការនៅក្នុងទូទាំងប្រទេសប៉ុណ្ណោះ ។ ពិតណាស់ការលក់ដីកសិកម្មភាគច្រើនមានលក្ខណៈក្រៅផ្លូវការ ។ ចំងាយផ្លូវពីខេត្តមកភ្នំពេញ ថ្លៃដឹកជញ្ជូនខ្ពស់ ចំណាយនានាដែលជាប់ទាក់ទិននឹងការចុះបញ្ជី/ការលក់ដូរជាផ្លូវការ និងការរំខានរុកគួនផ្សេងៗ បានរារាំងដល់កសិករក្នុងការប្រើប្រាស់ប្រព័ន្ធផ្លូវការ ។

ពីឆ្នាំ១៩៩៥-២០០១ អ្នកទិញដីជាច្រើននាក់គឺជាអ្នករស់នៅតាមទីក្រុង ឬខេត្តមានក្រុងធំៗ ។ ក្នុង ៦.៦៣៧ប្រតិបត្តិការលក់ដីកសិកម្មនៅក្រៅក្រុងភ្នំពេញ អ្នករស់នៅក្រុងភ្នំពេញបានចូលរួមក្នុងប្រហែល ៨០%នៃប្រតិបត្តិការ ។ ដូចគ្នាដែរក្នុង ៨.៧៥២ ប្រតិបត្តិការលក់ដីលំនៅដ្ឋាននៅក្រៅក្រុងភ្នំពេញ អ្នករស់នៅក្រុងភ្នំពេញបានចូលរួមក្នុងប្រហែល ៣៩%នៃប្រតិបត្តិការ ។ ស្ថានភាពនេះបានពង្រឹងការប្រមូលផ្តុំធនធាននៅក្នុងដៃអ្នកទីក្រុង ជាពិសេសអ្នកភ្នំពេញ ។ ទោះបីផ្ទៃដីសរុបដែលបានផ្លាស់ប្តូរម្ចាស់មានមិនច្រើនក៏ដោយ ក៏ការលក់ដីធ្លីបានបង្កការបារម្ភថា ប្រជាជនក្រីក្រនៅជនបទនឹងមានការបង់ចាញ់ក្នុងរឿង ទីលំនៅ លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និង គំលាតរវាងអ្នកមាននឹងអ្នកក្រដែលកាន់តែរីកធំឡើង ។

ក្រោយបានឡើងខ្ពស់បំផុតក្នុងឆ្នាំ១៩៩៦ (ដីកសិកម្ម ១៧៥៧ប្លង់ និងដីលំនៅដ្ឋាន ៩២៥ប្លង់) ចំនួនប្រតិបត្តិការលក់ដីធ្លីដែលអ្នកភ្នំពេញចូលរួមបានធ្លាក់ចុះយ៉ាងខ្លាំង ។ ការទិញដីជាផ្លូវការដោយអ្នកភ្នំពេញមានតែ ១៩៨ប្រតិបត្តិការសំរាប់ដីកសិកម្ម និង ៥៣ ប្រតិបត្តិការសំរាប់ដីលំនៅដ្ឋាន ។ ការថយចុះនេះអាចបណ្តាលមកពីការធ្លាក់សកម្មភាពសេដ្ឋកិច្ច កំណើនថ្លៃដី ព្រមទាំងការថយចុះសេចក្តីសង្ឃឹមថានឹងបានចំណេញច្រើនពីការជួញដី ឬការប្រើប្រាស់ដីធ្វើអ្វីផ្សេងៗ ។

ក្នុងចំណោមអ្នកទិញដី មាន ៨៦%ដែលរស់នៅក្នុងស្រុកមួយផ្សេងពីស្រុកនៃទីតាំងដីកសិកម្មបានលក់ដូរ និងមាន ៥០%សំរាប់ករណីដីលំនៅដ្ឋាន ។ ដូចគ្នាដែរ ៤៨%នៃអ្នកលក់ដីគឺរស់នៅក្នុងស្រុកមួយផ្សេងពីស្រុកនៃទីតាំងដីកសិកម្មបានលក់ដូរ ប៉ុន្តែមានតែ ២២%ប៉ុណ្ណោះសំរាប់ករណីដីលំនៅដ្ឋាន ។ ជាការពិតហើយ ដីធ្លីមួយចំនួនត្រូវបានលក់ដូរដើម្បីកេញយកចំណេញ ប៉ុន្តែក៏មានប្រជាជនមួយចំនួនដែរដែលលក់/ទិញដីដើម្បីទៅរស់នៅកន្លែងដែលខ្លួនចូលចិត្ត ។ ដូច្នេះទិន្នន័យទាំងនេះបានបង្ហាញថា ក្នុងចន្លោះឆ្នាំ១៩៩៥-២០០១ ការផ្លាស់ប្តូរនិងការតាំងលំនៅរបស់ប្រជាជនមិនទាន់ចប់សព្វគ្រប់នៅឡើយទេ បន្ទាប់ពីមានការបែកខ្ញែកក្នុងទសវត្សរ៍១៩៧០ និង ១៩៨០ ។

## លទ្ធផលរកឃើញក្នុងអង្កេតសំណាកគំរូតូចៗ

អង្កេតសំនាកគំរូតូចមួយដែលប្រើវិធីសិក្សាបរិមាណ និងវិធីសិក្សាគុណភាព ត្រូវបានធ្វើឡើងនៅខេត្តប្រាំគឺ កណ្តាល កំពង់ចាម កំពង់ស្ពឺ បាត់ដំបង និងក្រុងព្រះសីហនុ ។ អ្នកឆ្លើយសំភាសន៍មាន ការិយាល័យសុរិយោដីស្រុក មេឃុំ និងបុគ្គលនានាដែលដឹងរឿងនេះ ។

អ្នកឆ្លើយសំភាសន៍បាននិយាយថា ក្នុងឃុំ-ស្រុកភាគច្រើន ការលក់ដូរដីកើនខ្ពស់បំផុតនៅឆ្នាំ១៩៩៦ ។ និន្នាការដែលអ្នកឆ្លើយសំភាសន៍បានប្រាប់ គឺស្របគ្នានឹងនិន្នាការដែលទិន្នន័យផ្លូវការបានឆ្លុះបង្ហាញៈ ការលក់ដូរដីធ្លី ទាំងផ្លូវការនិងក្រៅផ្លូវការបានស្ទុះឡើងយ៉ាងខ្លាំងនៅដើមទសវត្សរ៍១៩៩០ ហើយអ្នកក្រៅចាប់ផ្តើមទិញដីធ្លីក្នុងឆ្នាំ១៩៩៣-៩៤ ។ ការទិញដីដោយអ្នកក្រៅក្នុងឆ្នាំ១៩៩៥ ជាពិសេសអ្នកភ្នំពេញ និងអាជីវករបរទេស បាននាំឱ្យមាន "ឥទ្ធិពលមេគុណ" យ៉ាងធំធេងនៅក្នុងទីផ្សារដីធ្លី ដោយសារប្រជាជនជាច្រើនបានលក់ដីរបស់ខ្លួនទៅទិញដីមានតំលៃថោកជាងនៅឯកន្លែងផ្សេង ។

មូលផលដ៏ច្បាស់មួយដែលធ្វើឱ្យការលក់ដូរដីធ្លីត្រូវបានអនុវត្តតាមផ្លូវការឬមិនផ្លូវការ គឺលក្ខណៈដែលដីនោះបានចុះបញ្ជីរួច ឬមិនទាន់ចុះ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង មានឯកសារពីរប្រភេទដែលគេប្រើប្រាស់សំរាប់បញ្ជាក់កម្មសិទ្ធិដីៈ បង្កាន់ដៃ និងប័ណ្ណប្លង់ដី ។ ការលក់ដីដែលមានប័ណ្ណប្លង់ដី តំណាងឱ្យតែមួយភាគតូចនៃការលក់ដូរសរុបប៉ុណ្ណោះ ។ ការចុះសំភាសដល់កន្លែងបានបង្ហាញថា គ្រួសារជាច្រើនគ្មានទាំងបង្កាន់ដៃសំរាប់ដីធ្លីខ្លួនផង ក្នុងនេះម្ចាស់ដីមួយចំនួនបានធ្វើបាត់បង្កាន់ដៃ ឯអ្នកខ្លះទៀតមិនបានដាក់ពាក្យសុំទេ ព្រោះមិនបានដឹង ឬមានការច្របូកច្របល់មិនដឹងដាក់ពាក្យនៅកន្លែងណា ។ អាជ្ញាធរក៏មានការខ្វះខាតមិនបានក្រើនរំលឹកម្ចាស់ដីឱ្យដាក់ពាក្យសុំដែរ ។ រឿងមួយទៀតគឺដីធ្លីជាច្រើនកន្លែងត្រូវបានពុះចែកជាច្រើនចំណែកក្នុងពេលសព្វថ្ងៃ ដូច្នេះហើយបង្កាន់ដៃដើមក៏គ្មានប្រយោជន៍អ្វីទៀត ។

ប្រតិបត្តិការលក់/ផ្ទេរដីដោយមានការឯកភាពយល់ព្រមពីមេឃុំ ឃើញមានច្រើនជាងគេ ។ អាជ្ញាធរសុរិយោដីស្រុកបានទទូចឱ្យថ្នាក់ឃុំរាយការណ៍ពីការលក់ដូរដីធ្លីទាំងអស់ឱ្យខ្លួន ទោះបីតាមគោលការណ៍គឺទាល់តែការលក់ដូរជាផ្លូវការនូវដីមានប័ណ្ណប្លង់ដី ទើបត្រូវរាយការណ៍ជាផ្លូវការ ។ ប៉ុន្តែរបាយការណ៍បែបនេះមិនសូវមានធ្វើញឹកញាប់ទេ គឺផ្ទុយទៅវិញមេឃុំគ្រាន់តែចុះហត្ថលេខា និងបោះត្រាលើលិខិតកិច្ចព្រមព្រៀងគឺជាការស្រេច ។ វិធីនេះប្រជាជនជាច្រើនយល់ថាវា "ផ្លូវការគ្រប់គ្រាន់" ហើយសំរាប់បញ្ជាក់ការផ្ទេរកម្មសិទ្ធិ ហើយពួកគេ ឬមួយមិនបានយល់ពីនីតិវិធីត្រឹមត្រូវ ឬមួយយល់ថាគ្មានប្រកអ្វីផ្សេងទោះបីនីតិវិធីបែបនេះមិនគ្រប់គ្រាន់ក៏ដោយ ។ នៅពេលខ្លះ ការលក់ដីធ្លីដែលមានប័ណ្ណប្លង់ដីត្រឹមត្រូវក៏មិនបានអនុវត្តដូចក្នុងច្បាប់ដែរ ពីព្រោះអ្នកទិញមិនចង់បង់ពន្ធប្រថាប់ត្រា ព្រមទាំងចង់រំលងនីតិវិធីដ៏ស្មុគស្មាញផ្សេងៗផង ។

ការិយាល័យសុរិយោដីស្រុកទទួលខុសត្រូវក្នុងការកំណត់ថ្លៃដីដើម្បីយកពន្ធដែលត្រូវស្មើនឹង ៤% នៃថ្លៃលក់ដី ។ ក្នុងការអនុវត្តន៍ជាក់ស្តែង មានការគេចពន្ធមួយចំនួនធំតាមវិធីរាយការណ៍បន្ទាបថ្លៃដី ។ ទំហំនៃការលាក់ថ្លៃដីប្រែប្រួលពីខេត្តមួយទៅខេត្តមួយ ហើយជាមធ្យមក្នុងឯកសារផ្លូវការគេកត់ត្រាប្រហែលតែ ៤០% នៃថ្លៃដីពិត ដូច្នេះប្រាក់ពន្ធត្រូវបាត់អស់ប្រហែល ៦០% ។ ការរាយការណ៍បន្ទាបថ្លៃដី គឺធ្វើឡើងតាមការឃុបឃិតគ្នារវាងភាគីជាប់ពាក់ព័ន្ធផ្សេងៗ ហើយរបៀបរបបនេះត្រូវបានសំរួលតាមរយៈការបង់ប្រាក់កំរៃក្រៅផ្លូវការ ។ នៅពេលឯកភាពគ្នារួចហើយ មន្ត្រីសុរិយោដីធ្វើការគណនាបញ្រ្ចាសវិញដើម្បីរកថ្លៃដីដែលត្រូវផ្តល់ប្រាក់ពន្ធ ៤% ឱ្យស្មើនឹង ទឹកប្រាក់ជាក់ស្តែងដែលគេបានបង់ចូលរតនាគារខេត្ត ។

ទោះបីប្រជាជនមិនបានបង់ពន្ធពេញលេញដូចការកំណត់ក្នុងច្បាប់ក៏ដោយ ក៏អ្នកឆ្លើយសំភាសន៍បានរាយការណ៍ថា ពន្ធប្រថាប់ត្រាបានធ្វើឱ្យប្រជាជនរាថយក្នុងការប្រើវិធីផ្ទេរកម្មសិទ្ធិជាផ្លូវការ ។ គេទទួលស្គាល់ជាទូទៅដែរថា ប្រជាជនជាច្រើនមិនចង់បានប័ណ្ណប្លង់ដីទេដោយសារដីធ្លីចុះបញ្ជីពិបាកលក់ ព្រោះត្រូវជាប់ពន្ធ ។

ឯកសារនេះមានបង្ហាញពីដំណើរការ និងរបៀបរបបអនុវត្តន៍ជាច្រើន ទោះបីត្រឹមត្រូវតាមច្បាប់ ឬមិនសូវត្រឹមត្រូវក្តី សំរាប់ការ លក់ដូរដីធ្លីនៅក្នុងតំបន់ជនបទកម្ពុជា ។ ឯកសារក៏ចង្អុលបង្ហាញផងដែរពីតំរូវការពង្រឹងការិយាល័យសុរិយោដី និងតំរូវការកាន់កាប់ថែ រក្សាកំណត់ត្រាផ្សេងៗឱ្យមានលក្ខណៈជាប្រព័ន្ធ និងសព្វគ្រប់ ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| DFID | នាយកដ្ឋានសំរាប់អភិវឌ្ឍន៍អន្តរជាតិ - ចក្រភពអង់គ្លេស (Department for International Development – United Kingdom) |
| GDCG | អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (General Department of Cadastre and Geography) |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (Ministry of Land Management, Urban Planning and Construction) |
| OXFAM-GB | អុកស្វាម ចក្រភពអង់គ្លេស (Oxfam—Great Britain) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| SES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ច (Socio-economic Survey) |
| WFP | អង្គការស្បៀងអាហារពិភពលោក (World Food Programme) |

# សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាពិសេស នាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម ចំពោះកិច្ចសហប្រតិបត្តិការក្នុងការរៀបចំកំរងទិន្នន័យដែលបានលើកយកមកពិភាក្សានៅក្នុងផ្នែកទី៣ និងទី៤ និងសូមថ្លែងអំណរគុណដល់ នាយកដ្ឋានសំរាប់អភិវឌ្ឍន៏អន្តរជាតិ (DFID) នៃប្រទេសអង់គ្លេស ចំពោះអំណោយមូលនិធិសំរាប់ការស្រាវជ្រាវនេះ ។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់ លោកស្រី ទេព សារ៉ាវី ចំពោះការជួយកែតំរូវទិន្នន័យ និងការរៀបចំតារាងក្នុងជំហានដំបូង ហើយយើងខ្ញុំក៏សូមថ្លែងអំណរគុណដល់លោក គីម សេតារា និងលោក សូ សុវណ្ណារិទ្ធិ ដែលបានជួយធ្វើសំភាសន៏មួយចំនួនដូចមានបង្ហាញជូននៅក្នុង ផ្នែកទី៥ ។ អ្នកនិពន្ធសូមអរគុណផងដែរដល់ថ្នាក់ដឹកនាំ វបសអ ជាពិសេស លោកស្រី អេវ៉ា មីស្លីវិក ចំពោះការជួយផ្តល់យោបល់នៅលើឯកសារពង្រាងលើកដំបូង និងការជួយគាំទ្រក្នុងគ្រប់ដំណាក់កាលនៃការសិក្សាស្រាវជ្រាវ ។

*រាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០០២*

*ច័ន្ទ-សុផល និង* Sarthi Acharya

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា*

# ជំពូក ១

# សេចក្តីផ្តើម

វិសមភាពក្នុងការបែងចែកដីធ្លី និងភាពគ្មានដីកសិកម្ម មានកំរិតគួរឱ្យកត់សំគាល់នៅក្នុងប្រទេសកម្ពុជា ។ អត្រា អិនិ នៃ វិសមភាពក្នុងការបែងចែកដីធ្លីកសិកម្ម មានកំរិតដល់ទៅ 0,៦ បើផ្អែកតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ១រប្រែប ឆ្នាំ១៩៩៧ និង ១៩៩៩ ។ អត្រាភាពអត់ដីធ្លីមានកំរិតដល់ទៅ ១៥-២0% នៅក្នុងតំបន់ជនបទ ដោយសារប្រជាជនមួយចំនួនធំបានផ្លាស់ទីលំនៅពីតំបន់មួយទៅតំបន់មួយក្នុងទសវត្សរ៍១៩៩0 ដោយមានខ្លះបានឆ្លងប្រទេស ដើម្បីស្វែងរកការចិញ្ចឹមជីវិតឱ្យមានស្ថិរភាព និងសុវត្ថិភាព[១] ។ ទោះបីជាដីត្រូវបានបែងចែកជាថ្មី ប្រកបដោយសមភាពនៅចុងទសវត្សរ៍១៩៨0ក៏ដោយ ក៏ភាពអត់ដីនៅតែមានកំរិតខ្ពស់[២] ។

ការផ្ទេរកម្មសិទ្ធិដីធ្លីធំៗ និងការច្រៀកបែងចែកដីជាបន្ត បានកើតឡើងនៅក្នុងទសវត្សរ៍១៩៩0 ដោយសារកំណើនប្រជាជន និងមូលហេតុផ្សេងទៀត ។ កន្លងមក ក្រៅពីស្ថិតិប្រជាសាស្ត្រ គ្មានទិន្នន័យសព្វជ្រុងជ្រោយណាមួយដើម្បីបញ្ជាក់ពីមូលហេតុដែលធ្វើឱ្យមានវិសមភាពខ្ពស់កើតឡើងក្នុងរយៈពេលខ្លីបែបនេះឡើយ ។ តាមពិត អង្កេតទ្រង់ទ្រាយធំលើកដំបូងដែលប្រមូលបានពត៌មានខ្លះៗអំពីដីធ្លីគឺ SES ក្នុងឆ្នាំ១៩៩៧ ។ បន្ទាប់មក SES ត្រូវបានធ្វើឡើងជាលើកទី២ ក្នុងឆ្នាំ១៩៩៩ ។ ក្នុងករណីដីលំនៅដ្ឋាន ភាពគ្មានដីមិនមែនជាវិបត្តិមួយទេ ក៏ប៉ុន្តែ វិសមភាព និងកង្វះខាតសិទ្ធិកាន់កាប់ គឺជាវិបត្តិ ។ យោងតាម SES ឆ្នាំ១៩៩៩ តួលេខ Gini នៃវិសមភាពក្នុងការកាន់កាប់ដីលំនៅដ្ឋានគឺ 0,៦៨ ។

ភាពគ្មានដីកសិកម្ម និងវិសមភាពកម្មសិទ្ធិដីធ្លី បានក្លាយជាបញ្ហាចោទមួយនៅក្នុងប្រទេសកម្ពុជា ពីព្រោះក្នុងសេដ្ឋកិច្ចពុំមានមុខរបរចំរុះគ្រប់គ្រាន់ទេ ។ កំលាំងពលកម្មជាង ៧៥% នៅតែពឹងផ្អែកលើដីធ្លីសំរាប់ការរស់រានមានជីវិត ។ ពួកកសិករគ្មានដីដែលគេឃើញមាននៅក្នុងប្រទេសអាស៊ីជាច្រើន គឺសឹងតែគ្មានទេនៅកម្ពុជាបើយោងតាមជំរឿនប្រជាជនឆ្នាំ១៩៩៨ ។ មូលហេតុគឺប្រហែលមកពី ទំរង់នៃកសិកម្មមិនអនុញ្ញាតឱ្យមានប្រភេទពលករដែលអាចរស់បានជាអចិន្ត្រៃយ៍ ដោយសារការលក់ពលកម្មនៅក្នុងវិស័យកសិកម្ម[៣] ។ ជាលទ្ធផល ពលករគ្មានជំនាញដែល"ឈរជើងមិននឹង"ទាំងនេះ ងាយនឹងធ្លាក់ចុះក្រោមបន្ទាត់ក្រីក្រ ។ រឿងនេះបណ្តាលមកពីប្រាក់កំរៃជាទូទៅត្រឹម ៤.000-៥.000រៀលក្នុងមួយថ្ងៃសំរាប់ពលកម្មគ្មានជំនាញ វាមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់ជីវភាពទេ។ លទ្ធភាពមានការងារធ្វើតិចថ្ងៃក្នុងមួយខែៗ រឹតតែបង្កឱ្យមានបញ្ហាធ្ងន់ធ្ងរថែមទៀត ។ ការស្វែងរករបរចិញ្ចឹមជីវិត

---

[១] មានឯកសារជាច្រើនស្តីអំពីប្រធានបទនេះ ។ ទិន្នន័យថ្មីៗបំផុតមាននៅក្នុងឯកសារ Chan *et al* 2001 និង So *et al* 2001 ។

[២] ឯកសារ Sik 2001 ផ្តល់នូវភស្តុតាងអំពីបញ្ហានេះ ។

[៣] ដើម្បីប្រើប្រាស់ពលករប្រភេទនេះ គេត្រូវមានធាតុចូលផ្សេងៗដូចជា សត្វចិញ្ចឹម គ្រឿងម៉ាស៊ីន និងវត្ថុធាតុផ្សេងៗខាងជីវសាស្ត្រ និងគីមី ព្រមទាំងធ្វើការដាំដុះតាមបែបប្រពលវប្បកម្មលើសពីមួយដងក្នុងមួយឆ្នាំ ។ នៅឥណ្ឌូនេស៊ី និងហ្វីលីពីន និងនៅតំបន់ភាគច្រើននៃអាស៊ីខាងត្បូង វិស័យកសិកម្មអាចផ្តល់ការងារឱ្យពលករជាច្រើននាក់ រួមទាំងកសិករគ្មានដីផង ព្រោះកសិកម្មក្នុងប្រទេសទាំងនោះមានលក្ខណៈប្រពលវប្បកម្មខ្លាំង ។ សូមអានឯកសារ Ghose 1983 ។

បានបង្ខំឱ្យប្រជាជនឃ្លាតឆ្ងាយពីផ្ទះសំបែង ហើយពលករពនេចរក្រីក្រទាំងនេះបានចូលមកក្នុងទីក្រុងយ៉ាងសន្ធឹកសន្ធាប់ ។ ក្រៅពីស្ថានភាពក្រីក្ររបស់បុគ្គលខ្លួនឯង ភាពអត់ដីធ្លីក៏ ជាប់ទាក់ទិននឹងកត្តាខាងនយោបាយផងដែរ ។ ចំណុចគួរព្រួយបារម្ភទាំងនេះ បានចោទជាសំណួរមួយថា តើភាពគ្មានដីធ្លីបានកកើតឡើង ដោយសារដំណើរការយ៉ាងដូចម្ដេច?

ឯកសារនេះមិនអាចផ្ដល់ចម្លើយពេញលេញ និងសព្វជ្រុងជ្រោយទៅនឹងសំនួរដែលថា តើវិសមភាពកម្មសិទ្ធិដីធ្លីបានកើតឡើង យ៉ាងដូចម្ដេច និងដោយសារមូលហេតុអ្វីនោះទេ ប៉ុន្តែនេះជាការប៉ុនប៉ងជំហានដំបូងមួយដើម្បីប្រមូល និងចងក្រងពត៌មានស្តីអំពីការជួញដូរដីធ្លី ក្នុងគោលបំណងបង្កើតឡើងនូវការយល់ដឹងជាបឋមពីទំហំបញ្ហា ។ ឯកសារនៃការទិញលក់ដីជាផ្លូវការក្នុងរយៈពេលពីឆ្នាំ១៩៩៥ ដល់ ២០០១ មាននៅអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ វបសអ បានបញ្ចូលទិន្នន័យទាំងនេះទៅក្នុងកំព្យូទ័រ ក្នុងគោលបំណង ជួយដល់ក្រសួងក្នុងការបង្កើតប្រព័ន្ធឯកសារ ព្រមទាំងសិក្សាពីនិន្នាការឬសណ្ឋាននៃការលក់ដូរដីធ្លីដែលអាចគេសន្និដ្ឋានបានដោយផ្អែកលើទិន្នន័យទាំងនេះ ។ ប៉ុន្តែគួរមានសេចក្ដីបញ្ជាក់ជាមុនថា ការវិភាគនេះប្រហែលមិនអាចផ្ដល់លទ្ធផលដែលមានន័យគ្រប់គ្រាន់ល្អទេ ពីព្រោះគំរូតាងមិនត្រូវបានជ្រើសរើសតាមវិធីចៃដន្យ ហើយមិនអាចតំណាងបានប្រសើរទេសំរាប់ការងារខាងស្ថិតិ ។ ដូច្នេះហើយ ឯកសារនេះបានត្រឹមបង្ហាញច្បោលៗនូវលំនាំ និងនិន្នាការមួយចំនួន តាមរយៈតារាង និងការពន្យល់ខ្លះៗប៉ុណ្ណោះ ។ បន្ទាប់មក ឯកសារនឹងពិភាក្សាពីលទ្ធផលនៃការសិក្សាខ្នាតតូចមួយតាមបែបគុណភាពដែលពិនិត្យមើលពីដំណើរការនៃទីផ្សារដីធ្លីនៅក្នុងឃុំ-ស្រុកខ្លះៗ នៃខេត្តមួយចំនួនដែលមានសកម្មភាពទីផ្សារដីធ្លីខ្លាំង ។

ផ្នែកបន្ទាប់នេះផ្ដល់នូវការពិនិត្យត្រួសៗពី ស្ថានភាពដីធ្លីដូចមានចុះនៅក្នុងពត៌មាន និងឯកសារដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនិយាយត្រឹមតែដីកសិកម្មប៉ុណ្ណោះ។ ផ្នែកទី៣ និងទី៤ ពិពណ៌នាពីទិន្នន័យបានមកពី អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដែលផ្ដោតលើទាំងដីកសិកម្ម និងដីលំនៅដ្ឋាន ។ ផ្នែកទី៥ បង្ហាញពីលទ្ធផលដែលបានមកពីការសិក្សាដល់ទីកន្លែង និងដែលនិយាយអំពីដីធ្លីទាំងអស់ជាទូទៅ ។ ផ្នែកចុងក្រោយ គឺជាសេចក្ដីសន្និដ្ឋានបញ្ចប់ ។ ឯកសារនេះ ត្រូវបានសរសេរឡើងតាមរបៀបរបបមួយដែលប្លែកពីធម្មតា ពីព្រោះផ្នែកទី២ ទី៣ ទី៤ និងទី៥ មិនពឹងផ្អែកលើគ្នាទៅវិញទៅមកទេ ។ សូម្បីតែតំបន់គ្របដណ្ដប់ក៏មិនត្រូវគ្នានៅក្នុងគ្រប់ផ្នែកដែរ ។ ជាក់ស្ដែងឯកសារនេះបានពិនិត្យនូវ កំរងទិន្នន័យ/ពត៌មាន បីផ្នែកផ្សេងគ្នា ដើម្បីស្វែងយល់អំពីស្ថានភាពទីផ្សារដីធ្លី ។ ការធ្វើដូច្នេះគឺមកពីគ្មានប្រភពទិន្នន័យទោលណាមួយដែលអាចពន្យល់ពេញលេញអំពីស្ថានភាពទីផ្សារដីធ្លីនៅក្នុងប្រទេសកម្ពុជាឡើយ ។

# ជំពូក ២

# ទីផ្សារដីធ្លី វិសមភាព និងភាពគ្មានដីនៅកម្ពុជា: ការពិនិត្យឯកសារដែលមានស្រាប់

## ២.១ ប្រវត្តិសាស្ត្រកម្ពុជាក្នុងពេលថ្មីៗទាក់ទិននឹងទីផ្សារដីធ្លី

### *២.១.១. កំរងព្រឹត្តិការណ៍*

គេអាចឆ្ងល់ខ្លាំងអំពីដំណើរការដែលវិសមភាពកម្មសិទ្ធិដីធ្លី និងភាពគ្មានដីធ្លី បានកើនឡើងខ្ពស់បែបនេះតែក្នុងប្រហែលមួយទសវត្សរ៍ ។ អាចមានកត្តាមួយចំនួនសំរាប់ពន្យល់ពីវិសមភាពនេះ ។ ចំណុចចាប់ផ្តើមក្នុងការខិតខំស្វែងយល់ អាចជាការពិពណ៌នាអំពីការវិវឌ្ឍន៍ក្នុងប្រវត្តិសាស្ត្រនៃប្រព័ន្ធគ្រប់គ្រងដីធ្លីដែលមានជាសំខាន់នៅក្នុងប្រទេសកម្ពុជា ។

មុនសម័យអាណានិគម ដីគឺជាកម្មសិទ្ធិរបស់ស្តេច ប៉ុន្តែប្រជាជនអាចបង្កបង្កើនផលលើដីតិចច្រើនតាមប្រាថ្នា ។ ដោយសារកង្វះខាតមធ្យោបាយផលិតកម្ម គ្រួសារនីមួយៗកាន់កាប់ដីមិនលើសពី ១-៣ហិកតាឡើយ ។ ដោយមានប្រជាជនតិច គឺពុំមានកង្វះខាតដីធ្លីទេ ដូច្នេះទីផ្សារដីធ្លីក៏គ្មាន ហើយកសិករអាចចល័តពីកន្លែងមួយទៅកន្លែងមួយ និងអាចចាប់យកដីជាកម្មសិទ្ធិ ។ ម្ចាស់កម្មសិទ្ធិមានសិទ្ធិកាន់កាប់ប្រើប្រាស់ និងបន្តមរតកដីកសិកម្ម ដោយមិនចាំបាច់បំពេញសំណុំបែបបទផ្លូវការអ្វីក្រៅពីការបង់ សួយសារសក្តិភូមិតូចមួយនោះឡើយ (Thion 1993) ។ ពីចុងទសវត្សរ៍១៨០០ ដល់ទសវត្សរ៍១៩៣០ អាណានិគមបារាំងបាន ព្យាយាមបង្កើតប្រព័ន្ធកម្មសិទ្ធិឯកជន និងកម្មសិទ្ធិដីធ្លីជាផ្លូវការ ប៉ុន្តែមិនបានទទួលជោគជ័យទាំងស្រុងទេ ។ មានការជឿនលឿនមួយចំនួនដែរនៅក្នុងតំបន់ទំនាបធ្វើស្រែ ប៉ុន្តែតំបន់មួយចំនួនធំក្រៅពីតំបន់ទំនាប (ឧ. តំបន់ព្រៃ ខ្ពង់រាប និងតំបន់កសិកម្មពនេចរ) គឺត្រូវបានរំលងចោល ។ ក្នុងសម័យក្រោយអាណានិគម (១៩៥៣-១៩៧៥) កម្ពុជាបានប្រើប្រាស់ប្រព័ន្ធដីធ្លីដូចគ្នានឹងប្រព័ន្ធដែលបារាំងបានដាក់អនុវត្ត ប៉ុន្តែដូចមុនដែរបានទទួលជោគជ័យមួយក៏រិតប៉ុណ្ណោះក្នុងការកំណត់លេខកូដដីធ្លី ការធ្វើឯកជនភាវូបនីយកម្ម និងការធ្វើពាណិជ្ជភាវូបនីយកម្មដីធ្លី ។ របបខ្មែរក្រហម (១៩៧៥-១៩៧៩) បានដាក់ដីធ្លីទាំងអស់ជាកម្មសិទ្ធិសមូហភាព។ ការធ្វើឯកជនភាវូបនីយកម្មបានដំណើរការជាថ្មីក្នុងឆ្នាំ១៩៨៤-៨៥ និងត្រូវបានអនុញ្ញាតជាផ្លូវការក្នុងឆ្នាំ១៩៨៩ ។ តាំងពីពេលនោះមក កសិករ និងពលរដ្ឋមិនមែនកសិករ អាចកាន់កាប់ដីធ្លីជាឯកជនបាន ឱ្យប្រើប្រាស់ដីនោះ ។ ដីមិនបានប្រើប្រាស់អស់រយៈពេល ៣ឆ្នាំ ត្រូវក្លាយជាកម្មសិទ្ធិរដ្ឋវិញ ។

គេប៉ាន់ស្មានថា នៅពាក់កណ្តាលសតវត្សទី១៩ ប្រជាជនមានចំនួនមិនលើសពី ១លាននាក់ឡើយ ហើយបានកើនដល់ប្រហែល ៤-៥លានប៉ុណ្ណោះនៅឆ្នាំ១៩៦០ (Chandler 1993) ។ នៅដើមទសវត្សរ៍១៩៨០ ប្រជាជនមានប្រហែល ៦លាននាក់

ហើយដីធ្លីមានចំនួនគ្រប់គ្រាន់សំរាប់សេដ្ឋកិច្ចបិទ និងផលិតដើម្បីបង្គ្រប់ការបរិភោគ (ជីវព្រឹត្តិ) ដែលពឹងផ្អែកលើផលិតកម្មប្រើដីធំទូលាយ ។ ចាប់ពីពេលនោះមក ប្រជាជនបានកើនយ៉ាងឆាប់ ឡើងដល់ជាង ១១លាននាក់ក្នុងឆ្នាំ១៩៩៨ ។ ក្នុងពេលជាមួយគ្នា សេដ្ឋកិច្ចបិទ បានចាប់ផ្តើមធ្វើចំរុះវប្បកម្ម និងបើកចំហ ទោះបីជាមិនបានស្មើគ្នាគ្រប់ទីកន្លែងក៏ដោយ ។ កត្តាទាំងពីរ នៃកំណើនប្រជាជន និងការពង្រីកសេដ្ឋកិច្ច បានដាក់កំហិតទៅលើបរិមាណដីធ្លី ។

### *២.១.២. ស្ថានភាពនៃទីផ្សារដីធ្លី*

ក្នុងរយៈពេលជាង ១០០ឆ្នាំកន្លងមក ការវិវត្តន៍នៃទីផ្សារដីធ្លី និងការកំណត់ដីជាវត្ថុទិញដូរ បានដំណើរការទៅយឺតៗ និងមិនបានស្មើគ្នាគ្រប់កន្លែងទេ ។ នៅក្នុងតំបន់ខ្លះ (ឧទាហរណ៍ តំបន់វាលស្រែធំៗ នៅជុំវិញបឹងទន្លេសាប) ការធ្វើកសិកម្មមិនផ្លាស់ ទីបានចាក់ឫសយ៉ាងរឹងមាំ[១] ។ ប៉ុន្តែនៅក្នុងតំបន់ថ្មីៗដែលគេបើកឱ្យធ្វើកសិកម្ម ក៏ដូចជាតំបន់នៅក្រៅកន្លែងមានពាណិជ្ជកម្ម និង /ឬ មានប្រជាជនរស់នៅច្រើន ទំលាប់ចាស់នៃការទាមទារកម្មសិទ្ធិដីធ្លីតាមរយៈការកាប់រំលំដើមឈើនៅតែមាននៅឡើយ ។ គេចាប់យកដីទាំងនេះជាមុន ទើបមានការដាក់ពាក្យទៅអាជ្ញាធរដើម្បីសុំកម្មសិទ្ធិស្របច្បាប់ ឬជួនកាលមិនទាំងបានដាក់ពាក្យ សុំផង ។ កសិកម្មពនេចរដែលជាមុខរបរចំបងមួយមានអនុវត្តយ៉ាងច្រើននៅតាមសហគមន៍ប្រជាជនដើម នៅភាគឦសាន ។ ក្នុងតំបន់ទាំងនេះ គោលគំនិតនៃកម្មសិទ្ធិទ្រព្យសម្បត្តិគឺផ្អែកលើសហគមន៍ មិនមែនលើឯកជនទេ ។ ក្នុងតំបន់ព្រៃឈើ មានភូមិ មួយចំនួនដែលប្រជាជនបន្តធ្វើកសិកម្មពនេចរ ក៏ដូចជាកាប់ឈើ និងប្រមូលផលិតផលព្រៃឈើផ្សេង ទៀត[២] ហើយនៅទីនោះ សកម្មភាពទីផ្សារនៅខ្សោយ ឬក៏គ្មានតែម្តង ។

សរុបមក ទីផ្សារដីធ្លីបានចាប់ផ្តើមកើតឡើងនៅក្នុងតំបន់មួយចំនួនដែលមានពាណិជ្ជភាវូបនីយកម្ម ឬនគរូបនីយកម្ម និងមានដង់ស៊ីតេប្រជាជនខ្ពស់ ។ ឯនៅកន្លែងផ្សេងទៀត ទីផ្សារដីធ្លីនៅមិនទាន់អភិវឌ្ឍន៍នៅឡើយ ។ ការពិនិត្យបន្ថែមបង្ហាញថា ទីផ្សារទាំងនេះមិនទាន់មានដំណើរការល្អទេ ។ ទីផ្សារភាគច្រើន គ្មានលក្ខណៈត្រឹមត្រូវ ពីព្រោះខ្វះខាតព័ត៌មាន ឥរិយាបថរបស់ប្រជាជននៅចាក់ឫសក្នុងប្រព័ន្ធផលិតដើម្បីគ្រប់ហូប ហើយយន្តការគ្រប់គ្រងនៅខ្សោយជួនកាលប្រកាន់បក្សពួកផង ។ ដូច្នេះអ្នកតូចតាច និងទន់ខ្សោយនៅក្នុងទីផ្សារ អាចចាញ់ប្រៀបយ៉ាងធ្ងន់ធ្ងរ នៅចំពោះមុខអ្នកមានកំលាំង (So *et al* 2001) ។

## ២.២. ការប្រែប្រួលកម្មសិទ្ធិដីធ្លី និងភាពគ្មានដី

ការធ្វើឯកជនភាវូបនីយកម្មដីធ្លីក្នុងឆ្នាំ១៩៨៩ បានដំណើរការទៅដោយគ្មានការធ្វើផែនទីសុរិយោដីលំអិត និងគ្មានការផ្តល់ប័ណ្ណប្លង់ដីទេ ។ ជាលទ្ធផល ព្រំប្រទល់ក្រៅផ្លូវការដែលបែងចែកដីឡូត៍នីមួយៗ និងការឯកភាពគ្នារវាងម្ចាស់កម្មសិទ្ធិ គឺជាមធ្យោបាយតែមួយគត់សំរាប់បង្កើតនិងកំណត់កម្មសិទ្ធិដីធ្លីឯកជន[៣] ហើយប្រព័ន្ធនេះអាចដំនើរការបានជាធម្មតានៅក្នុងសេដ្ឋកិច្ចបិទដែលមានការផលិតសំរាប់តែគ្រប់ហូប និងដែលមានដង់ស៊ីតេប្រជាជនតិច ។ ប៉ុន្តែការធ្វើឯកជនភាវូបនីយកម្មដីធ្លីបានដំនើរការក្នុងពេលជាមួយគ្នានឹងការចាប់យកសេដ្ឋកិច្ចទីផ្សារនៅឆ្នាំ១៩៩១ ដែលនាំឱ្យមានការហូរចូលមូលធនបរទេសដូចជាក្នុងវិស័យព្រៃឈើ និងកាត់ដេរ ហើយប្រជាជនបានកើនឡើងយ៉ាងឆាប់រហ័ស ។ ដូចបានកត់សំគាល់ខាងលើ នៅឆ្នាំ១៩៩៨ កម្ពុជាមានប្រជាជនជាង ១១លាននាក់ ។ អ្នកទីក្រុង ជនបរទេស និងសហគ្រិនដែលមានប្រាក់ បានចាប់ផ្តើមទិញដីសំរាប់ធ្វើពាណិជ្ជកម្ម កសិកម្ម ការកាប់ឈើ និងសកម្មភាពក្រៅពីកសិកម្មផ្សេងទៀត រួមទាំងការទិញដីទុកលក់យកចំណេញផងដែរ ។ ជាលទ្ធផល ដីបានក្លាយជាវត្ថុដែលអ្នកពាក់ព័ន្ធជាច្រើនមានតំរូវការសំរាប់គោលដៅផ្សេងៗគ្នា ។ អ្នកខ្លះបានទិញដីជាផ្លូវការ ខ្លះទៀតបាន

---

[១] ប៉ុន្តែ ទោះនៅតំបន់ទាំងនោះក៏ដោយ ក៏ទំលាប់ជាប្រពៃណីក្នុងការកាន់កាប់ និងគ្រប់គ្រងដីធ្លី នៅតែបន្តអនុវត្តយ៉ាងច្រើន ។

[២] ប៉ុន្តែអ្នកភូមិកាន់តែត្រូវបានម្ចាស់ព្រៃសម្បទានហាមឃាត់មិនឱ្យកាប់ឈើ ឬមិនឱ្យចូលព្រៃ ។

[៣] អាជ្ញាធរបានបញ្ជាក់ថា មូលហេតុដែលមិនបានវាស់វែងដីធ្លីឱ្យបានត្រឹមត្រូវគឺកង្វះខាតធនធាននៅក្នុងពេលនោះ ។

ប្រើមធ្យោបាយក្រៅផ្លូវការ ។ ក្នុងតំបន់មួយចំនួន តំរូវការកើនលើសពីការផ្គត់ផ្គង់ ដែលធ្វើឱ្យដីឡើងថ្លៃយ៉ាងខ្លាំង ។

ក្នុងវិស័យកសិកម្ម កំណើនសមាហរណកម្មជាមួយទីផ្សារក្នុងតំបន់ ទោះបីជាមិនបានគ្រប់កន្លែងក៏ដោយ ក៏បានបង្កើតនូវតំរូវការខ្ពស់នូវធាតុចូលកសិកម្មទំនើប (modern farm inputs) ។ ជាលទ្ធផល មានការប្រើប្រាស់កាន់តែច្រើននូវជីគីមី ថ្នាំសំលាប់សត្វល្អិត និងធាតុចូលផ្សេងទៀតដែលត្រូវចំណាយថវិកា ។ មានកត្តាពីរយ៉ាងតិច ដែលបានជះឥទ្ធិពលអវិជ្ជមានដល់កសិករ ។ ទី១ ឥណទានបែបស្ថាប័នមានតិចតួចណាស់សំរាប់កសិករ ដូច្នេះពួកគេត្រូវខ្ចីទុនពីអ្នកចងការប្រាក់ឯកជន ក្នុងអត្រាការប្រាក់យ៉ាងខ្ពស់ប្រហែល ៥-១០%ក្នុងមួយខែ ។ សភាពការណ៍នេះបង្កបញ្ហាដល់កសិករជាច្រើន ដែលបង្ខំចិត្តលក់ដីមួយចំណែក ឬទាំងអស់ ដើម្បីបំពេញចំណាយទាំងនេះ ។ ទី២ ទោះបីធាតុចូលទំនើបបានចូលដល់តំបន់ឆ្ងាយៗហើយក៏ដោយ ក៏បន្ថែទីផ្សារផលិតផលមិនទាន់អភិវឌ្ឍន៍នៅឡើយទេ ។ ថ្លៃស្រូវ ប្រែប្រួលចុះឡើងយ៉ាងច្រើនទៅតាមរដូវកាល ។ ថ្លៃស្រូវធ្លាក់ចុះទាបខ្លាំងនៅពេលដែលកសិករ ជាពិសេសកសិករតូចតាច ត្រូវលក់ផលិតផលរបស់ខ្លួនក្រោយពេលច្រូតកាត់រួច ហើយវាឡើងខ្ពស់នៅពេលកសិករត្រូវទិញស្បៀងនៅក្នុងរដូវខ្វះខាត (Sik 2001) ។ ការដាំដុះឱ្យបាន២ដង ដែលសំដៅធានាឱ្យមានស្បៀងពេញមួយឆ្នាំសំរាប់គ្រួសារ នៅមិនទាន់មានអនុវត្តតាមកន្លែងភាគច្រើនទេ ។ ក្នុងដំណើរការនេះ ឈ្មួញកណ្តាលអាចទាញយកចំណេញបានយ៉ាងច្រើន រីឯកសិករតូចតាចក្នុងពេលខ្លះត្រូវបង្ខំលក់ដីរបស់ខ្លួនដើម្បីដោះស្រាយចំនាយក្នុងគ្រួសារ ។ ក្នុងរឿងនេះ មិនមែនមានតែចំនាយលើស្បៀងមួយមុខប៉ុណ្ណោះទេដែលត្រូវលើកឡើង ប៉ុន្តែចំនាយផ្សេងទៀតការព្យាបាលសុខភាពជាដើម ក៏ធ្វើឱ្យគ្រួសារមានចំណាយខ្ពស់ដែរ (Biddulph 2000)[៤] ។ ប្រព័ន្ធទីផ្សារដែលមិនសូវសុក្រិត និងកង្វះខាតស្ថាប័នទីផ្សារ និង/ឬ ប្រព័ន្ធគ្រប់គ្រងព្រមទាំងស្ថាប័នបន្ទាប់បន្សំផ្សេងទៀត បានធ្វើឱ្យមានការផ្ទេរកម្មសិទ្ធិដីធ្លីច្រើនខ្លាំងណាស់ ។

ការផុសឡើងនូវកំលាំងទីផ្សារ ការយល់ដឹងពីសេដ្ឋកិច្ចវិមាត្រ (economy of scale) បានជះឥទ្ធិពលជាបណ្តើរៗទៅលើទីផ្សារដីធ្លី ។ ក្បាលដីតូចៗពេក អាចដាំដុះមិនសូវចំណេញនៅក្នុងរបៀបរបបផលិតកម្មដំណាំបច្ចុប្បន្ន ។ ជាលទ្ធផល អ្នកមានដីតូចៗជាច្រើននាក់ បានលក់ដីធ្លីដើម្បីចាប់យកមុខរបរផ្សេងទៀតដែលស្រួលរកចិញ្ចឹមជីវិតជាង (So *et al* 2001) ។ ហេតុការណ៍នេះកើតមានកាន់តែច្រើន ដោយសារការពុះចែកដីនៅពេលបន្តមរតក ។ ប្រជាជនច្រើនលក់ដីផ្តាច់ជាជាងជួលឱ្យគេ ពីព្រោះការកាន់កាប់ដីមិនសូវមានសន្តិសុខ ដោយសារគ្មានកម្មសិទ្ធិផ្លូវការ និងគ្មានប្រព័ន្ធអភិបាលកិច្ចអព្យាក្រិត ។ មានភស្តុតាងថ្មីៗបង្ហាញថា ក្រុមអ្នកមានអំនាចមកពីសហគមន៍អ្នកជំនួញ សហគមន៍អន្តរជាតិ ឬអង្គភាពរដ្ឋ គឺជាអ្នកមានចំណែកធំក្នុងការចាប់យកដីដែលកាលពីមុនជាកម្មសិទ្ធរបស់សហគមន៍កសិករ[៥] ។

ដូចបានពណ៌នារួចមកហើយ ប្រព័ន្ធប្រើប្រាស់ដីធ្លីនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា មានប្រភេទជាការប្រើប្រាស់ទូលំទូលាយដោយគ្មានការប្រគល់កម្មសិទ្ធិដីធ្លីមាំទាំឱ្យប្រជាជនទេ ។ ក្នុងពេលថ្មីៗ ដោយសារវត្តមានប្រព័ន្ធទីផ្សារ កង្វះខាតការបញ្ជាក់កម្មសិទ្ធិនេះ បានបង្កើតបញ្ហាជាច្រើនដល់សុវត្ថិភាពនៃការប្រើប្រាស់ដីធ្លី ។ នៅពេលពាណិជ្ជភាវូបនីកម្មរីកធំឡើង អ្នកដែលមិនបានធ្វើសមាហរណកម្មល្អទៅក្នុងប្រព័ន្ធទីផ្សារ នឹងមានអារម្មណ៍ថាខ្វះសុវត្ថិភាពកាន់តែខ្លាំងឡើង ។ ឧទាហរណ៍ អង្កេតរបស់ WFP (Helmers and Kenefick 1999) បង្ហាញថា មានគ្រួសារដល់ទៅ៣% បានរាយការណ៍ ពីការបាត់បង់ដីធ្លីដោយសារមានអ្នកដទៃរំលោភយក ។ អនក្ខរកម្ម ក៏មានតួនាទីមួយដែរ ។ អង្កេត SES 1997 បានបង្ហាញថា អ្នកឆ្លើយសំភាសន៍ភាគច្រើនមិនស្គាល់ពីក្រដាសស្នាមត្រឹមត្រូវឡើយ ។ រឿងនេះនាំឱ្យមានអសន្តិសុខនៃការប្រើប្រាស់ដីធ្លី ។

បទពិសោធន៍បង្ហាញថា "សុវត្ថិភាពនៃការប្រើប្រាស់ដីធ្លី មានសារៈសំខាន់ណាស់ បើសិនកសិករត្រូវធ្វើវិនិយោគនៅក្នុង

---

[៤] ខុសពីសង្គមកសិករដទៃទៀតដែលនៅតែមានថ្នាំបុរាណនៅឡើយ ប្រព័ន្ធថ្នាំបុរាណនៅកម្ពុជាមិនបានអភិវឌ្ឍគ្រប់គ្រាន់ទេ ។ ថ្នាំពេទ្យសម័យបានចូលមកនៅពេលប្រព័ន្ធទីផ្សារបានកើតឡើង ក៏ប៉ុន្តែមានតំលៃខ្ពស់ពេកសំរាប់អ្នកក្រីក្រ ។

[៥] ចំណុចនេះត្រឹមតែបានមកពីស្រាវជ្រាវទេ (ដូចជា Kato 1999; Williams 1999; So *et al* 2001) ប៉ុន្តែមានក្នុងកាសែតមួយចំនួនដែរ ។

របៀបរបបធ្វើកសិកម្មមានចីរភាព ។ កសិករនៅកម្ពុជា គ្មានប្លង់ដីស្របច្បាប់សំរាប់ដីដែលពួកគេប្រើប្រាស់ទេ ហើយរឿងនេះបណ្តាលឱ្យមានជំលោះដីធ្លី និងបង្កើតនូវបរិស្ថានអស្ថិរភាពមួយរារាំងការងារលើកកំពស់គុណភាពដីធ្លី” (RGC 1998) ។ ឃ្លានេះបានដកស្រង់ចេញពីឯកសាររបស់រដ្ឋាភិបាលផ្ទាល់ ដែលទទួលស្គាល់នូវផលវិបាកនៃអសន្តិសុខក្នុងការកាន់កាប់ដីធ្លី ។

ក្នុងរឿងនេះ មិនមែនមានតែម្ចាស់ដី និងកសិករទេដែលត្រូវខាតបង់ ប៉ុន្តែរដ្ឋក៏ខាតបង់ដែរ ពីព្រោះគ្មានការបង់ពន្ធលើការទិញ-លក់ដីក្រៅផ្លូវការ ។ ម្យ៉ាងវិញទៀត ភាពស្របច្បាប់នៃប្រព័ន្ធក៏ត្រូវប៉ះពាល់ បើសិនគ្មានសកម្មភាពអ្វីដោះស្រាយ ។

កត្តាមួយទៀត គឺសម្ពាធនៃកំណើនប្រជាជន ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗ ប្រជាជនកើនជាង ២,៥%ក្នុងមួយឆ្នាំ ប៉ុន្តែដីធ្លីមិនបានកើនឡើងគួរឱ្យកត់សំគាល់ទេ ការងារក្រៅពីវិស័យបឋមក៏មិនបានកើនឡើងច្រើនដែរ (Godfrey et al 2001), ឯកំរិតធនធានមនុស្សនៅតែទាបនៅឡើយ ។ ទិន្នន័យផ្លូវការបង្ហាញថា ប្រជាជនបានកើនជាង២ដង ក្នុង២ទសវត្សរ៍ចុងក្រោយនេះ ។ ពីឆ្នាំ១៩៩0-៩៩ ប្រជាជនកើនឡើងជិត ៣0% (Williams 1999) ។ កំណើនប្រជាជន/កំលាំងពលកម្មខ្ពស់បែបនេះ គួបនឹងការគ្មានកំណើនការងារផ្សេងៗក្រៅពីកសិកម្ម និងការគ្មានទំនើបភាវូបនីយកម្មកសិកម្មដែលប្រើប្រាស់ពលកម្មច្រើន នឹងធ្វើឱ្យដីធ្លីត្រូវពុះច្រៀកតូចៗអស់ ហើយប្រជាជនមួយចំនួនធំនឹងចូលទៅក្នុងកំលាំងពលកម្មក្នុងលក្ខណៈជាអ្នកគ្មានដី ។ ការសិក្សាពីដីធ្លីរបស់អង្គការ Oxfarm បង្ហាញថា ក្នុងចំណោមគ្រួសារថ្មីៗដែលកកើតឡើងក្នុងរយៈពេល១៥ឆ្នាំមុនឆ្នាំ១៩៩៩ ប្រហែលពាក់កណ្តាលជាអ្នកគ្មានដីតាំងពីដំបូងម្ល៉េះ ពីព្រោះគ្មានដីសំរាប់ចែកចាយបន្តទៅឱ្យពួកគេ ។

ចំពោះដីលំនៅដ្ឋាន ស្ថានភាពមិនសូវខុសគ្នាប៉ុន្មានទេ ។ តាំងពីដើមរៀងមក ប្រជាជនតែងសង់ផ្ទះនៅលើដីដែលពួកគេកាប់ឆ្ការ ប៉ុន្តែពុំសូវមានឯកសារច្រើនទេដែលនិយាយអំពីការទទួលបាន និងការគ្រប់គ្រងដីលំនៅដ្ឋាន ។ ក្នុងឆ្នាំ១៩៨៩ ដីលំនៅដ្ឋាន ត្រូវបានបែងចែកទៅតាមទំហំដីដែលមាន និងតាមទំហំគ្រួសារ ក៏ប៉ុន្តែដីឡូតិ៍នីមួយៗមិនលើសពី ២ហិកតាឡើយ ។ ប៉ុន្តែរដ្ឋអំណាចភូមិកាន់តែមានការរារែកច្រើនហើយក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ដីថ្មីៗ ។ ទន្ទឹមគ្នានេះ ចំនួនគ្រួសារថ្មីបានកើនឡើង ទីផ្សារដីលំនៅដ្ឋានក្នុងមូលដ្ឋានបានលូតលាស់ ការពុះចែកដីឡូតិ៍ដែលមានស្រាប់បានកើតឡើង ហើយដីសល់ទំនេរដោយសារប្រជាជនផ្លាស់ទីលំនៅក៏បានប្តូរទៅជាកម្មសិទ្ធិទៅអ្នកផ្សេង ។ ទោះបីភាពគ្មានដីលំនៅដ្ឋានមានកំរិតទាប ប៉ុន្តែវិសមភាពក្នុងរបាយកម្មសិទ្ធិដីលំនៅដ្ឋានមានកំរិតខ្ពស់ (Chan et al 2001) ។ ក្នុងតំបន់ទីក្រុង វិសមភាពកម្មសិទ្ធិដីធ្លី និងភាពគ្មានដី គឺមានកំរិតកាន់តែខ្ពស់ ។ តំរូវការដីធ្លីពីគ្រប់មជ្ឈដ្ឋាន រួមទាំងកំណើនប្រជាជន និងកំណើននៃការហូរចូលប្រជាជនពីជនបទ គឺជាមូលហេតុចំបងៗជាងគេ[៦] ។

សរុបសេចក្តីមក ការបែងចែកដីធ្លីក្នុងឆ្នាំ១៩៨៩ គឺជាការទទួលស្គាល់នូវលំនាំនៃការគ្រប់គ្រង និងប្រើប្រាស់ដីក្នុងពេលនោះ ហើយគេមិនបានរៀបចំវា ដើម្បីសំរបសំរួលតាមការប្រែប្រួលដ៏ឆាប់រហ័សនៅក្នុងរបៀបរបបប្រើប្រាស់ដី ឬការបើកចំហទីផ្សារ ឬសំរាប់ដោះស្រាយកំណើនប្រជាជនដ៏លឿននោះឡើយ ។ បញ្ហាវាកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារកង្វះបទប្បញ្ញត្តិសំរាប់គ្រប់គ្រងទីផ្សារ កង្វះពត៌មានច្បាស់លាស់ និងកង្វះរដ្ឋបាលមួយដែលមានអព្យាក្រិតភាពគ្រប់គ្រាន់ ។ ដូច្នេះអ្វីដែលបានកើតឡើងជាបន្តមកទៀត អាជ្ញាធរមិនបានប្រមើលឃើញជាមុនទេ ។ ប៉ុន្តែបើសិនបានធ្វើការស្រាវជ្រាវជ្រៅជ្រះជាប់រហូតមកយ៉ាងហោចណាស់ក៏គេអាចទាយទុកមុនបានខ្លះនូវអ្វីដែលបានកើតឡើងក្នុងពេលកន្លងមក ។ ជាការពិតហើយ នៅក្នុងរយៈពេលពីដំបូងៗ ការសិក្សាស្រាវជ្រាវមានតិចតួចណាស់ ដូច្នេះហើយទីផ្សារបានផុសឡើងដោយគ្មានការគ្រប់គ្រង គ្មានការសង្កេតតាមដាន និងគ្មានការត្រួតពិនិត្យ[៧] ។

---

[៦] សូម្បីនៅជនបទ ក៏គេឧស្សាហ៍ឃើញមាន ២ ឬ ៣គ្រួសាររស់នៅជាមួយគ្នាក្នុងផ្ទះតូចមួយ ។ ប៉ុន្តែមកទល់សព្វថ្ងៃមិនទាន់មានទិន្នន័យអង្កេតណាមួយដែលបង្ហាញពីទិដ្ឋភាពនេះទេ ។

[៧] គួរកត់សំគាល់ថា នៅក្នុង អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៣ គ្មានសំនួរទាក់ទងនឹងដីធ្លីឡើយ ។

## ជំពូក ៣

# និន្នាការនៃការលក់ដូរដីធ្លី

ឈរលើមូលដ្ឋាននៃការពិភាក្សាខាងលើស្តីអំពីទីផ្សារដីធ្លី គេអាចចោទជាសំណួរមួយចំនួនដូចខាងក្រោម មុននឹងធ្វើការពិចារណាអំពីទិន្នន័យដែលបានមកពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រៈ

ក. តើការផ្ទេរដីធ្លី ទាំងដីកសិកម្ម និងដីលំនៅដ្ឋាន មាននិន្នាការដូចម្តេច?

ខ. ក្នុងការផ្ទេរដីធ្លី តើមានលក្ខណៈអ្វីខ្លះដែលពិសេសៗទៅតាមតំបន់ ឬខេត្ត ?

គ. តើការផ្ទេរដីរវាងអ្នកលក់ និងអ្នកទិញដែលមានលំនៅដ្ឋានក្នុងខេត្ត និងស្រុកដូចគ្នា មានកំរិតប៉ុណ្ណា ហើយរវាងអ្នកនៅក្នុងខេត្តផ្សេងពីគ្នាមានកំរិតប៉ុណ្ណា?

ឃ. ក្នុងការផ្ទេរដីធ្លី តើមានចំណុចអ្វីជាក់លាក់គួរកត់សំគាល់ឬទេរវាងជនបទ-ទីក្រុង? និយាយឱ្យច្បាស់ជាងនេះទៀត តើដីធ្លីត្រូវបានផ្ទេរពីអ្នករស់នៅជនបទ មកក្នុងដៃអ្នករស់នៅទីក្រុងឬយ៉ាងណា?

ង. ទាក់ទិននឹងដីដែលគេផ្ទេរចុះឡើង តើមានលក្ខណៈអ្វីពិសេសទេក្នុងរឿងទំហំ?

ច. តើដីដែលត្រូវបានផ្ទេរក្នុងកន្លែងខុសៗគ្នា វាមានថ្លៃយ៉ាងដូចម្តេចខ្លះ? តើមានចំណងទាក់ទងអ្វីជាពិសេសទេរវាងទំហំដី និងថ្លៃដី? ប្រសិនបើមាន តើមកពីហេតុអ្វី?

សំនួរទាំងនេះនឹងត្រូវលើកមកស្រាយបំភ្លឺនៅក្នុងផ្នែកជាបន្តបន្ទាប់ ប៉ុន្តែអាចបានតែមួយកំរិតទេ ពីព្រោះខ្វះទិន្នន័យ ។

## ៣.១ វិធីសាស្ត្រនៃការវិភាគទិន្នន័យ

ការស្រាវជ្រាវក្នុងផ្នែកនេះត្រូវផ្អែកតាមលទ្ធភាពខាងទិន្នន័យ គឺបានន័យថា ទិន្នន័យដែលមានស្រាប់នៅក្នុងឯកសារផ្ទេរកម្មសិទ្ធិ វាកំណត់ចេញនូវបែបបទ និងកំរិតព្រំដែននៃការស្រាវជ្រាវ ដូច្នេះគេត្រូវតែលើកពីវិធីសាស្ត្រយកមកបង្ហាញមុន ។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដែលបច្ចុប្បន្ននៅក្រោមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) រក្សាទុកនូវឯកសារនៃការផ្ទេរកម្មសិទ្ធិដីគ្រប់ប្រភេទនៅកម្ពុជា ។ គិតមកដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០១ អគ្គនាយកដ្ឋានមានសរុប ១៥.៧៩៦ឯកសារ ដែលទាក់ទិននឹង ដីលំនៅដ្ឋាន និងដីកសិកម្ម ទាំងក្នុងជនបទ និងទីក្រុង ។ ឯកសារនៃការទិញ-លក់ទាំងនេះ ស្ថិតនៅក្នុងឆ្នាំ១៩៩៥ ដល់ ២០០១ ។

នៅក្នុងឯកសារផ្ទេរ មានពត៌មានលំអិតដូចជា ទំហំដី ថ្លៃដីដែលគេព្រមព្រៀងលក់ អាសយដ្ឋានដី អាសយដ្ឋានអ្នកទិញ និងអាសយដ្ឋានអ្នកលក់ ។ ពត៌មានលំអិតផ្សេងទៀតអំពីដីធ្លី ដែលជាធម្មតាមានចុះនៅក្នុងប័ណ្ណកាន់កាប់ដី ពុំមានចុះជាថ្មីនៅក្នុង

លិខិតផ្ទេរកម្មសិទ្ធិទេ ។ ពត៌មានសំខាន់ៗដែលមិនចុះកត់ត្រាក្នុងលិខិតផ្ទេរកម្មសិទ្ធិមានជាអាទិ តើមានសំណង់នៅលើដីឡូត៍ឬទេ តើដីស្ថិតនៅកន្លែងមានអំណោយផលល្អឬទេ (ឧ. នៅជាប់ផ្លូវធំ ឬនៅតាមដងទន្លេ) ។ កង្វះខាតទិន្នន័យទាំងនេះធ្វើឱ្យការវិភាគមានកំរិត ។ ពិតហើយ ពត៌មានលំអិតដូចជា ប្រវត្តិសេដ្ឋកិច្ច-សង្គមកិច្ច របស់អ្នកទិញ និងអ្នកលក់ គឺមានប្រយោជន៍ជាខ្លាំង ប៉ុន្តែគេមិនគួររំពឹងទេថា ពត៌មានទាំងនេះនឹងមានចុះនៅក្នុងឯកសារលក់ផ្តាច់តាមផ្លូវច្បាប់ នោះឡើយ ។ គំរូនៃទំព័រពត៌មានដែលផ្តល់ទិន្នន័យ មានចុះនៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ ។

**តារាង៣.១. ដំណើរការចុះបញ្ជីដីធ្លី (ពីឆ្នាំ១៩៨៩ ដល់ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០០០)**

| ខេត្ត/ក្រុង | ចំនួនប័ណ្ណប្លង់ដីដែលបានផ្តល់រួចហើយ | | | | របាយចំនួនគ្រួសារ គិតតាមខេត្ត * |
|---|---|---|---|---|---|
| | A 1989 –1995 | B 1995 – 2000 | សរុប (A+B) 1989 – 2000 | របាយតាមខេត្ត គិតជា % | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 186,584 | 38,304 | 224,888 | 43.39% | 45.63% |
| ភ្នំពេញ | 1,028 | 4,621 | 5,649 | 1.09% | 7.95% |
| កណ្តាល | 109,749 | 9,675 | 119,424 | 23.04% | 9.44% |
| សៀមរាប | 28,098 | 5,041 | 33,139 | 6.39% | 5.83% |
| ព្រះសីហនុ | 11,659 | 5,779 | 17,438 | 3.36% | 1.28% |
| បាត់ដំបង | 19,432 | 6,683 | 26,115 | 5.04% | 6.80% |
| កំពង់ចាម | 16,618 | 6,505 | 23,123 | 4.46% | 14.33% |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 261,693 | 32,053 | 293,746 | 56.68% | 54.37% |
| បន្ទាយមានជ័យ | 13,641 | 3,745 | 17,386 | 3.35% | 5.12% |
| កំពង់ឆ្នាំង | 25,981 | 3,291 | 29,272 | 5.65% | 3.79% |
| កំពង់ស្ពឺ | 22,469 | 4,204 | 26,673 | 5.15% | 5.30% |
| កំពង់ធំ | 4,973 | 2,152 | 7,125 | 1.37% | 4.90% |
| កំពត | 54,462 | 1,668 | 56,130 | 10.83% | 5.04% |
| កែប | 570 | 783 | 1,353 | 0.26% | 0.25% |
| កោះកុង | 6,490 | 2,756 | 9,246 | 1.78% | 1.14% |
| ក្រចេះ | 3,064 | 1,261 | 4,325 | 0.83% | 2.26% |
| មណ្ឌលគិរី | 0 | 0 | 0 | 0.00% | 0.26% |
| ឧត្តរមានជ័យ | 0 | 95 | 95 | 0.02% | 0.98% |
| ប៉ៃលិន | 0 | 31 | 31 | 0.01% | 0.19% |
| ព្រះវិហារ | 0 | 104 | 104 | 0.02% | 0.10% |
| ព្រៃវែង | 36,884 | 2,061 | 38,945 | 7.51% | 8.89% |
| ពោធិ៍សាត់ | 10,857 | 4,140 | 14,997 | 2.89% | 3.13% |
| រតនគិរី | 436 | 1,056 | 1,492 | 0.29% | 0.77% |
| ស្ទឹងត្រែង | 0 | 128 | 128 | 0.02% | 0.66% |
| ស្វាយរៀង | 38,530 | 1,808 | 40,338 | 7.78% | 4.50% |
| តាកែវ | 43,336 | 2,770 | 46,106 | 8.90% | 7.10% |
| សរុប | 448,277 | 70,357 | 518,258 | 100.00% | 100.00% |

*សំគាល់ : ទិន្នន័យទាំងនេះ គឺបានមកពីការចុះបញ្ជីតាមប្រព័ន្ធ sporadic and systematic ។ ប្រភព: MLMUPC and * Census 1998*

ចំណុចខ្វះខាតកាន់តែធ្ងន់ធ្ងរនៃទិន្នន័យទាំងនេះ គឺបញ្ហាថា ក្នុងចំណោមដី ៤,៥លានក្បាលដែលបានផ្តល់បង្កាន់ដៃហើយ (សំរាប់ដីលំនៅដ្ឋាន និងដីផលិតកម្ម) មានតែ ៥១៨.០០០ក្បាលដី ឬជាង ១០% បន្តិចប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជី (តារាង៣.១) ។ ការនេះមានន័យថា ចំនួនការលក់ផ្តាច់ដែលបានចុះបញ្ជីជាផ្លូវការ មានតែនៅក្នុងចំណោមដី ៥១៨.០០០ ប្លង់ប៉ុណ្ណោះ ។ ដោយសារមានក្បាលដីជិត ៩០%ទៀត ស្ថិតនៅក្នុងការកាន់កាប់ក្រៅផ្លូវការ ដូច្នេះការទិញ-លក់ដីទាំងនេះ មិនត្រូវបានបូកបញ្ចូលក្នុងតួលេខខាងលើទេ[១] ។ លើសពីនេះទៀត ដីប្រហែលជាង ១០% ដែលបានចុះបញ្ជីហើយ មិននៅរាយស្មើគ្នាក្នុងទូទាំងប្រទេសឡើយ ។ តារាង៣.១ បង្ហាញថា ចំពោះដីបានចុះបញ្ជីហើយ ភាគច្រើនស្ថិតនៅ ក្នុងខេត្តដែលនៅជាប់រាជធានី ក្នុងតំបន់

[១] ជាការជាក់ស្តែងហើយ ដីដែលមិនបានចុះបញ្ជីជាផ្លូវការ មិនអាចផ្ទេរជាផ្លូវការបានទេ ។

ទំនាបទន្លេសាប និងក្នុងតំបន់ទីក្រុងដទៃទៀត[២] ។ នៅក្នុងទសវត្សរ៍កន្លងមក ការចុះបញ្ជីដីភាគច្រើនទំនងបានធ្វើនៅក្នុងតំបន់ដែលគ្មានបញ្ហាច្រើនដូចជា ការទាមទារកម្មសិទ្ធិជាន់គ្នា ការវាស់វែង និងការងាររដ្ឋបាលផ្សេងៗ ។ បើសំណុំគំរូតាងមានទំហំតូចធៀបនឹងផ្ទៃប្រទេស ហើយមានរបាយមិនស្មើល្អនោះ ទិន្នន័យទិញ-លក់ដីធ្លីមុខតែមានលំអៀងស្រដៀងគ្នានឹងការចុះបញ្ជីដីធ្លីដែរ ។ លើសពីនេះទៀត ការទិញលក់ដីជាផ្លូវការភាគច្រើនកើតមាននៅតំបន់ដែលមានពាណិជ្ជកម្មច្រើន ដូច្នេះវាបង្កើតលំអៀងបន្ថែមទៀតនៅក្នុងគំរូតាងនេះ ។ ចំនុចចុងក្រោយ គឺជាទូទៅប្រជាជនសុំចុះបញ្ជីដីរបស់ខ្លួន និងធ្វើការផ្ទេរតាមផ្លូវការត្រឹមត្រូវលុះណាតែពួកគេមានបំណងវិនិយោគ ឬសាងសង់នៅលើដីនោះ ។ មានដីជាច្រើនកន្លែង ទាំងដីកសិកម្ម ទាំងដីលំនៅដ្ឋាន ត្រូវបានលក់ដូរក្រៅផ្លូវការ ដោយគ្មានការទទួលស្គាល់ជាផ្លូវការ និងគ្មានក្រដាសស្នាមត្រឹមត្រូវ ដោយសារវាទាក់ទិននឹង ការលក់ដីដើម្បីដោះទ័ល (ដូចជា ការសងបំណុល, ជំងឺ) ការប្រមូលផ្តុំដីធ្លី ចំណាកស្រុក (migration) ឬការដូរមុខរបរ ។ ការផ្ទេរទាំងនេះមិនត្រូវបានកត់បញ្ចូលនៅក្នុងកំរងទិន្នន័យទេ ។ នៅក្នុងការវិភាគតទៅនេះ គេគួរចងចាំពីចំណុចខ្វះខាតទាំងនេះជានិច្ច ។

## ៣.២. ការទិញលក់ដីលំនៅដ្ឋាន

### *៣.២.១. កំរិតនៃការទិញលក់ដី*

ពីឆ្នាំ១៩៩៥-២០០០ មានការទិញលក់ដីលំនៅដ្ឋានប្រហែល ៩.០០០ប្លង់ ត្រូវជា ១.៤០០ហិកតា[៣] ឬ ០,៤៥%នៃផ្ទៃដីលំនៅដ្ឋានសរុបនៅក្នុងប្រទេស[៤] ដូច្នេះអត្រាទិញលក់ដីជាមធ្យមក្នុងមួយឆ្នាំមានមិនដល់ ០,១%ផង ។ ជាការពិតណាស់ ការលក់ជាផ្លូវការមានកំរិតតិចតួចណាស់ បើធៀបនឹងចំនួនដីលំនៅដ្ឋានសរុប ហើយវាជាហេតុផលដែលធ្វើឱ្យគេយល់ឃើញថា និន្នាការនៃការលក់ដីក្នុងគំរូតាងនេះ មិនអាចតំនាងឱ្យការពិតនៅទូទាំងប្រទេសទេ ។

### *៣.២.២. ការលក់ដីគិតតាមឆ្នាំ*

ជាទូទៅ ទីផ្សារដីលំនៅដ្ឋានបានកើនសកម្មភាពខ្លាំងនៅឆ្នាំ១៩៩៥-៩៦ ស្របតាមសន្ទុះសេដ្ឋកិច្ច ក៏ប៉ុន្តែបានធ្លាក់ចុះវិញនៅឆ្នាំ២០០០ ។ ពីឆ្នាំ១៩៩៥ ដល់ ២០០០ ក្នុងមួយឆ្នាំៗមានដីលំនៅដ្ឋានប្រហែល ១.៥០០ឡូត៍ ត្រូវជា ៣០០ហិកតា បានផ្លាស់ប្តូរម្ចាស់ (តារាង៣.១ក និង ៣.១ខ) ។ និន្នាការនេះត្រូវបានបញ្ជាក់គាំទ្រ ដោយអ្នកឆ្លើយសម្ភាសន៍នៅក្នុងអង្កេតទ្រង់ទ្រាយតូចមួយរបស់ CDRI ដូចមានបង្ហាញជូននៅក្នុងផ្នែកបន្ទាប់ ។ យោងតាមសំភាសន៍ទាំងនេះ ជាទូទៅការលក់ដីកើនឡើងខ្ពស់បំផុតនៅឆ្នាំ១៩៩៦ បន្ទាប់ពីមានវិនិយោគបរទេសជាច្រើនបានហូរចូល ជាពិសេសនៅក្នុងវិស័យកាត់ដេរ ដែលបង្កើតបានជាតំរូវការផ្ទាល់ និងដោយប្រយោល យ៉ាងច្រើននៅក្នុងទីផ្សារដីធ្លី ។

មុននឹងសន្និដ្ឋានពីនិន្នាការនៃបរិមាណទិញលក់ដីធ្លី គេគួរកត់សំគាល់ថា ពីឆ្នាំ១៩៩០-៩៥ នាយកដ្ឋានសុរិយោដី ស្ថិតនៅក្រោមក្រសួងកសិកម្ម ។ បន្ទាប់មកក្នុងឆ្នាំ១៩៩៩៥-៩៨ នាយកដ្ឋាននេះត្រូវបានដាក់ឱ្យនៅក្រោម ទីស្តីគណៈរដ្ឋមន្ត្រី ។ ហើយចាប់ពី ឆ្នាំ១៩៩៨ មក គឺស្ថិតនៅក្រោមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ ការផ្លាស់ប្តូរញឹកញាប់បែបនេះមានន័យថា មានការណែនាំខុសៗគ្នាចំពោះមន្ត្រីថ្នាក់ក្រោម ស្តីពីអាទិភាពនៃការងារសុរិយោដី ការកំរិតថ្លៃក្នុងការចុះបញ្ជីនិងការផ្ទេរកម្មសិទ្ធិដីធ្លី ។ ប្រភពច្បាស់ការមួយចំនួនបានលើកថា កាលនៅចុងទសវត្សរ៍១៩៩០ ការងារសុរិយោដីមិនត្រូវបានគេផ្តល់សារៈសំខាន់ឱ្យច្រើនទេ ហើយថ្លៃចុះបញ្ជី និងផ្ទេរដី ក៏មានកំរិតខ្ពស់ដែរ ។

---

[២] ភ្នំពេញ ដែលជាទីប្រជុំជនធំជាងគេ គ្មានទិន្នន័យច្រើននៅទីនេះទេ ពីព្រោះផ្នែកសុរិយោដីរបស់ក្រុងភ្នំពេញ ត្រូវបានផ្តាច់ចេញពី អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រជាយូរមកហើយ ។ ឯកសារដីធ្លីនៅភ្នំពេញ ត្រូវបានរក្សាទុកដោយឡែកនៅឯសាលាក្រុង ។

[៣] ដីមួយចំនួនអាចត្រូវបានលក់លើសពីមួយដង ដូច្នេះចំនួនផ្ទៃដីនេះ អាចលើសពីទំហំផ្ទៃដីមែនទែន ។

[៤] ចំនួនដីឡូត៍លំនៅដ្ឋានសរុប បានមកពី អង្កេតSES 1999 ។

ដូចបានលើកខាងលើ ការលក់ដីកើនខ្ពស់បំផុតនៅឆ្នាំ១៩៩៦ ដែលជាឆ្នាំប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់បំផុត ។ កំណើនដល់កំពូល ដែលស្របគ្នានឹងលទ្ធផលសេដ្ឋកិច្ច គឺទំនងជាទីផ្សារផ្សេងៗវាមានដំណើរការទៅមុខជាមួយគ្នា ។

### *៣.២.៣. ការលក់ដីគិតតាមតំបន់*

ដោយទីផ្សារដីធ្លី មានចំណងទាក់ទងជិតស្និតទៅនឹងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃតំបន់និមួយៗ យើងបានបែងចែកទិន្នន័យជាពីរផ្នែកធំៗទៅតាមតំបន់ភូមិសាស្ត្រ ។ ដោយពុំមានលក្ខណៈវិនិច្ឆ័យវិទ្យាសាស្ត្រឱ្យបានគ្រប់គ្រាន់ ការបែងចែកនេះត្រូវបានធ្វើឡើងតាមបែប heuristic (ការកំនត់ហើយកែតំរូវជាក្រោយ) ។ ចំណាត់ថ្នាក់ទាំងពីរនេះគឺ ១) ខេត្តមានទីក្រុងឬទីប្រជុំជនធំ ដែលជាទូទៅមានដង់ស៊ីតេប្រជាជនខ្ពស់ និងមានសកម្មភាពសេដ្ឋកិច្ចមមាញឹក និង ២) ខេត្តមានទីក្រុងឬទីប្រជុំជនតូច និងមិនសូវមានការអភិវឌ្ឍន៍ ។ ឯកសារផ្ទេរដីនៅក្នុង តារាង៣.២.ក និង៣.២.ខ បង្ហាញថា ៦២%នៃប្រតិបត្តិការលក់ដីលំនៅដ្ឋាន ដែលតំណាងឱ្យ ៣/៤ នៃផ្ទៃដីលំនៅដ្ឋានសរុបដែលបានលក់ គឺស្ថិតនៅក្នុងខេត្តទាំងប្រាំដែលមានទីក្រុងធំៈ កណ្ដាល សៀមរាប ក្រុងព្រះសីហនុ បាត់ដំបង និងកំពង់ចាម ។ ខេត្តកណ្ដាលតែមួយ មានចំនែក ៣៤% នៃចំនួនប្រតិបត្តិការលក់ដី និងផ្ទៃដីដែលគេបានលក់ផ្ដាច់[៥] ។ ភាគរយខ្ពស់ជាងនៃការលក់ដីជាផ្លូវការក្នុងខេត្តមានទីប្រជុំជនធំៗ អាចមិនមែនមកពីខេត្តទាំងនេះទទួលបានប័ណ្ណប្លង់ដីច្រើនជាងគេនោះទេ (ទោះបីកត្តានេះមានសារៈសំខាន់ក៏ដោយ) ។ តាមពិត ខេត្តមានទីប្រជុំជនតូចមួយចំនួន បានទទួលប័ណ្ណប្លង់ដី ច្រើនជាងខេត្តមានទីប្រជុំជនធំទៅទៀត (តារាង៣.១) ។ ប៉ុន្តែគេមិនអាចធ្វើសេចក្ដីសន្និដ្ឋានណាមួយបានទេពីព្រោះគ្មានការរាប់ចំនួនដីឡូត៍នៅក្នុងតំបន់ ឬខេត្តនីមួយៗ ដើម្បីផ្ទៀងផ្ទាត់នឹងភាគរយនៃដីឡូត៍ដែលបានលក់ក្នុងតំបន់នីមួយៗ ។

### *៣.២.៤. ការបែងចែកតាមទីក្រុង និងជនបទ*

ការទិញលក់ដីលំនៅដ្ឋាន បង្ហាញនូវរូបភាពគួរឱ្យចាប់អារម្មណ៍មួយនៅពេលធ្វើការបែងចែកទៅតាមតំបន់ទីក្រុង និងជនបទ ។ ជារួម ការលក់ដីជាផ្លូវការនៅក្នុងតំបន់ទីក្រុង (ចំនួន ៥.០៨៧ឡូត៍) មានចំនួនច្រើនជាងនៅតំបន់ជនបទ (៣.៨៣៨ ឡូត៍) បើគិតក្នុងខេត្តទាំងធំទាំងតូច (តារាង៣.៣.ក)[៦] ។ ប៉ុន្តែនៅខេត្តកណ្ដាល កំពង់ចាម ព្រៃវែង និងបន្ទាយមានជ័យ ការលក់ដីក្នុងតំបន់ជនបទ មានចំនួនច្រើនជាងនៅតំបន់ទីក្រុងទៅវិញ ហើយមូលហេតុមួយនៃរូបភាពលាយឡំគ្នានេះ គឺអាចបណ្ដាលមកពីរបៀបធ្វើចំណាត់ថ្នាក់ទីក្រុង និងជនបទ ។

លក្ខណៈវិនិច្ឆ័យក្នុងការកំណត់តំបន់ជនបទ និងតំបន់ទីក្រុងក្នុងជំរឿនឆ្នាំ១៩៩៨ (ឬអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ១៩៩៩) មានលក្ខណៈមិនច្បាស់លាស់ទេ ។ ស្រុកដែលមានទីរួមខេត្តតាំងនៅ ត្រូវបានរាប់ថាជាតំបន់ទីក្រុង រីឯស្រុកផ្សេងៗទៀតត្រូវបានចាត់ជាតំបន់ជនបទ។ តាមការពិត ឃុំជាច្រើននៅក្នុងស្រុកដែលគេហៅថាតំបន់ទីក្រុង គឺគ្មានលក្ខណៈគ្រប់គ្រាន់សមជាទីក្រុងទេ បើសិនគេគិតដល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ (utilities) ។ម្យ៉ាងវិញទៀត នៅក្នុងខេត្តមួយចំនួនមានទីរួមស្រុកធំៗ ដែលមានលក្ខណៈជាតំបន់ទីក្រុង ប៉ុន្តែត្រូវបានចាត់ទុកជាតំបន់ជនបទ ពីព្រោះមិនមែនជាទីរួមខេត្តៈ ឧ. នៅខេត្តកណ្ដាល មានតែស្រុកតាខ្មៅមួយគត់ដែលត្រូវបានចាត់ទុកជាតំបន់ទីក្រុង រីឯស្រុកកៀនស្វាយ និងស្រុកមួយចំនួនទៀតដែលមានលក្ខណៈជាទីក្រុងនៅជុំវិញភ្នំពេញ ត្រូវបានចាត់ទុកជាតំបន់ជនបទ ។ ហេតុនេះហើយបានជា ៨០%នៃដីលំនៅដ្ឋានដែលគេបានលក់ជាផ្លូវការនៅក្នុងខេត្តកណ្ដាល បានធ្លាក់ចូលទៅក្នុងចំណាត់ថ្នាក់តំបន់ជនបទ ។ នៅខេត្តកំពង់ចាម ព្រៃវែង និងបន្ទាយមានជ័យ ក៏មានរឿងប្រហាក់ប្រហែលគ្នានេះដែរ ។

---

[៥] បើសិនគិតបញ្ចូលទាំងទិន្នន័យនៅភ្នំពេញផង ក៏រិតភាគរយវាកាន់តែធំថែមទៀត ។ ចំណែកឯទិន្នន័យសំរាប់ខេត្តកណ្ដាលក្រោយឆ្នាំ២០០០ ក៏គ្មាននៅក្នុងនេះដែរ ពីព្រោះខេត្តនេះបានទទួលស្វ័យភាពក្នុងការចេញប្លង់ដី និងរក្សាទុកឯកសារដោយខ្លួនឯង ចាប់ពីឆ្នាំ២០០១ មក ។

[៦] តួលេខគិតជាផ្ទៃក្រឡាមានបង្ហាញនៅក្នុងតារាង៣.៣.ខ ។

## តារាង៣.២.ក. ចំនួនដីលំនៅដ្ឋានដែលបានលក់ តាមខេត្ត-ក្រុង ពីឆ្នាំ១៩៩៥ ដល់ ២០០១

| ទីតាំងដីដែលបានលក់ | ចំនួននៃប្រតិបត្តិការលក់ដី | | | | | | | សរុប (១៩៩៥-២០០១) | |
|---|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001* | ចំនួន | % |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 1,178 | 1,338 | 859 | 760 | 833 | 492 | 78 | 5,538 | 62% |
| ភ្នំពេញ** | | | | | | | | | |
| កណ្តាល | 853 | 869 | 478 | 429 | 376 | 30 | .. | 3,035 | 34% |
| សៀមរាប | 185 | 259 | 189 | 161 | 236 | 244 | 42 | 1,316 | 15% |
| ព្រះសីហនុ | 54 | 68 | 34 | 41 | 57 | 77 | 9 | 340 | 4% |
| បាត់ដំបង | 59 | 63 | 87 | 74 | 89 | 58 | 14 | 444 | 5% |
| កំពង់ចាម | 27 | 79 | 71 | 55 | 75 | 83 | 13 | 403 | 5% |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 278 | 533 | 624 | 560 | 580 | 570 | 232 | 3,377 | 38% |
| បន្ទាយមានជ័យ | 33 | 86 | 134 | 118 | 104 | 167 | 38 | 680 | 8% |
| កំពង់ឆ្នាំង | 40 | 77 | 67 | 45 | 42 | 44 | 6 | 321 | 4% |
| កំពង់ស្ពឺ | 36 | 43 | 26 | 37 | 52 | 23 | 3 | 220 | 2% |
| កំពង់ធំ | 7 | 66 | 67 | 46 | 61 | 52 | 25 | 324 | 4% |
| កំពត | 31 | 66 | 59 | 77 | 56 | 55 | 35 | 379 | 4% |
| ក្រុងកែប | 1 | 22 | 32 | 23 | 20 | 10 | 6 | 114 | 1% |
| កោះកុង | 59 | 26 | 24 | 10 | 9 | 7 | 3 | 138 | 2% |
| ក្រចេះ | 24 | 26 | 28 | 36 | 49 | 37 | 32 | 232 | 3% |
| ព្រៃវែង | 10 | 10 | 20 | 25 | 12 | 15 | 3 | 95 | 1% |
| ពោធិសាត់ | 1 | 7 | 10 | 4 | 10 | 4 | 3 | 39 | 0% |
| រតនគិរី | .. | .. | 4 | 13 | 7 | 11 | 9 | 44 | 0% |
| ស្វាយរៀង | 36 | 36 | 69 | 38 | 70 | 65 | 39 | 353 | 4% |
| តាកែវ | .. | 68 | 84 | 88 | 88 | 80 | 30 | 438 | 5% |
| **សរុប** | 1,456 | 1,871 | 1,483 | 1,320 | 1,413 | 1,062 | 310 | 8,915 | 100% |

** ទិន្នន័យឆ្នាំ២០០១ មានតែសំរាប់ឆមាសទី១ ។** ទិន្នន័យនៅភ្នំពេញត្រូវបានរក្សាទុកដោយសាលាក្រុងភ្នំពេញ ហើយមិនបានបញ្ចូលក្នុងកំរងទិន្នន័យនេះទេ ។*

## តារាង៣.២.ខ. ទំហំដីលំនៅដ្ឋានដែលបានលក់ តាមខេត្ត-ក្រុង ពីឆ្នាំ១៩៩៥ ដល់ ២០០១

| ទីតាំងដីដែលបានលក់ | ផ្ទៃដី, ហិកតា | | | | | | | សរុប (១៩៩៥-២០០១) | |
|---|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001* | ផ្ទៃដី (ហ.ត) | % |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 235.6 | 217.6 | 225.2 | 164.7 | 113.1 | 52.13 | 11 | 1019.304 | 75% |
| ភ្នំពេញ** | | | | | | | | | |
| កណ្តាល | 165.7 | 129.5 | 55.8 | 57.3 | 47.4 | 3.7 | .. | 459.4 | 34% |
| សៀមរាប | 25.0 | 47.8 | 23.8 | 19.7 | 27.0 | 28.1 | 6.7 | 178.0 | 13% |
| ព្រះសីហនុ | 14.6 | 6.4 | 15.9 | 3.7 | 4.8 | 13.5 | 2.5 | 61.3 | 5% |
| បាត់ដំបង | 28.3 | 27.9 | 122.8 | 78.5 | 28.8 | 2.6 | 0.6 | 289.5 | 21% |
| កំពង់ចាម | 2.0 | 6.1 | 6.9 | 5.5 | 5.2 | 4.3 | 1.2 | 31.1 | 2% |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 48.7 | 56.0 | 75.8 | 57.1 | 47.3 | 41.1 | 16.9 | 342.9 | 25% |
| បន្ទាយមានជ័យ | 2.6 | 3.4 | 7.6 | 6.0 | 5.2 | 5.5 | 3.7 | 33.9 | 2% |
| កំពង់ឆ្នាំង | 16.4 | 13.8 | 24.5 | 5.1 | 4.0 | 3.2 | 1.1 | 68.1 | 5% |
| កំពង់ស្ពឺ | 2.5 | 6.8 | 2.0 | 5.5 | 4.3 | 2.2 | 0.0 | 23.4 | 2% |
| កំពង់ធំ | 0.5 | 5.2 | 5.0 | 9.0 | 4.3 | 7.2 | 2.6 | 33.8 | 2% |
| កំពត | 1.5 | 4.8 | 2.6 | 3.4 | 4.8 | 2.7 | 1.6 | 21.4 | 2% |
| ក្រុងកែប | 0.4 | 6.1 | 7.8 | 5.8 | 2.9 | 2.6 | 1.4 | 26.9 | 2% |
| កោះកុង | 21.3 | 3.1 | 4.1 | 0.5 | 1.6 | 0.8 | 0.2 | 31.4 | 2% |
| ក្រចេះ | 0.6 | 6.0 | 1.7 | 10.7 | 1.6 | 2.3 | 1.0 | 24.0 | 2% |
| ព្រៃវែង | 0.9 | 0.4 | 1.6 | 2.5 | 0.7 | 0.8 | 0.1 | 7.0 | 1% |
| ពោធិសាត់ | 0.0 | 0.6 | 1.1 | 0.2 | 1.0 | 0.5 | 0.0 | 3.5 | 0% |
| រតនគិរី | .. | .. | 0.2 | 0.5 | 0.6 | 0.9 | 0.1 | 2.3 | 0% |
| ស្វាយរៀង | 1.9 | 2.5 | 12.7 | 3.6 | 10.5 | 7.5 | 3.8 | 42.6 | 3% |
| តាកែវ | .. | 3.3 | 5.0 | 4.5 | 5.8 | 5.0 | 1.2 | 24.7 | 2% |
| **សរុប** | 284.3 | 273.6 | 301.0 | 221.8 | 160.4 | 93.2 | 27.9 | 1,362.2 | 100% |

** ទិន្នន័យឆ្នាំ២០០១ មានតែសំរាប់ឆមាសទី១ ។** ទិន្នន័យនៅភ្នំពេញត្រូវបានរក្សាទុកដោយសាលាក្រុងភ្នំពេញ ហើយមិនបានបញ្ចូលក្នុងកំរងទិន្នន័យនេះទេ ។*

## តារាង៣.៣.ក. ប្រតិបត្តិការលក់ដីលំនៅដ្ឋាន តាមតំបន់ទីក្រុង និងជនបទ (ចំនួនប្រតិបត្តិការ)

| ទីតាំងដីដែលបានលក់ | ចំនួននៃប្រតិបត្តិការលក់ដី (១៩៩៥-២០០១) | | | | |
|---|---|---|---|---|---|
| | ទីក្រុង | | ជនបទ | | សរុប |
| | ចំនួន | ចំនួនភាគរយសរុប | ចំនួន | ចំនួនភាគរយសរុប | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 3,064 | 55% | 2,474 | 45% | 5,538 |
| កណ្តាល | 963 | 32% | 2,072 | 68% | 3,035 |
| សៀមរាប | 1,237 | 94% | 79 | 6% | 1,316 |
| ព្រះសីហនុ | 340 | 100% | .. | 0% | 340 |
| បាត់ដំបង | 372 | 84% | 72 | 16% | 444 |
| កំពង់ចាម | 152 | 38% | 251 | 62% | 403 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 2,023 | 60% | 1,354 | 40% | 3,377 |
| បន្ទាយមានជ័យ | 189 | 28% | 491 | 72% | 680 |
| កំពង់ឆ្នាំង | 189 | 59% | 132 | 41% | 321 |
| កំពង់ស្ពឺ | 101 | 46% | 119 | 54% | 220 |
| កំពង់ធំ | 271 | 84% | 53 | 16% | 324 |
| កំពត | 283 | 75% | 96 | 25% | 379 |
| ក្រុងកែប | 114 | 100% | .. | 0% | 114 |
| កោះកុង | 118 | 86% | 20 | 14% | 138 |
| ក្រចេះ | 217 | 94% | 15 | 6% | 232 |
| ព្រៃវែង | 29 | 31% | 66 | 69% | 95 |
| ពោធិសាត់ | 31 | 79% | 8 | 21% | 39 |
| រតនគីរី | 44 | 100% | .. | 0% | 44 |
| ស្វាយរៀង | 225 | 64% | 128 | 36% | 353 |
| តាកែវ | 212 | 48% | 226 | 52% | 438 |
| **សរុប** | 5,087 | 57% | 3,828 | 43% | 8,915 |

## តារាង៣.៣.ខ. ប្រតិបត្តិការលក់ដីលំនៅដ្ឋាន តាមតំបន់ទីក្រុង និងជនបទ (ផ្ទៃក្រឡា)

| ទីតាំងដីដែលបានលក់ | ផ្ទៃដីដែលបានលក់ ហិកតា (១៩៩៥-២000) | | | | |
|---|---|---|---|---|---|
| | ទីក្រុង | | ជបបទ | | |
| | ចំនួន | សរុបជាភាគរយ | ចំនួន | សរុបជាភាគរយ | ផ្ទៃដី សរុប |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | *534* | *53%* | *483* | *47%* | *1,017* |
| កណ្តាល | 90 | 20% | 367 | 80% | 457 |
| សៀមរាប | 167 | 94% | 11 | 6% | 178 |
| ព្រះសីហនុ | 61 | 100% | .. | .. | 61 |
| បាត់ដំបង | 209 | 72% | 81 | 28% | 289 |
| កំពង់ចាម | 7 | 23% | 24 | 77% | 31 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | *184* | 54% | *158* | 46% | *343* |
| បន្ទាយមានជ័យ | 8 | 23% | 26 | 77% | 34 |
| កំពង់ឆ្នាំង | 31 | 45% | 37 | 55% | 68 |
| កំពង់ស្ពឺ | 12 | 50% | 12 | 50% | 23 |
| កំពង់ធំ | 25 | 74% | 9 | 26% | 34 |
| កំពត | 12 | 56% | 9 | 44% | 21 |
| ក្រុងកែប | 27 | 100% | .. | .. | 27 |
| កោះកុង | 28 | 88% | 4 | 12% | 31 |
| ក្រចេះ | 9 | 38% | 15 | 62% | 24 |
| ព្រៃវែង | 2 | 29% | 5 | 71% | 7 |
| ពោធិសាត់ | 3 | 74% | 1 | 26% | 3 |
| រតនគីរី | 2 | 100% | .. | .. | 2 |
| ស្វាយរៀង | 12 | 28% | 31 | 72% | 43 |
| តាកែវ | 15 | 60% | 10 | 40% | 25 |
| **សរុប** | *719* | *53%* | *641* | *47%* | *1,360* |

### ៣.២.៥. លំនៅដ្ឋានរបស់អ្នកទិញ អ្នកលក់ និងទីតាំងដី

ជាការសំខាន់មួយដែរដែលគេគួរដឹងថា តើអ្នកទិញដីលំនៅដ្ឋានមកពីណា ។ ពត៌មាននេះនឹងបញ្ជាក់គាំទ្រ ឬបដិសេធសម្មតិកម្មដែលថា អ្នកមាននៅទីក្រុងច្រើនតែទិញដីយកពីអ្នកក្រនៅជនបទ[៧] ។ តារាង៣.៤ បង្ហាញថា ប្រជាជនមកពីខេត្ត-ក្រុង ធំៗទាំង៦ ដែលគេបានចាត់ចូលជាខេត្ត-ក្រុងមានទីប្រជុំជនធំ បានទិញដីចំនួន ៦.១៣៣ប្រតិបត្តិការ ត្រូវជា ៧០%នៃចំនួនសរុប ក្នុងកំរងទិន្នន័យ។ ចំនួននេះត្រូវជា ១.១០៧ហត នៃផ្ទៃដីលំនៅដ្ឋាន ឬ ៨៤%នៃផ្ទៃដីដែលបានលក់សរុបពីឆ្នាំ១៩៩៥-២០០០[៨] ។ ភាគច្រើនបំផុតនៃអ្នកទិញមានអាសយដ្ឋាននៅភ្នំពេញ ហើយតំណាងឱ្យ ៣៩% (ឬ៣.៣៩៩ប្រតិបត្តិការ) នៃអ្នកទិញសរុប ដោយទិញយក ៥០%នៃផ្ទៃដីលំនៅដ្ឋានដែលគេបានលក់នៅក្រៅទីក្រុងភ្នំពេញ ។ ការដែល ៣៩%នៃអ្នកទិញ បានទិញយក ៥០%នៃផ្ទៃដី វាបង្ហាញឱ្យឃើញដែរថា ប្រតិបត្តិការទិញដីទាំងនេះ ទាក់ទិននឹងដីឡូត៍ដែលមានទំហំធំៗ ។

ផ្ទុយមកវិញ ទិន្នន័យបង្ហាញថា អ្នកទិញមានលំនៅដ្ឋាននៅក្នុងខេត្តតូចៗទាំង១៦ បានទិញតែ ៣០%នៃប្រតិបត្តិការទិញដីឡូត៍ ឬ ១៦%នៃផ្ទៃដីសរុបដែលគេបានលក់ ដែលបង្ហាញឱ្យឃើញថា អ្នកនៅក្នុងខេត្តតូចៗច្រើនតែទិញដីឡូត៍តូចៗជាង ។

តាមការពិនិត្យត្រួសៗនូវទិន្នន័យ គេអាចសន្និដ្ឋានថា អ្នកនៅក្រុងភ្នំពេញបានចូលរួមទិញដីយ៉ាងច្រើន សំរាប់ធ្វើផលិតកម្ម ឬសំរាប់ទុកលក់ ហើយមានការប្រមូលផ្តុំធនធានយ៉ាងច្រើននៅក្នុងរាជធានី ។ អ្នកនៅខេត្ត កណ្តាល សៀមរាប និង បាត់ដំបង (សុទ្ធតែមានក្រុងធំៗ) ក៏បានទិញដីច្រើនគួរកត់សំគាល់ដែរក្នុងរយៈពេលកន្លងទៅ បើគិតនៅក្នុងគំរូតាងនេះ ។ ប៉ុន្តែដូចបានរៀបរាប់នៅខាងលើរួច គំរូតាងមានលំអៀងដ៏ធំមួយ ហើយការសន្និដ្ឋានដោយប្រញាប់ប្រញាល់អាចជាការខុសឆ្គង ។ ឧទាហរណ៍ អ្នកទិញរស់នៅក្នុងក្រុងភ្នំពេញដែលច្រើនតែមានការអប់រំខ្ពស់ជាង អាចទាមទារឱ្យមានក្រដាសស្នាមត្រឹមត្រូវសំរាប់ការទិញដី ។ លើសពីនេះទៀត ដោយសារពួកគេរស់នៅទីកន្លែងមួយឆ្ងាយពីដីធ្លីដែលទិញ ដូច្នេះពួកគេអាចទទូចឱ្យមានក្រដាសស្នាមត្រឹមត្រូវ ដើម្បីធានាសុវត្ថិភាពនៃកម្មសិទ្ធិ ។ ផ្ទុយទៅវិញ អ្នកទិញដែលរស់នៅក្នុងតំបន់ជនបទ រួមទាំងកសិករផង អាចមិន បានដឹងពីតំរូវការក្រដាសស្នាម ឬមិនបានខិតខំធ្វើលិខិតស្នាមត្រឹមត្រូវ ដើម្បីបញ្ជាក់ពីការផ្ទេរដី ។ ដូច្នេះទើបឈ្មោះរបស់ពួកគេ ពុំឃើញមាននៅក្នុងគំរូតាង ។ គេរកឃើញដែរថា សកម្មភាពសុរិយោដីនៅតាមតំបន់ផ្សេងៗនៃកម្ពុជា មិនបានស្មើៗគ្នាល្អទេ ។ នៅតំបន់ខ្លះ ការិយាល័យសុរិយោដីគ្មានជំនាញ ឬមានជំនាញតិចតួចក្នុងបច្ចេកទេសវាស់វែង និងធ្វើផែនទីដី ហើយនេះអាចជាមូលហេតុមួយធ្វើឱ្យការជួញដូរដីធ្លីតែមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានចុះបញ្ជីនៅក្នុងតំបន់ទាំងនោះ (So et al 2001) ។

ផ្អែកតាមទិន្នន័យនេះ ចំនួននៃប្រតិបត្តិការការលក់ដីលំនៅដ្ឋាននៅទីក្រុង មានកំរិតខ្ពស់ជាងនៅតំបន់ជនបទ ។ លើសពីនេះទៀត អ្នករស់នៅក្នុងខេត្តមានទីប្រជុំជនធំៗ បានទិញដីធំៗជាងអ្នករស់នៅក្នុងខេត្តតូចៗ ។ អ្នករស់នៅក្នុងភ្នំពេញ បានទិញដីនៅជនបទ ច្រើនជាងនៅតំបន់ទីក្រុង ។ រឿងនេះអាចបណ្តាលមកពី ដីនៅទីក្រុងមិនមានចំនួនច្រើនសំរាប់លក់ទេ ហើយដីដែលដាក់លក់អាចមានតំលៃខ្ពស់ពេក ។

ដោយសារអ្នកភ្នំពេញ ជាអ្នកទិញដីលំនៅដ្ឋានក្រៅក្រុងភ្នំពេញច្រើនជាងគេ ដូច្នេះគេគួរពិនិត្យមើលឱ្យបានលំអិតថែមទៀតអំពីដីដែលពួកគេបានទិញតាមឆ្នាំ និងក្នុងខេត្តនីមួយៗ ។ តារាង៣.៥.ក បង្ហាញថា ចំនួនដីដែលបានលក់ជាផ្លូវការឱ្យអ្នក

[៧] គួររំលឹកឡើងវិញថា នៅពេលបើកចំហសេដ្ឋកិច្ច ចំនួនអ្នកពាក់ពាន់នឹងដីធ្លីបានកើនចំនួន ហើយដីមានសក្តានុពលអាចឡើងថ្លៃខ្ពស់ បានទាក់ទាញអតិថិជនជាច្រើន ។ ការលើកឡើងនេះ សំអាងទៅលើការសិក្សាតូចៗមួយចំនួនដែលបានធ្វើកន្លងមក (សូមមើលឯកសាររបស់ William 1999; Kato 1999) ។

[៨] ដីខ្លះអាចត្រូវបានលក់លើសពីមួយដង ដូចនេះចំនួននេះអាចជាការប៉ាន់ស្មានលើស ។

ភ្នំពេញ បានកើនឡើងខ្ពស់បំផុតនៅឆ្នាំ១៩៩៦ រហូតដល់ ៩២៥ឡូតិ៍ ។ បន្ទាប់មក ចំនួននេះបានធ្លាក់ចុះយ៉ាងខ្លាំង រហូតដល់ឆមាសទី១ ឆ្នាំ២០០១ ដែលមានតែ ៥៣ប្រតិបត្តិការទិញដីឡូតិ៍ប៉ុណ្ណោះ ។

**តារាង៣.៤. តើអ្នកទិញដីលំនៅដ្ឋាន មកពីណា?**

| ទីតាំងរបស់អកទិញ | ចំនួននៃប្រតិបត្តិការលក់ដីធ្លី (១៩៩៥-២000) | | | | ផ្ទៃដី គិតជាហិកតា | | | សរុបជា % |
|---|---|---|---|---|---|---|---|---|
| | ទីក្រុង | ជនបទ | សរុប | សរុបជា% | ទីក្រុង | ជនបទ | សរុប | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 3,355 | 2,778 | 6,133 | 70.1% | 569 | 538 | 1,107 | 83.7% |
| ភ្នំពេញ** | 1,531 | 1,868 | 3,399 | 38.8% | 275 | 373 | 648 | 49.0% |
| កណ្តាល | 502 | 371 | 873 | 10.0% | 32 | 41 | 73 | 5.5% |
| សៀមរាប | 723 | 65 | 788 | 9.0% | 72 | 6 | 79 | 5.9% |
| ព្រះសីហនុ | 129 | 59 | 188 | 2.1% | 13 | 12 | 25 | 1.9% |
| បាត់ដំបង | 329 | 155 | 484 | 5.5% | 170 | 78 | 248 | 18.7% |
| កំពង់ចាម | 141 | 260 | 401 | 4.6% | 7 | 28 | 34 | 2.6% |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 1,699 | 920 | 2,619 | 29.9% | 143 | 72 | 215 | 16.3% |
| បន្ទាយមានជ័យ | 195 | 282 | 477 | 5.5% | 17 | 19 | 37 | 2.8% |
| កំពង់ឆ្នាំង | 147 | 62 | 209 | 2.4% | 24 | 9 | 33 | 2.5% |
| កំពង់ស្ពឺ | 65 | 81 | 146 | 1.7% | 7 | 4 | 11 | 0.8% |
| កំពង់ធំ | 245 | 48 | 293 | 3.3% | 21 | 7 | 28 | 2.1% |
| កំពត | 208 | 66 | 274 | 3.1% | 7 | 4 | 11 | 0.8% |
| ក្រុងកែប | 6 | .. | 6 | 0.1% | 1 | .. | 1 | 0.1% |
| កោះកុង | 136 | 51 | 187 | 2.1% | 29 | 8 | 37 | 2.8% |
| ក្រចេះ | 205 | 13 | 218 | 2.5% | 8 | 1 | 8 | 0.6% |
| មណ្ឌលគិរី | 1 | .. | 1 | 0.0% | 0 | .. | 0 | 0.0% |
| ព្រះវិហារ | 1 | 1 | 2 | 0.0% | 0 | 0 | 0 | 0.0% |
| ព្រៃវែង | 23 | 46 | 69 | 0.8% | 1 | 3 | 4 | 0.3% |
| ពោធិសាត់ | 25 | 9 | 34 | 0.4% | 2 | 1 | 2 | 0.2% |
| រតនគិរី | 43 | .. | 43 | 0.5% | 2 | .. | 2 | 0.2% |
| ស្ទឹងត្រែង | 1 | 1 | 2 | 0.0% | 0 | 0 | 0 | 0.0% |
| ស្វាយរៀង | 199 | 61 | 260 | 3.0% | 10 | 9 | 19 | 1.4% |
| តាកែវ | 199 | 199 | 398 | 4.5% | 14 | 7 | 21 | 1.6% |
| *សរុប* | 5,054 | 3,698 | 8,752 | 100.0% | 712 | 610 | 1,322 | 100.0% |

* *ទិន្នន័យនៅភ្នំពេញត្រូវបានរក្សាទុកដោយសាលាក្រុងភ្នំពេញ ហើយមិនត្រូវបានបញ្ចូលនៅក្នុងទិន្នន័យក្នុងរបាយការណ៍នេះទេ ។*

តារាង៣.៥ បែងចែកខេត្តនានាដែលមានដីលំនៅដ្ឋានបានលក់ទៅឱ្យអ្នកភ្នំពេញ ។ ខេត្តកណ្តាល មានដីច្រើនជាងគេ (៦0% ឬ ១៩00ឡូតិ៍) ដែលបានលក់ទៅឱ្យអ្នកភ្នំពេញ ពីព្រោះខេត្តនេះនៅព័ទ្ធជុំវិញរាជធានី ដូច្នេះជាជំរើសទី១របស់អ្នកភ្នំពេញ ទោះបីដីមានតំលៃខ្ពស់ក៏ដោយ ។ អ្នកភ្នំពេញជាច្រើនទិញដីយកធ្វើជា ចំការ/ផ្ទះលំហែកាយ ធ្វើជារោងចក្រ ឬសំរាប់ទុក លក់យកចំណេញ រីឯមួយចំនួនទៀតទិញដីសំរាប់ធ្វើលំនៅដ្ឋាន ហើយអ្នករស់នៅខេត្តកណ្តាល ប៉ុន្តែធ្វើដំណើរចុះឡើងទៅធ្វើការ ឬប្រកបរបរនៅក្រុងភ្នំពេញ វាមិនមែនជារឿងចំលែកទេអ្វីទេ។

អ្នកទិញដីជាអ្នកភ្នំពេញ បានទិញដីលំនៅដ្ឋានចំនួន ៥0៨ឡូតិ៍នៅខេត្តសៀមរាប និង ១៩១ឡូតិ៍នៅក្រុងព្រះសីហនុ ។ ខេត្ត-ក្រុងទាំងពីរនេះស្ថិតនៅក្នុងចំណាត់ថ្នាក់ខេត្តមានទីប្រជុំជនធំ ។ អ្នកភ្នំពេញបានទិញដីប្រហែល ១00ឡូតិ៍ផងដែរនៅខេត្តកំពត និងកែប ។ ជាការមួយគួរឱ្យឆ្ងល់ដែរ ដោយចំនួនដីលំនៅដ្ឋាននៅក្រុងព្រះសីហនុ ដែលបានលក់ទៅឱ្យអ្នកភ្នំពេញបានកើនឡើងខ្ពស់បំផុតនៅឆ្នាំ២000 ខណៈដែលនិន្នាការជាទូទៅបានកើនខ្ពស់បំផុតនៅឆ្នាំ១៩៩៦ ។

រឿងសំខាន់គួរកត់សំគាល់មួយទៀតគឺថា នៅក្នុងកំរងទិន្នន័យនេះ ក្រៅពីខេត្តកណ្តាលចេញ ចំនួនដីឡូតិ៍ដែលបានផ្លាស់ប្តូរម្ចាស់ មិនដែលច្រើនលើសពីបីខ្ទង់ទេ ។ តួរលេខដ៏តូចបែបនេះ ពោលគឺប្រហែល ៥.000-៦.000ឡូតិ៍ ដែលបានលក់នៅ

ទូទាំងប្រទេសក្នុងរយៈ ៦ឆ្នាំ មិនគួរជាប្រការគួរឱ្យបារម្ភទេ ។ ក៏ប៉ុន្តែដូចបានបញ្ជាក់ច្រើនលើកហើយ កំរងទិន្នន័យនេះមិនអាចតំណាងឱ្យប្រទេសទាំងមូលបានល្អទេ ។

**តារាង៣.៥. ប្រតិបត្តិការលក់ដីលំនៅដ្ឋានទៅឱ្យអ្នកភ្នំពេញ**

| ទីតាំងដី | ចំនួនប្រតិបត្តិការទិញដោយអ្នកភ្នំពេញ | | | | | | | | ទិញដោយអ្នកផ្សេង |
|---|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | (95-00) | (95-00) |
| កណ្តាល | 452 | 622 | 327 | 254 | 229 | 16 | .. | 1,900 | 1,135 |
| សៀមរាប | 68 | 105 | 89 | 73 | 83 | 82 | 8 | 508 | 808 |
| ក្រុងព្រះសីហនុ | 29 | 39 | 19 | 22 | 27 | 49 | 6 | 191 | 149 |
| ក្រុងកែប | 1 | 17 | 29 | 19 | 20 | 9 | 4 | 99 | 15 |
| កំពត | 9 | 18 | 14 | 14 | 15 | 10 | 14 | 94 | 285 |
| កំពង់ឆ្នាំង | 5 | 33 | 29 | 10 | 6 | 7 | 3 | 93 | 228 |
| ស្វាយរៀង | 4 | 10 | 34 | 7 | 16 | 17 | 4 | 92 | 261 |
| បន្ទាយមានជ័យ | 5 | 12 | 18 | 22 | 5 | 22 | 7 | 91 | 589 |
| បាត់ដំបង | 16 | 18 | 30 | 6 | 9 | 2 | .. | 81 | 363 |
| កំពង់ស្ពឺ | 13 | 16 | 8 | 8 | 18 | 4 | 1 | 68 | 152 |
| កំពង់ចាម | 4 | 11 | 10 | 3 | 12 | 11 | .. | 51 | 352 |
| តាកែវ | .. | 13 | 13 | 4 | 4 | 8 | 1 | 43 | 395 |
| ព្រៃវែង | 1 | 2 | 11 | 11 | 1 | 2 | 2 | 30 | 65 |
| កំពង់ធំ | 2 | 3 | 8 | 5 | 7 | 3 | 1 | 29 | 295 |
| ក្រចេះ | 1 | 4 | 2 | 6 | .. | .. | 2 | 15 | 217 |
| កោះកុង | 1 | .. | 3 | 1 | .. | .. | .. | 5 | 133 |
| ពោធិសាត់ | .. | 2 | 1 | .. | 1 | 1 | .. | 5 | 34 |
| រតនគិរី | .. | .. | .. | 1 | 1 | 2 | .. | 4 | 40 |
| *សរុប* | *611* | *925* | *645* | *466* | *454* | *245* | *53* | *3,399* | *5,516* |

ទិន្នន័យនេះ ត្រូវបានបែងចែកបន្តទៀត ដើម្បីពិនិត្យមើលថា តើអ្នកទិញ និងអ្នកលក់ មានអាសយដ្ឋានដូចគ្នានឹងទីតាំងដីឬទេ ។ ស្រុក គឺជាឯកតាសំរាប់ការវិភាគបែងចែករវាង អ្នកទិញ/អ្នកលក់ដែលមកពីក្រៅ និងអ្នកនៅនឹងមូលដ្ឋាន ។ អាចនិយាយម្យ៉ាងទៀតថា តើអ្នកទិញ និងអ្នកលក់ ជាអ្នករស់នៅក្នុងស្រុកដែលដីឡូតិ៍តាំងនៅ ឬក៏មកពីស្រុកផ្សេង? ក្នុងចំណោម ៨.៩១៥ប្រតិបត្តិការការទិញ-លក់ជាផ្លូវការពីឆ្នាំ១៩៩៥ ដល់ ២០០១ គឺមាន ៨.៧៤២ករណីដែលមានបញ្ជាក់ពីអាសយដ្ឋានអ្នកទិញ រីឯ ១៧៣ករណីទៀតគ្មានកត់អាសយដ្ឋានទេ ហើយត្រូវបានលុបចេញពីការវិភាគនេះ[៩] ។ តារាង៣.៤ បង្ហាញថា ប្រហែលពាក់កណ្តាលនៃអ្នកទិញដីលំនៅដ្ឋាន គឺមកពីស្រុកផ្សេង ក្រៅពីស្រុកដែលដីតាំងនៅ ។ ក្នុងចំនោមអ្នកក្រៅទាំង ៤.៤៣៧នាក់នេះ មាន ៣.៣៩៩នាក់មកពីភ្នំពេញ ។

ភាគរយនៃអ្នកទិញដីមកពីស្រុកផ្សេង បានធ្លាក់ចុះជាលំដាប់ ចាប់តាំងពីឆ្នាំ១៩៩៥ ដល់ ២០០១ (តារាង៣.៦.ក) ។ នៅឆ្នាំ១៩៩៥, ៦០%ក្នុងចំណោមអ្នកទិញ១.៣៤០នាក់ គឺមកពីស្រុកផ្សេង ក្រៅពីស្រុកដែលដីតាំងនៅ រីឯនៅឆ្នាំ២០០០ វិញមានតែ ៣២%ប៉ុណ្ណោះ ។ តួលេខសំរាប់ឆ្នាំ២០០១ កាន់ទាបថែមទៀតគឺ ២៦% ក៏ប៉ុន្តែគេមិនអាចធៀបជាមួយឆ្នាំមុនៗបានទេ ពីព្រោះតួលេខឆ្នាំ២០០១ មានតែសំរាប់ឆមាសទី១ប៉ុណ្ណោះ ។ ទោះយ៉ាងនេះក្តី គេឃើញមានការធ្លាក់ចុះយ៉ាងខ្លាំង ។ គេអាចពន្យល់បានថា នៅពេលដែលទីផ្សារដីធ្លីទើបនឹងបើកឡើង និងនៅពេលដែលថ្លៃដីនៅទាប អ្នកភ្នំពេញជាច្រើនបានចាប់ផ្តើមទិញដីនៅតាមតំបន់ផ្សេងៗ។ នៅពេលថ្លៃដីកើនឡើង (ក៏រិតចំណេញថយចុះ) ការទិញដីក៏បានថយចុះវិញ។ នៅពេលនោះដែរ អ្នកទិញ ទំនងជាបានទិញគ្រប់គ្រាន់ ឯដីល្អៗក៏បានលក់អស់ ។ អង្កេតតាមស្រុករបស់យើងបានបង្ហាញថា អ្នកភ្នំពេញទិញដីលំនៅដ្ឋាន មិន មែនសំរាប់តាំងទីលំនៅទេ ប៉ុន្តែសំរាប់ទុកលក់យកចំនេញ ឬធ្វើជាកន្លែងលំហែ ។

[៩] តាមធម្មតា អ្នកទិញត្រូវតែផ្តល់អាសយដ្ឋានរបស់ពួកគេ ។ មតិខ្លះបាននិយាយថា មានអ្នកទិញមួយចំនួនលាក់បាំងអាសយដ្ឋានរបស់ខ្លួន ប៉ុន្តែ គ្មានមូលហេតុអ្វីដែលគួរឱ្យជឿឡើយ ។ អាចមានការខុសឆ្គងផ្នែករដ្ឋបាលដែលបានកើតឡើង ។

**តារាង៣.៦.ក. អាសយដ្ឋានរបស់អ្នកទិញ ដីលំនៅដ្ឋាន ធៀបនឹងទីតាំងដី**

| ឆ្នាំទិញ-លក់ដី | លំនៅដ្ឋានរបស់អ្នកទិញ | | | | សរុប | |
|---|---|---|---|---|---|---|
| | នៅក្នុងស្រុកដែល ដីតាំងនៅ | | មកពីស្រុកផ្សេង ពីស្រុកដែលដីតាំងនៅ | | | |
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| 1995 | 541 | 40% | 799 | 60% | 1,340 | 100% |
| 1996 | 734 | 39% | 1,125 | 61% | 1,859 | 100% |
| 1997 | 642 | 44% | 822 | 56% | 1,464 | 100% |
| 1998 | 691 | 53% | 617 | 47% | 1,308 | 100% |
| 1999 | 841 | 60% | 570 | 40% | 1,411 | 100% |
| 2000 | 720 | 68% | 335 | 32% | 1,055 | 100% |
| 2001 | 226 | 74% | 79 | 26% | 305 | 100% |
| សរុប | 4,395 | 50% | 4,347 | 50% | 8,742 | *100%* |

តារាង៣.៦.ខ បង្ហាញថា ប្រហែល ២0% នៃអ្នកលក់ដីលំនៅដ្ឋានទាំងអស់ មានអាសយដ្ឋាននៅស្រុកផ្សេងពីទីតាំងដីដែលគេលក់ ។ ស្ថិតិនេះទំនងជាបង្ហាញនូវការលក់ដីជាថ្មី ក្រោយពីការទិញទុកយកចំណេញដោយអ្នកមកពីខាងក្រៅ ។ សភាពការណ៍នេះត្រូវបានបញ្ជាក់ថាពិត តាមរយៈអង្កេតទ្រង់ទ្រាយតូចនានា ។ មន្ត្រីភូមិបាលបានរាយការណ៍ថា ដីមួយចំនួនបានផ្លាស់ប្តូរម្ចាស់លើសពីមួយដងក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយ ។ មូលហេតុមួយទៀត អាចមកពីម្ចាស់ដីបានផ្លាស់ទីលំនៅទៅកន្លែងផ្សេង ហើយក៏បានលក់ដីធ្លី ដើម្បីទៅទិញផ្ទះសំបែងនៅកន្លែងថ្មី ប៉ុន្តែរឿងបែបនេះប្រហែលមានមិនច្រើនទេ ពីព្រោះទិន្នន័យមកមកវិភាគនៅទីនេះ ទាក់ទិនតែនឹងដីឡូត៍មានប័ណ្ណប្លង់ដីត្រឹមត្រូវប៉ុណ្ណោះ ។ ភាគច្រើននៃដីទាំងនេះ ទំនងជាកាន់កាប់ដោយក្រុមអ្នកមានដែលមិនសូវប្តូរទីលំនៅញឹកញាប់ទេ ។

**តារាង៣.៦.ខ. អាសយដ្ឋានរបស់អ្នកលក់ដីលំនៅដ្ឋាន ធៀបនឹងទីតាំងដី**

| ឆ្នាំលក់ដី | លំនៅដ្ឋានរបស់អ្នកលក់ | | | | សរុប | |
|---|---|---|---|---|---|---|
| | នៅក្នុងស្រុកដែល ដីតាំងនៅ | | នៅក្នុងស្រុកផ្សេង ពីស្រុកដែលដីតាំងនៅ | | | |
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| 1995 | 1,210 | 83% | 245 | 17% | 1,455 | 100% |
| 1996 | 1,473 | 79% | 392 | 21% | 1,865 | 100% |
| 1997 | 1,062 | 72% | 415 | 28% | 1,477 | 100% |
| 1998 | 998 | 77% | 306 | 23% | 1,304 | 100% |
| 1999 | 1,123 | 80% | 276 | 20% | 1,399 | 100% |
| 2000 | 798 | 76% | 250 | 24% | 1,048 | 100% |
| 2001 | 249 | 84% | 49 | 16% | 298 | 100% |
| សរុប | *6,913* | *78%* | *1,933* | *22%* | *8,846* | *100%* |

### *៣.២.៦. ទំហំដី*

តារាង៣.៧ បង្ហាញថា ដីមានទំហំខុសៗគ្នាយ៉ាងខ្លាំងត្រូវបានគេទិញ-លក់ ។ ប្រហែល ៤៥%នៃប្រតិបត្តិការទិញ-លក់សរុប ទាក់ទិននឹងដីឡូត៍មានទំហំ ៥00ម៉ែត្រការ៉េឬតូចជាង និងតំណាងឱ្យត្រឹមតែ ៦% នៃផ្ទៃដីលំនៅដ្ឋានសរុបដែលគេបានលក់ប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ប្រតិបត្តិការទិញ-លក់ដីឡូត៍មានទំហំលើសពី ៥.000ម៉ែត្រការ៉េ ដែលតំណាងឱ្យតែ ៣%នៃចំនួនប្រតិ-បត្តិការទិញ-លក់សរុប, វាមានទំហំដល់ទៅ ៤៥%នៃផ្ទៃដីលំនៅដ្ឋានសរុបដែលគេបានលក់ ។ តារាង ៣.៨.ក និង ៣.៨.ខ បង្ហាញនូវ ខេត្ត-ក្រុងដែលមានដីឡូត៍លក់ធំៗ និងខេត្ត-ក្រុងដែលអ្នកទិញគេរស់នៅ ។

នៅទីក្រុងមានប្រតិបត្តិការទិញ-លក់ដីលំនៅដ្ឋានច្រើនជាងនៅទីជនបទ សំរាប់ដីទាំងធំទាំងតូច លើកលែងតែដីឡូត៍ទំហំ ១.២០០-៥.០០០ម៉ែត្រការ៉េចេញ។ ក្នុងទំហំ ១.២០០-៥.០០០ម៉ែត្រការ៉េ មាន ៩២១ដីឡូត៍ត្រូវជា ១៩២ហិកតានៅតំបន់ទីក្រុង និង ១.១៥៣ឡូត៍ ត្រូវជា ២៦០ហិកតានៅជនបទ ដែលត្រូវបានទិញ-លក់ ។ តួលេខនេះអាចមានន័យថា នៅតំបន់ទីក្រុង មិនសំបូណ៌ដីឡូត៍ធំៗដូចនៅជនបទទេ ឬក៏វាថ្លៃខ្លាំងពេក ។

វិធីមួយដើម្បីធ្វើចំណាត់ថ្នាក់ដី គឺចែកជាក្រុមដែលមានទំហំដល់ ១.២០០ម៉ែត្រការ៉េ និងក្រុមមានទំហំលើស១.២០០ម៉ែត្រការ៉េ ដោយមូលហេតុថា រដ្ឋាភិបាលមានគោលនយោបាយយកពន្ធលើដីមានទំហំលើសពី ១.២០០ម៉ែត្រការ៉េ ដែលទុកឱ្យនៅទំនេរចោល[១០] ។ ដូចមានបង្ហាញនៅក្នុង តារាង៣.៧ និង ៣.៨.ក មានដីលំនៅដ្ឋានជាច្រើនឡូត៍ដែលមានទំហំលើសពី ១.២០០ម៉ែត្រការ៉េ គឺមាន ២.៣២៦ឡូត៍ក្នុងចំណោម ៨.៩១៥ឡូត៍ដែលស្ថិតក្នុងចំណាត់ថ្នាក់នេះ ។ ក្នុងចំណោមដីទាំង ២.៣២៦ឡូត៍ មាន ១.៣២៣ឡូត៍ ត្រូវបានទិញដោយអ្នកភ្នំពេញ (តារាង៣.៨.ខ) ។ ដីធំៗមួយចំនួន ត្រូវបានទិញសំរាប់បើកធ្វើអាជីវកម្ម ។ ប៉ុន្តែមានគេរាយការណ៍ក្នុងពេលចុះអង្កេតថា ដីមួយចំនួនត្រូវបានទិញនិងទុកចោលទំនេរដើម្បីទុកយកចំណេញ។ ដូច្នេះបើសិនគោលនយោបាយពន្ធរបស់រដ្ឋាភិបាលត្រូវបានអនុវត្តយ៉ាងសក្តិសិទ្ធិ អាជ្ញាធរខេត្ត-ក្រុង អាចរកចំណូលបានយ៉ាងច្រើនពីម្ចាស់ដីធំៗ ។

**តារាង៣.៧. ទំហំដីលំនៅដ្ឋាន ដែលគេបានលក់ពីឆ្នាំ១៩៩៥ ដល់ ២០០១**

| | ចំនួនប្រតិបត្តិការលក់ដី | | | | ផ្ទៃដីដែលបានលក់ (ហិកតា) | | | |
|---|---|---|---|---|---|---|---|---|
| ទំហំដី (ម²) | ទីក្រុង | ជនបទ | សរុប | សរុបជា% | ទីក្រុង | ជនបទ | សរុប | សរុបជា% |
| ≤100 | 792 | 419 | 1,211 | 14% | 6 | 3 | 9 | 1% |
| >100 – 500 | 1,690 | 1,032 | 2,722 | 31% | 43 | 27 | 70 | 5% |
| >500 - 1,200 | 1,548 | 1,108 | 2,656 | 30% | 132 | 92 | 223 | 16% |
| >1,200 – 5,000 | 921 | 1,153 | 2,074 | 23% | 192 | 260 | 452 | 33% |
| >5,000 - | 136 | 116 | 252 | 3% | 347 | 261 | 608 | 45% |
| សរុប | 5,087 | 3,828 | 8,915 | 100% | 719 | 643 | 1,362 | 100% |

តារាង៣.៨.ក បង្ហាញថាដីលំនៅដ្ឋានធំៗដែលគេបានលក់នៅតាមខេត្តមានទីប្រជុំជនធំៗ មានចំនួនច្រើនជាងនៅតាមខេត្តមានទីប្រជុំជនតូច ។ ចំពោះដីទំហំ ៥០០ម៉ែត្រការ៉េឬតិចជាង ប្រតិបត្តិការលក់៥៣% ទាក់ទិននឹងដីតាំងនៅក្នុងខេត្តមានទីប្រជុំជនតូច ទោះបីមានតែ ៣៨%នៃប្រតិបត្តិការលក់ដីទំហំគ្រប់ប្រភេទប៉ុណ្ណោះ ដែលស្ថិតនៅក្នុងខេត្តតូចៗទាំងនេះក៏ដោយ (តារាង៣.២.ក) ។ ចំពោះដីធំជាង ៥០០ម៉ែត្រការ៉េ, គឺមាន ៣.៦៧១ប្រតិបត្តិការ ឬ ៧៤%នៃការលក់សរុបចំនួន ៤.៩៨២ ប្រតិបត្តិការដែលទាក់ទិននឹងដីស្ថិតនៅក្នុងខេត្តមានទីប្រជុំជនធំ ។ ខេត្តកណ្តាល និងសៀមរាប មានដីធំៗទិញ-លក់ជាច្រើនដែលឆ្លុះបញ្ចាំងឱ្យឃើញថា មានតំរូវការដីធំៗច្រើនក្នុងខេត្តទាំងពីរនេះ ។

មានការលក់ដីជាច្រើនដែលមានទំហំ ១០០ម៉ែត្រការ៉េ ឬតិចជាង[១១] ។ ជាក់ស្តែងគឺមាន ១.២១១ដីឡូត៍ ឬ ១៤%នៃដីលំនៅដ្ឋានទិញ-លក់ជាផ្លូវការពីឆ្នាំ១៩៩៥ ដល់ ២០០១ ដែលស្ថិតក្នុងប្រភេទនេះ ។ គេឃើញមានយ៉ាងច្រើននូវ ដីឡូត៍មានទំហំតូចជាង ៥០ម៉ែត្រការ៉េ (ឧ. ៥ម x ១០ម) ។ គេអាចឆ្ងល់ថា ហេតុអ្វីបានជាដីតូចៗទាំងនេះ មានប្លង់ និងត្រូវបានផ្ទេរជាផ្លូវការ ។ គេអាចស្មានថា ដីទាំងនេះទំនងជាមានតំលៃខ្ពស់ ពីព្រោះនៅជាប់ផ្លូវធំ នៅក្នុងតំបន់ទីក្រុង ឬទីផ្សារ ។ ហេតុផលមួយទៀតផ្តល់ដោយមន្ត្រីសុរិយោដី គឺចំពោះដីតូចៗជាពិសេស (ប្រហែល២០ម៉ែត្រការ៉េ) តាមពិតដីដែលគេតាំងទីលំនៅជាក់ស្តែងវាធំជាងនេះ ប៉ុន្តែក្នុងការវាស់វែងជាផ្លូវការ គេបានកាត់ "ដីចំណីផ្លូវ" ចេញ[១២] គឺបានន័យថា ចំណែកដីដែលគេតាំងនៅដោយខុសច្បាប់

---

[១០] អាជ្ញាធរខេត្ត-ក្រុង គឺជាអ្នកប្រមូលពន្ធនេះ ។

[១១] ១០០ម² ស្មើនឹង ១០ម x ១០ម ឬ ៥ម x ២០ម ដែលជាទំហំធម្មតាសំរាប់ការសង់ផ្ទះល្វែងមួយនៅក្នុងតំបន់ទីក្រុងនៃប្រទេសកម្ពុជា ។

[១២] ដីដែលមានចំងាយ ២៥ម៉ែត្រសងខាងអ័ក្សផ្លូវមិនមែនជាកម្មសិទ្ធិឯកជនទេ ។ វាជាដីបំរុងសំរាប់ការពង្រីកផ្លូវ ។

មិនមានកត់ត្រានៅក្នុងឯកសារទេ ។

## តារាង៣.៨.ក. ប្រតិបត្តិការទិញ-លក់ដីលំនៅដ្ឋាន គិតតាមទំហំដី

| ទីតាំងដី | ≤100 | >100-500 | >500-1200 | >1200-5000 | >5000 - |
|---|---|---|---|---|---|
| | ទំហំដីដែលគេបានលក់ (ម៉ែ²) | | | | |
| | ចំនួនប្រតិបត្តិការលក់ដី (១៩៩៥-២០០១) | | | | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 530 | 1,337 | 2,006 | 1,494 | 171 |
| កណ្តាល | 248 | 675 | 1,062 | 981 | 69 |
| សៀមរាប | 88 | 264 | 577 | 344 | 43 |
| ក្រុងព្រះសីហនុ | 17 | 85 | 165 | 58 | 15 |
| បាត់ដំបង | 124 | 131 | 99 | 51 | 39 |
| កំពង់ចាម | 53 | 182 | 103 | 60 | 5 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 681 | 1,385 | 650 | 580 | 81 |
| បន្ទាយមានជ័យ | 253 | 267 | 93 | 64 | 3 |
| កំពង់ឆ្នាំង | 27 | 106 | 85 | 78 | 25 |
| កំពង់ស្ពឺ | 17 | 104 | 49 | 46 | 4 |
| កំពង់ធំ | 68 | 120 | 72 | 54 | 10 |
| កំពត | 64 | 212 | 57 | 42 | 4 |
| ក្រុងកែប | .. | 3 | 29 | 73 | 9 |
| កោះកុង | 10 | 59 | 31 | 33 | 5 |
| ក្រចេះ | 44 | 141 | 29 | 12 | 6 |
| ព្រៃវែង | 24 | 30 | 21 | 20 | .. |
| ពោធិសាត់ | 4 | 16 | 6 | 13 | .. |
| រតនគិរី | 12 | 17 | 10 | 5 | .. |
| ស្វាយរៀង | 50 | 131 | 79 | 79 | 14 |
| តាកែវ | 108 | 179 | 89 | 61 | 1 |
| សរុប | 1,211 | 2,722 | 2,656 | 2,074 | 252 |

## តារាង៣.៨.ខ. ចំនួនប្រតិបត្តិការលក់ដីលំនៅដ្ឋាន គិតតាមទំហំដី និងខេត្តរបស់អ្នកទិញ

| ទីតាំងរបស់អ្នកទិញ | ទំហំដីលំនៅដ្ឋានដែលបានលក់ (ម៉ែ²) | | | | | សរុប |
|---|---|---|---|---|---|---|
| | ≤100 | >100-500 | >500-1200 | >1200-5000 | >5000 - | |
| | *ចំនួនប្រតិបត្តិការលក់ដី (១៩៩៥-២០០១)* | | | | | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | *630* | *1,532* | *2,107* | *1,655* | *209* | *6,133* |
| ភ្នំពេញ | 177 | 588 | 1,311 | 1,189 | 134 | 3,399 |
| កណ្តាល | 158 | 327 | 226 | 146 | 16 | 873 |
| សៀមរាប | 79 | 221 | 316 | 158 | 14 | 788 |
| ក្រុងព្រះសីហនុ | 13 | 60 | 62 | 50 | 3 | 188 |
| បាត់ដំបង | 145 | 158 | 96 | 51 | 34 | 484 |
| កំពង់ចាម | 58 | 178 | 96 | 61 | 8 | 401 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | *577* | *1,181* | *514* | *310* | *37* | *2,619* |
| បន្ទាយមានជ័យ | 173 | 195 | 61 | 44 | 4 | 477 |
| កំពង់ឆ្នាំង | 24 | 87 | 54 | 36 | 8 | 209 |
| កំពង់ស្ពឺ | 14 | 81 | 30 | 20 | 1 | 146 |
| កំពង់ធំ | 69 | 116 | 63 | 36 | 9 | 293 |
| កំពត | 58 | 163 | 34 | 17 | 2 | 274 |
| ក្រុងកែប | .. | .. | 5 | .. | 1 | 6 |
| កោះកុង | 13 | 70 | 56 | 42 | 6 | 187 |
| ក្រចេះ | 43 | 134 | 30 | 9 | 2 | 218 |
| មណ្ឌលគិរី | .. | .. | 1 | .. | .. | 1 |
| ព្រះវិហារ | .. | .. | 1 | 1 | .. | 2 |
| ព្រៃវែង | 19 | 25 | 16 | 9 | .. | 69 |
| ពោធិសាត់ | 5 | 15 | 6 | 8 | .. | 34 |
| រតនគិរី | 11 | 17 | 9 | 6 | .. | 43 |

| | | | | | | |
|---|---|---|---|---|---|---|
| ស្ទឹងត្រែង | .. | 1 | 1 | .. | .. | 2 |
| ស្វាយរៀង | 41 | 117 | 66 | 33 | 3 | 260 |
| តាកែវ | 107 | 160 | 81 | 49 | 1 | 398 |
| សរុប | *1,207* | *2,713* | *2,621* | *1,965* | *246* | *8,752* |

តារាង៣.៨.ខ. បង្ហាញថា អ្នកនៅខេត្ត-ក្រុងមានទីប្រជុំជនធំ ជាពិសេសអ្នកភ្នំពេញ មិនមែនត្រឹមតែទិញដីច្រើនជាងអ្នកនៅខេត្ត-ក្រុងមានទីប្រជុំជនតូចប៉ុណ្ណោះទេ ប៉ុន្តែពួកគេទិញដីដែលមានទំហំធំៗច្រើនជាងនេះទៀតផង ។ អ្នកទិញមកពីខេត្តក្រុងធំៗ ទាំងប្រាំមួយ បានទិញដីលំនៅដ្ឋាន ២.១៦២ឡូតិ៍ ដែលមានទំហំ ៥០០ម៉ែត្រការ៉េ ឬតិចជាង ។ ចំនួននេះត្រូវជា ២៣% ច្រើនជាងចំនួនដីតូចៗដែលទិញដោយពលរដ្ឋនៅក្នុង ១៦ខេត្ត-ក្រុងផ្សេងទៀត ។ ម្យ៉ាងវិញទៀត ចំពោះដីមានទំហំធំជាង ៥០០ម៉ែត្រការ៉េ អ្នកនៅខេត្ត-ក្រុងមានទីប្រជុំជនធំ បានទិញ ៣.៩៧១ឡូតិ៍ ឬបួនដងច្រើនជាងចំនួនដីឡូតិ៍ទិញដោយអ្នកនៅ ១៦ខេត្តក្រុងផ្សេងទៀត ។ ក្នុងចំណោមដីធំជាង ៥០០ម៉ែត្រការ៉េ ចំនួន ៤.៨៣២ឡូតិ៍ដែលគេបានលក់ជាផ្លូវការពីឆ្នាំ១៩៩៥-២០០១ នៅទូទាំងប្រទេស (លើកលែងតែរាជធានីភ្នំពេញ) គឺមាន ២.៦៣៤ឡូតិ៍ (ឬ៤៥%) ត្រូវបានទិញដោយអ្នកភ្នំពេញ ។ ទិន្នន័យនេះ បានបង្ហាញថា ពលរដ្ឋនៅរាជធានីបានក្តោបក្តាប់នូវទ្រព្យធន និងកម្មសិទ្ធិដីធ្លី យ៉ាងច្រើនខ្លាំងណាស់ ។

## ៣.៣ និន្នាការនៃការទិញលក់ដីកសិកម្ម

### *៣.៣.១. កំរិតនៃការទិញលក់ដី*

ពីឆ្នាំ១៩៩៥-២០០១ បើសិនគិតតាមចំនួនប្រតិបត្តិការទិញ-លក់, ដីកសិកម្មត្រូវបានលក់ដូរ *ជាផ្លូវការ* តិចជាងដីលំនៅដ្ឋាន ។ ក្រោយបានដកឯកសារមួយចំនួនចេញ (តិចជាង ៥០) នៅពេលកែតំរូវទិន្នន័យ គឺមាន ៦.៨៨១ប្រតិបត្តិការលើដីកសិកម្ម និង ៨.៩១៥ប្រតិបត្តិការលើដីលំនៅដ្ឋានចំនួន ។ ប៉ុន្តែបើគិតជាផ្ទៃដីវិញ ដីកសិកម្មត្រូវបានលក់ច្រើនជាងដីលំនៅដ្ឋាន ។ ពីព្រោះមានដីកសិកម្ម ១៧.១៤៦ហិកតាត្រូវបានលក់ជាផ្លូវការ ឯដីលំនៅដ្ឋានមានតែ ១.៣៦២ហិកតាប៉ុណ្ណោះ ។ ក្នុងតួលេខនេះ ដីកសិកម្មរួមមានដីដាំដំណាំ និងដីគ្មានដាំអ្វីសោះប៉ុន្តែមានការកំណត់ថានឹងដាំក្នុងពេលអនាគត ។

ផ្ទៃដី ១៧.១៤៦ហិកតាដែលគេបានលក់ វាជាចំណែកតូចមួយនៃដីកសិកម្មសរុបនៅកម្ពុជា គឺប្រហែល 0,៤៣% ។ ក្នុងមួយឆ្នាំៗជាមធ្យមគេបានលក់ជាផ្លូវការ តែ 0.១%នៃផ្ទៃដីកសិកម្មសរុបប៉ុណ្ណោះ ។ ទំហំដីទិញ-លក់ជាក់ស្តែងនៅកម្ពុជា ពិតជាច្រើនជាងនេះឆ្ងាយណាស់ពីព្រោះកំរិតវិសមភាព និងភាពគ្មានដីកសិកម្ម គឺវាខ្ពស់យ៉ាងខ្លាំង[១៣] ។ ដូចបានពិពណ៌នារួចមកហើយ រាល់ការសន្និដ្ឋានត្រូវបានធ្វើឡើងដោយផ្អែកលើដីមួយចំនួនតូចដែលបានលក់ដូរជាផ្លូវការ និងបានចុះបញ្ជីនៅ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ។ ម្យ៉ាងវិញទៀត ការលក់ដីនៅភ្នំពេញ និងខេត្តកណ្តាល នៅក្រោយឆ្នាំ២000 ពុំមានបញ្ចូលនៅទីនេះទេ ដោយសារមូលហេតុដូចបានបញ្ជាក់រួចមកហើយ ។ ភាគច្រើនគឺពួកអ្នកមានប្រាក់ច្រើននៅក្នុងសង្គមដែលអាចស្វែងរកកម្មសិទ្ធិសំរាប់ដីរបស់ខ្លួនបាន ដូចមានលើករួចមកហើយ[១៤] ។ ដូច្នេះកំរងទិន្នន័យនេះក៏ដូចជាកំរងទិន្នន័យខាងលើដែរ គឺនិយាយតែអំពី "ដីរបស់អ្នកមាន" ។

### *៣.៣.២. ការទិញលក់ដីគិតតាមពេលវេលា និងភូមិសាស្ត្រ*

តារាង៣.៩.ក និង៣.៩.ខ បង្ហាញនូវនិន្នាការនៃការលក់ដីកសិកម្មពីឆ្នាំ១៩៩៥-២០០១ គិតតាមខេត្តនីមួយៗ ដោយបែងចែកជាពីរក្រុម (ខេត្ត-ក្រុងមានទីប្រជុំជនធំ និងខេត្ត-ក្រុងមានទីប្រជុំជនតូច) ដូចបានរៀបរាប់នៅខាងលើរួចមកហើយ ។ ការផ្ទេរកម្មសិទ្ធិដីកសិកម្ម ដូចគ្នានឹងដីលំនៅដ្ឋានដែលបានលើកនៅខាងលើដែរ គឺមានកំរិតខ្ពស់គួរឱ្យកត់សំគាល់នៅចន្លោះឆ្នាំ ១៩៩៥-៩៧ ដោយឡើងខ្ពស់បំផុតនៅឆ្នាំ១៩៩៦ ពីព្រោះមានដល់ទៅ ២.0១0ប្រតិបត្តិការលក់ដី ត្រូវជា ៥.0៦១ហិកតា ។

[១៣] ទោះបីគិតក្រោយពេលបែងចែកដីជាថ្មីដោយសារមានកំណើនប្រជាជនច្រើនក៏ដោយ ក៏រឿងនេះនៅតែពិតដូច្នេះដែរ ។

[១៤] So et al, 2001

ចាប់តាំងពីពេលនោះមក សកម្មភាពទិញ-លក់បានធ្លាក់ចុះវិញ ។ ដូចបានពិពណ៌នារួចមកហើយ មានទំនាក់ទំនងដ៏ជិតស្និទ្ធិរវាងទីផ្សារដីធ្លី និងសកម្មភាពសេដ្ឋកិច្ចជាទូទៅ ។

ការលក់ដីកសិកម្មភាគច្រើនបំផុត កើតមាននៅក្នុង ៥ខេត្ត ដែលត្រូវបានចាត់ទុកជាខេត្តមានទីប្រជុំជនធំ ។ ពីឆ្នាំ១៩៩៥ ដល់ ២០០១ មានការលក់ដីចំនួន ៤.៥០០កន្លែង ត្រូវជា ១០.៦៧៩ហិកតានៃដីកសិកម្មនៅក្នុង ៥ខេត្តនេះ ។ ក្នុង ១៣ខេត្តផ្សេងទៀតដែលមានទីប្រជុំជនតូច គឺមានការលក់ដីចំនួន ២.៣៦៥ប្រតិបត្តិការ ត្រូវជា ៦.៤៦៧ហិកតា ។ ដូច្នេះ ការលក់ដូរនៅក្នុងខេត្តមានទីប្រជុំជនធំ វាមានកើត ៤០%ខ្ពស់ជាង ខេត្តដែលមានទីប្រជុំជនតូច ។

**តារាង៣.៩.ក. ចំនួនដីកសិកម្ម ដែលគេបានលក់ គិតតាមខេត្ត ពីឆ្នាំ១៩៩៥ ដល់ ២០០១**

| ទីតាំងដីដែលបានលក់ | ចំនួនប្រតិបត្តិការលក់ដី | | | | | | | សរុប (១៩៩៥-២០០១) | |
|---|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001* | ចំនួន | % |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 1,055 | 1,330 | 1,154 | 434 | 334 | 119 | 90 | 4,516 | 66% |
| កណ្ដាល | 640 | 791 | 465 | 143 | 159 | 6 | .. | 2,204 | 32% |
| សៀមរាប | 9 | 41 | 19 | 8 | 19 | 29 | 10 | 135 | 2% |
| ក្រុងព្រះសីហនុ | 383 | 463 | 569 | 206 | 114 | 68 | 14 | 1,817 | 26% |
| បាត់ដំបង | 17 | 29 | 27 | 12 | 29 | .. | .. | 114 | 2% |
| កំពង់ចាម | 6 | 6 | 74 | 65 | 13 | 16 | 66 | 246 | 4% |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 101 | 680 | 488 | 325 | 443 | 208 | 120 | 2,365 | 34% |
| បន្ទាយមានជ័យ | .. | 3 | 5 | 22 | 17 | 20 | 40 | 277 | 2% |
| កំពង់ឆ្នាំង | 16 | 188 | 272 | 99 | 52 | 46 | 3 | 676 | 10% |
| កំពង់ស្ពឺ | 27 | 84 | 59 | 23 | 34 | 16 | 2 | 245 | 4% |
| កំពង់ធំ | .. | 4 | .. | 13 | 5 | 18 | 33 | 73 | 1% |
| កំពត | 19 | 66 | 18 | 27 | 49 | 19 | 12 | 210 | 3% |
| ក្រុងកែប | .. | 15 | 14 | 10 | 8 | 15 | 5 | 67 | 1% |
| កោះកុង | 34 | 307 | 97 | 77 | 225 | 61 | 4 | 805 | 12% |
| ក្រចេះ | .. | 2 | .. | 1 | .. | 1 | 1 | 5 | 0% |
| ព្រៃវែង | 4 | .. | 3 | 3 | .. | .. | .. | 10 | 0% |
| ពោធិសាត់ | .. | 3 | 1 | .. | 9 | 2 | 1 | 16 | 0% |
| រតនគិរី | .. | .. | 2 | 5 | 1 | 1 | .. | 9 | 0% |
| ស្វាយរៀង | 1 | .. | 3 | 4 | 9 | 2 | 7 | 26 | 0% |
| តាកែវ | .. | 9 | 14 | 41 | 34 | 7 | 12 | 117 | 2% |
| *សរុប* | *1,156* | *2,010* | *1,642* | *759* | *777* | *327* | *210* | *6,881* | *100%* |

តាមពិត ការទិញ-លក់ដីភាគច្រើនបំផុតនៅក្នុងខេត្ត-ក្រុងធំៗ វាកើតមាននៅតែពីរកន្លែងប៉ុណ្ណោះ គឺខេត្តកណ្ដាល និងក្រុងព្រះសីហនុ ដែលមានការលក់ដីកសិកម្មជាផ្លូវការចំនួន ២០០០ប្រតិបត្តិការ ឬប្រហែល ៥.០០០ហិកតា រៀងៗខ្លួន។ ដីកសិកម្មមួយចំនួននៅក្នុងខេត្តកណ្ដាលត្រូវបានគេធ្វើជាកន្លែងសង់រោងចក្រ ឬដីលំនៅដ្ឋាន ដោយសារការពង្រីកទីក្រុងបានរីកធំហួសពីបរិវេណក្រុងភ្នំពេញ ។ លើសពីនេះ ដីធំៗមួយចំនួនត្រូវបានគេទិញ និងធ្វើរបងព័ទ្ធទុក សំរាប់ការសាងសង់រោងចក្រ ឬការធ្វើពាណិជ្ជកម្មផ្សេងៗក្នុងពេលអនាគត ។ ករណីក្រុងព្រះសីហនុដែលជាក្រុងជាប់ឆ្នេរសមុទ្រ គឺមានលក្ខណៈខុសគ្នាបន្តិច ដោយសារសកម្មភាពពាណិជ្ជកម្មផ្លូវសមុទ្រ បានបង្កើតឱ្យមានតំរូវការដី ។ នៅក្រុងព្រះសីហនុ ដីកសិកម្មមួយភាគធំដែលគេបានលក់ គឺបានមកពីការកាប់ឆ្ការព្រៃ ។ ក្នុងពេលបច្ចុប្បន្ន ដីព្រៃដែលនៅសេសសល់ ត្រូវបានចាត់ចូលជា ឧទ្យានជាតិក្បាលឆាយ ដើម្បីទប់ស្កាត់កុំឱ្យមានសកម្មភាពចាប់យកដីទៀត[១៥] ។

ខេត្តបាត់ដំបងដែលល្បីឈ្មោះពីផលិតកម្មស្រូវមានគុណភាពខ្ពស់ គឺជាខេត្តមួយដែលមានការទិញ-លក់ដីស្រែយ៉ាងច្រើនក្នុងប៉ុន្មានឆ្នាំមកនេះ ផ្អែកតាមអង្កេតទ្រង់ទ្រាយតូចនានាដែលនឹងលើកមកពិភាក្សាក្នុងផ្នែកទី៥ ។ ប៉ុន្តែការលក់ដីនេះពុំមានឆ្លុះ

[១៥] មន្ត្រីស្រុកដែលផ្ដល់សំភាសន៍ថា សាលាក្រុងព្រះ.យល់ថា តំបន់ការពារនេះមានទំហំធំ នឹងស្នើរដ្ឋាភិបាលឱ្យពិចារណារឿងព្រំប្រទល់វិញ ។

បញ្ចាំងនៅក្នុងទិន្នន័យផ្លូវការនៅខាងក្រោមទេ។ ពីឆ្នាំ១៩៩៥-២០០១ មានការទិញលក់ជាផ្លូវការតែ ១១៤ប្រតិបត្តិការ ត្រូវជា ១២៨ហិកតាប៉ុណ្ណោះនៅបាត់ដំបង ដែលតំណាងឱ្យ ១,៦%នៃការលក់ដីកសិកម្មជាផ្លូវការទាំងអស់នៅក្នុងទូទាំងប្រទេស ។ ជាការពិតណាស់ ភាគច្រើននៃការទិញ-លក់ដីកសិកម្ម មានលក្ខណៈក្រៅផ្លូវការ ។ ចំងាយផ្លូវទៅភ្នំពេញ ការដឹកជញ្ជូនតំលៃខ្ពស់ និងសោហ៊ុយផ្សេងៗជាប់ទាក់ទិននឹងការចុះបញ្ជី និងការផ្ទេរស្របច្បាប់ គឺសុទ្ធតែរាំងមិនឱ្យកសិករដើរតាមនិតិវិធីផ្លូវការ ។ ចំពោះខេត្តបន្ទាយមានជ័យ និងខេត្តផ្សេងៗទៀតដែលនៅឆ្ងាយ ក៏មានស្ថានភាពប្រហាក់ប្រហែលគ្នាដែរ ។

**តារាង៣.៩.២. ផ្ទៃដីកសិកម្មដែលគេបានលក់ គិតតាមខេត្ត ពីឆ្នាំ១៩៩៥-២០០១**

| ទីតាំងដីដែលបានលក់ | ផ្ទៃដីដែលបានលក់ (ហិកតា) | | | | | | | សរុប (១៩៩៥-២០០១) | |
|---|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001* | ផ្ទៃដី (ហិកតា) | % |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 2,276 | 2,707 | 3,507 | 1,093 | 593 | 198 | 305 | 10,679 | 62% |
| កណ្តាល | 1,259 | 1,413 | 1,393 | 173 | 305 | 7 | .. | 4,551 | 27% |
| សៀមរាប | 5 | 17 | 18 | 4 | 17 | 56 | 31 | 148 | 1% |
| ក្រុងព្រះសីហនុ | 984 | 1,245 | 1,800 | 652 | 204 | 83 | 9 | 4,977 | 29% |
| បាត់ដំបង | 11 | 13 | 28 | 35 | 42 | .. | .. | 128 | 1% |
| កំពង់ចាម | 17 | 18 | 269 | 229 | 24 | 52 | 264 | 875 | 5% |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 169 | 2,354 | 881 | 863 | 1,388 | 432 | 380 | 6,467 | 38% |
| បន្ទាយមានជ័យ | .. | 3 | 17 | 62 | 27 | 29 | 167 | 305 | 2% |
| កំពង់ឆ្នាំង | 24 | 447 | 432 | 323 | 160 | 42 | 6 | 1,435 | 8% |
| កំពង់ស្ពឺ | 23 | 300 | 78 | 60 | 41 | 64 | .. | 565 | 3% |
| កំពង់ធំ | .. | 42 | .. | 47 | 16 | 44 | 159 | 308 | 2% |
| កំពត | 20 | 153 | 27 | 14 | 142 | 31 | 10 | 398 | 2% |
| ក្រុងកែប | .. | 5 | 10 | 9 | 10 | 14 | 4 | 52 | 0% |
| កោះកុង | 98 | 1,387 | 295 | 201 | 880 | 192 | 8 | 3,063 | 18% |
| ក្រចេះ | .. | 9 | .. | 5 | .. | 1 | 1 | 16 | 0% |
| ព្រៃវែង | 4 | .. | 5 | 4 | .. | .. | .. | 13 | 0% |
| ពោធិសាត់ | .. | 1 | .. | .. | 6 | 2 | 1 | 10 | 0% |
| រតនគិរី | .. | .. | 5 | 22 | 4 | 3 | .. | 34 | 0% |
| ស្វាយរៀង | .. | .. | 2 | 1 | 9 | 2 | 3 | 17 | 0% |
| តាកែវ | .. | 6 | 10 | 115 | 92 | 8 | 20 | 251 | 1% |
| **សរុប** | 2,446 | 5,061 | 4,388 | 1,956 | 1,980 | 630 | 685 | 17,146 | 100% |

** ទិន្នន័យឆ្នាំ២០០១ មានប្រហែលតែពាក់កណ្តាលឆ្នាំ ។*

## ៣.៣.៣. ការបែងចែកតាមទីក្រុង និងជនបទ

មនុស្សជាច្រើនរំពឹងថា ការទិញលក់ដីកសិកម្មភាគច្រើនលើសលុប កើតមាននៅជនបទ មិនមែននៅទីក្រុងទេ ពីព្រោះសកម្មភាពកសិកម្មអនុវត្តនៅជនបទ ។ ប៉ុន្តែក្នុងទិន្នន័យវិភាគនៅទីនេះ គេពុំឃើញមានលក្ខណៈដូច្នេះឡើយ ។ ប្រហែល ៤២% (ឬ ២.៨៥៨ប្រតិបត្តិការ) នៃការលក់ចំនួន ៦.៨៨១លើក កើតមាននៅតំបន់ទីក្រុង ។ តួលេខនេះអាចមានបញ្ហាចោទ មកពីវិធីកំណត់តំបន់ទីក្រុង និងជនបទ ដែលបានបញ្ជាក់ពីខាងដើមរួចហើយ ។ ឧទាហរណ៍ ក្រុងព្រះសីហនុទាំងមូល ត្រូវបានចាត់ទុកជាតំបន់ទីក្រុង ទោះមួយភាគធំជាតំបន់ព្រៃក៏ដោយ ។ ការលក់ដីកសិកម្ម ១.៨១៧ប្រតិបត្តិការ ដែលមានផ្ទៃជិត ៥.០០០ហិកតា នៅក្នុងក្រុងនេះ តំណាងឱ្យ ៦៤% នៃប្រតិបត្តិការលក់ដីកសិកម្មសរុប និង ៨០% នៃផ្ទៃដីកសិកម្មទិញ-លក់សរុបដែលស្ថិតនៅតំបន់ទីក្រុង ។ ក្រុងកែបក៏មានលក្ខណៈដូចគ្នាដែរ ។ តាមគោលការណ៍បច្ចេកទេសដែលផ្អែកលើស្ថានភាពរូបវន្ត និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែង កែបជាតំបន់ជនបទមួយ ប៉ុន្តែត្រូវបានចាត់ទុកជាតំបន់ ទីក្រុងដោយសារហេតុផលខាងរដ្ឋបាល និងស្ថិតិ ។

ខេត្ត-ក្រុងមានទីប្រជុំជនតូច បានបង្ហាញនូវរូបភាពខុសគ្នានៃការលក់ដីកសិកម្មនៅទីក្រុង និងជនបទ ។ ខេត្តទាំង ១៣ នេះ ការផ្ទេរកម្មសិទ្ធិចំនួន ១៦% ស្ថិតក្នុងតំបន់ទីក្រុង ហើយការលក់ដីច្រើនកើតមាននៅខេត្តកោះកុង ព្រោះដីចំនួន ៨០៥កន្លែង មានផ្ទៃសរុប ៣.០៦៣ហិកតា (ឬប្រហែល ៥០% នៃផ្ទៃដីសរុបដែលគេលក់នៅក្នុងខេត្តតូចៗទាំង១៣) គឺស្ថិតក្នុងខេត្តតែមួយ

នេះ ។ ខេត្តកោះកុងភាគច្រើនគឺជាទីជនបទ មានដីសល់ច្រើន ហើយកន្លងមកបានលក់ដីក្នុងតំលៃថោក ។ ដីនៅខេត្តនេះទើបនឹងបើកចំហដែលផ្តល់ឱកាសឱ្យមនុស្សមួយចំនួនទិញដីទុក ដោយរំពឹងថានឹងមានការអភិវឌ្ឍន៍ យ៉ាងឿនៅពេលអនាគត ។

**តារាង៣.១០.ក. ចំនួនប្រតិបត្តិការលក់ដីកសិកម្ម គិតតាមតំបន់ជនបទ និងតំបន់ទីក្រុង (ចំនួន)**

| ទីតាំងដីដែលបានលក់ | ចំនួនប្រតិបត្តិការលក់ (១៩៩៥ - ២០០១) | | | | ចំនួនប្រតិបត្តិការសរុប |
|---|---|---|---|---|---|
| | ទីក្រុង | | ជនបទ | | |
| | ចំនួនប្រតិបត្តិការ | សរុបជា % | ចំនួនប្រតិបត្តិការ | សរុបជា % | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 2,476 | 55% | 2,040 | 45% | 4,516 |
| កណ្តាល | 500 | 23% | 1,704 | 77% | 2,204 |
| សៀមរាប | 78 | 58% | 57 | 42% | 135 |
| ក្រុងព្រះសីហនុ | 1,817 | 100% | .. | .. | 1,817 |
| បាត់ដំបង | 80 | 70% | 34 | 30% | 114 |
| កំពង់ចាម | 1 | 0% | 245 | 100% | 246 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 382 | 16% | 1,983 | 84% | 2,365 |
| បន្ទាយមានជ័យ | 13 | 12% | 93 | 88% | 106 |
| កំពង់ឆ្នាំង | 12 | 2% | 664 | 98% | 676 |
| កំពង់ស្ពឺ | 43 | 18% | 202 | 82% | 245 |
| កំពង់ធំ | .. | .. | 73 | 100% | 73 |
| កំពត | 24 | 11% | 186 | 89% | 210 |
| ក្រុងកែប | 67 | 100% | .. | .. | 67 |
| កោះកុង | 170 | 21% | 635 | 79% | 805 |
| ក្រចេះ | 1 | 20% | 4 | 80% | 5 |
| ព្រៃវែង | 9 | 90% | 1 | 10% | 10 |
| ពោធិសាត់ | 11 | 69% | 5 | 31% | 16 |
| រតនគិរី | 4 | 44% | 5 | 56% | 9 |
| ស្វាយរៀង | 12 | 46% | 14 | 54% | 26 |
| តាកែវ | 16 | 14% | 101 | 86% | 117 |
| *សរុប* | 2,858 | 42% | 4,023 | 58% | 6,881 |

**តារាង៣.១០.ខ. ទំហំផ្ទៃដីកសិកម្ម ដែលគេបានលក់ គិតតាមតំបន់ជនបទ និងតំបន់ទីក្រុង (ទំហំផ្ទៃដី)**

| ទីតាំងដីដែលបានលក់ | ផ្ទៃដីដែលបានលក់ គិតជា ហិកតា (១៩៩៥ - ២០០១) | | | | ផ្ទៃដីសរុប |
|---|---|---|---|---|---|
| | ទីក្រុង | | ជនបទ | | |
| | ផ្ទៃដី | សរុបជា % | ផ្ទៃដី | សរុបជា % | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | 5,385 | 50% | 5,293 | 50% | 10,679 |
| កណ្តាល | 246 | 5% | 4,305 | 95% | 4,551 |
| សៀមរាប | 89 | 60% | 59 | 40% | 148 |
| ក្រុងព្រះសីហនុ | 4,977 | 100% | .. | .. | 4,977 |
| បាត់ដំបង | 69 | 54% | 58 | 46% | 128 |
| កំពង់ចាម | 4 | 0% | 871 | 100% | 875 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | 842 | 13% | 5,625 | 87% | 6,467 |
| បន្ទាយមានជ័យ | 28 | 9% | 277 | 91% | 305 |
| កំពង់ឆ្នាំង | 11 | 1% | 1,424 | 99% | 1,435 |
| កំពង់ស្ពឺ | 10 | 2% | 555 | 98% | 565 |
| កំពង់ធំ | .. | .. | 308 | 100% | 308 |
| កំពត | 32 | 8% | 366 | 92% | 398 |
| ក្រុងកែប | 52 | 100% | .. | .. | 52 |
| កោះកុង | 663 | 22% | 2,400 | 78% | 3,063 |
| ក្រចេះ | 1 | 6% | 15 | 94% | 16 |
| ព្រៃវែង | 12 | 92% | 1 | 8% | 13 |
| ពោធិសាត់ | 8 | 81% | 2 | 19% | 10 |
| រតនគិរី | 12 | 35% | 22 | 65% | 34 |
| ស្វាយរៀង | 4 | 23% | 13 | 77% | 17 |
| តាកែវ | 9 | 3% | 242 | 97% | 251 |

| | | | | | |
|---|---|---|---|---|---|
| *សរុប* | 6,228 | 36% | 10,918 | 64% | 17,146 |

*សំគាល់ : ទិន្នន័យការលក់ដីនៅភ្នំពេញ មិនត្រូវបានបញ្ចូលនៅទីនេះទេ*

## *៣.៣.៤. អាសយដ្ឋានរបស់អ្នកទិញ និងអ្នកលក់*

ពីឆ្នាំ១៩៩៥-២០០១ អ្នកលក់ដីកសិកម្មមួយចំនួនធំ មានអាសយដ្ឋាននៅក្នុងខេត្ត-ក្រុងមានទីប្រជុំជនធំ ។ និន្នាការខាង ដីកសិកម្ម វាស្រដៀងគ្នានឹងការលក់ដូរដីលំនៅដ្ឋានដែរ ។ ក្នុងចំណោម ៦.៦៣៧ប្រតិបត្តិការលក់ដីកសិកម្មនៅក្រៅក្រុងភ្នំពេញ ជិតដល់ ៨០%ត្រូវបានទិញដោយអ្នកភ្នំពេញ (តារាង៣.១១) ។ ក្នុងចំនោម ៨០៥ប្រតិបត្តិការលក់ដីនៅកោះកុង ៤១៨ប្រតិបត្តិ ការជាប់ទាក់ទិននឹងអ្នកទិញជាអ្នកភ្នំពេញ (តារាង៣.១២) ។

បើយោងតាមទិន្នន័យទាំងនេះ អ្នកភ្នំពេញបានទិញប្រហែល ៨៥%នៃផ្ទៃដីកសិកម្មសរុបដែលត្រូវបានលក់ជាផ្លូវការ ។ នេះជាការបញ្ជាក់បន្ថែមនូវចំណុចដែលថា មានការប្រមូលផ្តុំទ្រព្យសម្បត្តិនៅក្នុងដៃអ្នកនៅទីក្រុង ជាពិសេសអ្នកនៅភ្នំពេញ ។ ទោះបីផ្ទៃដីទាំងអស់ដែលបានផ្ទេរកម្មសិទ្ធិវាមានតួលេខតូចក៏ដោយ ក៏ការផ្ទេរទាំងនេះបានបង្កការបារម្ភពី ភាពទន់ខ្សោយរបស់អ្នកក្រីក្រនៅជនបទ ចំពោះលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ដែលដីទាំងនេះតាំងនៅ ។ គំលាតកាន់តែធំរវាងអ្នកមាន នឹងអ្នកក្រ ក៏ជាចំណុចព្រួយបារម្ភយ៉ាងធំមួយដែរ ។

**តារាង៣.១១. តើអ្នកទិញដីកសិកម្មមកពីណា?**

| ទីតាំងអ្នកទិញ | ចំនួនប្រតិបត្តិការលក់ដី | | | | ផ្ទៃដី គិតជាហិកតា | | | |
|---|---|---|---|---|---|---|---|---|
| | ទីក្រុង | ជនបទ | សរុប | សរុបជា% | ទីក្រុង | ជនបទ | សរុប | សរុបជា% |
| ខេត្តក្រុង មានទីប្រជុំជនធំ | 2,475 | 3,525 | 6,000 | 90.4% | 5,142 | 9,803 | 14,945 | 92.0% |
| ភ្នំពេញ | 1,979 | 3,260 | 5,239 | 78.9% | 4,354 | 9,403 | 13,757 | 84.6% |
| កណ្តាល | 132 | 74 | 206 | 3.1% | 89 | 63 | 152 | 0.9% |
| សៀមរាប | 28 | 14 | 42 | 0.6% | 31 | 9 | 39 | 0.2% |
| ក្រុងព្រះសីហនុ | 249 | 7 | 256 | 3.9% | 615 | 25 | 639 | 3.9% |
| បាត់ដំបង | 65 | 59 | 124 | 1.9% | 43 | 100 | 143 | 0.9% |
| កំពង់ចាម | 22 | 111 | 133 | 2.0% | 11 | 204 | 215 | 1.3% |
| ខេត្តក្រុង មានទីប្រជុំជនតូច | 294 | 345 | 637 | 9.6% | 792 | 515 | 1,307 | 8.0% |
| បន្ទាយមានជ័យ | 11 | 20 | 31 | 0.5% | 23 | 31 | 54 | 0.3% |
| កំពង់ឆ្នាំង | 10 | 30 | 40 | 0.6% | 22 | 18 | 40 | 0.2% |
| កំពង់ស្ពឺ | 20 | 24 | 44 | 0.7% | 1 | 19 | 21 | 0.1% |
| កំពង់ធំ | 1 | 29 | 30 | 0.5% | 0 | 89 | 89 | 0.5% |
| កំពត | 20 | 40 | 60 | 0.9% | 31 | 45 | 76 | 0.5% |
| ក្រុងកែប | 1 | .. | .. | 0.0% | 0 | .. | 0 | 0.0% |
| កោះកុង | 178 | 163 | 341 | 5.1% | 670 | 230 | 900 | 5.5% |
| ក្រចេះ | 1 | .. | 1 | 0.0% | 1 | .. | 1 | 0.0% |
| មណ្ឌលគីរី | 1 | .. | 1 | 0.0% | 1 | .. | 1 | 0.0% |
| ឧត្តរមានជ័យ | 1 | .. | .. | 0.0% | 0 | .. | 0 | 0.0% |
| ព្រៃវែង | 11 | .. | 11 | 0.2% | 13 | .. | 13 | 0.1% |
| ពោធិសាត់ | 8 | 6 | 14 | 0.2% | 6 | 2 | 9 | 0.1% |
| រតនគីរី | 3 | 1 | 4 | 0.1% | 9 | 5 | 14 | 0.1% |
| ស្វាយរៀង | 12 | 5 | 17 | 0.3% | 4 | 2 | 6 | 0.0% |
| តាកែវ | 16 | 27 | 43 | 0.6% | 11 | 74 | 84 | 0.5% |
| សរុប | 2,769 | 3,870 | 6,637 | 100.0% | 5,934 | 10,318 | 16,253 | 100.0% |

** ទិន្នន័យនៃការលក់ដីនៅភ្នំពេញ មិនត្រូវបានបញ្ចូលនៅទីនេះទេ ។*

តារាង៣.១២ ផ្តល់នូវទិន្នន័យអំពីដីកសិកម្មក្នុងខេត្តនីមួយៗដែលបានធ្លាក់ទៅក្នុងកម្មសិទ្ធិរបស់អ្នកភ្នំពេញ តាមលំដាប់នៃចំនួនដីសរុប ។ ពលរដ្ឋក្នុងខេត្តកណ្តាលបានលក់ដីកសិកម្មច្រើនជាងគេទៅអោយអ្នកភ្នំពេញ ។ ពីឆ្នាំ១៩៩៥-២០០០ មានតែ ១៤% (២៦៧ ក្នុងចំនោម ១.៩៣៧ប្រតិបត្តិការ) នៃប្រតិបត្តិការលក់ដីសរុបប៉ុណ្ណោះ ដែលបានផ្ទេរដីទៅឱ្យប្រជាជនផ្សេងក្រៅ

អ្នកភ្នំពេញ ។ បន្ទាប់ពីខេត្តកណ្តាល គឺក្រុងព្រះសីហនុដែលមានអ្នកភ្នំពេញទិញដីកសិកម្ម ១.៤១៨កន្លែង ។ ដីលក់ចេញ ២៨% ទៀត ត្រូវបានទិញដោយអ្នកផ្សេង ។

អ្នកភ្នំពេញប្រហែលបានចាប់ផ្តើមទិញដីក្នុងខេត្តផ្សេងៗតាំងពីឆ្នាំ១៩៩៥ ឬមុននេះទៀត ។ ជាលទ្ធផល គឺមានលំនាំនៃការផ្ទេរដីបែបនេះកើតឡើង ។ គេអាចធ្វើសម្មតិកម្មម៉្យាងទៀតថា អ្នកមានទ្រព្យសម្បត្តិនៅក្នុងទូទាំងប្រទេស បានមករស់នៅក្នុងរាជធានី ហើយបន្ទាប់មកក៏បានទិញដីនៅផ្សេងៗដែលពួកគេចូលចិត្ត ។ គេអាចនិយាយបានជាទូទៅថា ប្រជាជនបានវិនិយោគទុនលើដីធ្លី ដោយសារច្រកវិនិយោគផ្សេងទៀតនៅមានតិចតួចពេកក្នុងប្រទេសកម្ពុជា ។

ក្រោយឡើងខ្ពស់បំផុតក្នុងឆ្នាំ១៩៩៦ ការលក់ដីទៅឱ្យអ្នកភ្នំពេញបានធ្លាក់ចុះវិញយ៉ាងខ្លាំង ។ ការទិញដីកសិកម្មដោយអ្នកភ្នំពេញ មានតែ ១៩៨ប្រតិបត្តិការប៉ុណ្ណោះ នៅឆ្នាំ២000 ដែលជាការធ្លាក់ចុះយ៉ាងខ្លាំង បើធៀបនឹងចំនួន ១.៧៥៧ប្រតិ-បត្តិការនៅឆ្នាំ១៩៩៦ ។ ការធ្លាក់ចុះនេះ អាចបណ្តាលមកពីការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ច ការឡើងថ្លៃដី និងការធ្លាក់ចុះនៃប្រាក់ចំណេញដែលគេរំពឹងទុកក្នុងការជួញដីធ្លី ឬការប្រើប្រាស់ដីក្នុងគោលដៅផ្សេងទៀត ។

**តារាង៣.១២. ប្រតិបត្តិការលក់ដីកសិកម្មទៅឱ្យអ្នកភ្នំពេញ**

| ទីតាំងដីដែលបានលក់ | ចំនួនប្រតិបត្តិការទិញដោយអ្នកភ្នំពេញ | | | | | | | | ការទិញដោយអ្នកផ្សេង |
|---|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | (95-00) | (95-00) |
| កណ្តាល | 506 | 755 | 437 | 118 | 117 | 4 | .. | 1,937 | 267 |
| ក្រុងព្រះសីហនុ | 343 | 423 | 318 | 183 | 94 | 47 | 10 | 1,418 | 399 |
| កំពង់ឆ្នាំង | 4 | 134 | 263 | 96 | 46 | 40 | 3 | 586 | 90 |
| កោះកុង | 18 | 271 | 26 | 27 | 42 | 33 | 1 | 418 | 387 |
| កំពង់ចាម | 5 | 3 | 67 | 56 | 5 | 3 | 66 | 205 | 41 |
| កំពង់ស្ពឺ | 22 | 77 | 41 | 21 | 28 | 15 | .. | 204 | 41 |
| កំពត | 12 | 32 | 15 | 8 | 16 | 9 | 8 | 100 | 110 |
| សៀមរាប | 3 | 35 | 8 | 6 | 14 | 16 | 8 | 90 | 45 |
| តាកែវ | .. | 7 | 9 | 30 | 14 | 1 | 12 | 73 | 44 |
| ក្រុងកែប | .. | 13 | 14 | 10 | 7 | 14 | 4 | 62 | 5 |
| បន្ទាយមានជ័យ | .. | .. | .. | 8 | 2 | 8 | 35 | 53 | 53 |
| កំពង់ធំ | .. | 4 | .. | 7 | 5 | 6 | 19 | 41 | 32 |
| បាត់ដំបង | .. | .. | .. | 1 | 28 | .. | .. | 29 | 85 |
| ស្វាយរៀង | .. | .. | 3 | .. | 5 | 1 | .. | 9 | 17 |
| រតនគិរី | .. | .. | 1 | 4 | 1 | .. | .. | 6 | 3 |
| ក្រចេះ | .. | 2 | .. | 1 | .. | .. | 1 | 4 | 1 |
| ពោធិសាត់ | .. | 1 | .. | .. | .. | 1 | 1 | 3 | 13 |
| ព្រៃវែង | .. | .. | .. | 1 | .. | .. | .. | 1 | 9 |
| *សរុប* | *913* | *1,757* | *1,202* | *577* | *424* | *198* | *168* | *5,239* | *1,642* |

តារាង៣.១៣ បង្ហាញថា តើអ្នកទិញរស់នៅក្នុង ស្រុកដែលដីលក់តាំងនៅឬយ៉ាងណា ។ ក្នុងចំណោមដី ៦.៦២៨ប្លង់ដែលបានលក់ ៨៦%ត្រូវបានទិញដោយ អ្នករស់នៅក្នុងស្រុកផ្សេង ។ ក្នុងឆ្នាំ១៩៩៦ តួលេខនេះឡើងដល់ ៩៤% ប៉ុន្តែវាធ្លាក់ទាបបំផុតវិញដល់ ៧២%ក្នុងឆ្នាំ២000 ។

ភាគរយនៃអ្នកទិញមកពីក្រៅ (មកពីស្រុកផ្សេង) មានកំរិតខ្ពស់ជាងសំរាប់ដីកសិកម្ម បើធៀបនឹងដីលំនៅដ្ឋាន ដូចបានពិភាក្សាខាងលើ ហើយក្នុងចំណោមអ្នកទិញមកពីក្រៅ មាន ៨0%មកពីភ្នំពេញ និង ៦%មកពីស្រុកផ្សេងៗនៃខេត្តដដែលទៀត ។

គេអាចពិនិត្យឃើញថា តើមានដីប៉ុន្មានដែលអ្នកនៅក្រៅស្រុកបានទិញរួចហើយ និងបានលក់បន្តទៀត តាមរយៈការគណនាលើទិន្នន័យអំពីទីតាំងដី និងអាសយដ្ឋានរបស់អ្នកលក់ និងអ្នកទិញ ។ ប្រហែលពាក់កណ្តាលនៃអ្នកទិញនៅក្នុងគំរូតាងមកពីស្រុកផ្សេងពីស្រុកដែលដីតាំងនៅ (តារាង៣.១៤) ។ នៅពេលដីត្រូវបានបែងចែកជាថ្មីក្នុងឆ្នាំ១៩៨៩ វាមិនអាចជាការពិត

ទេដែលថា ពលរដ្ឋមួយចំនួនធំត្រូវបានផ្តល់ឱ្យនូវ ដីធ្លីនៅក្នុងស្រុកផ្សេងពីស្រុកដែលពួកគេរស់នៅ ។ រឿងដែល ប្រហែល៩០% នៃដីកសិកម្មដែលបានលក់ជាផ្លូវការពីឆ្នាំ១៩៩៥-២០០១ គឺមានអ្នកលក់ជាអ្នកខាងក្រៅស្រុក វាបញ្ជាក់ឱ្យឃើញថា មានការទិញដីហើយលក់បន្តទៀតយ៉ាងច្រើនដោយអ្នកក្រៅស្រុក នៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។ មូលហេតុមួយទៀតអាចមានប្រជាជនចាកចេញពីស្រុកដើមរបស់ពួកគេ ហើយក៏លក់ដីកសិកម្មរបស់ខ្លួននៅក្នុងស្រុកនោះ ប៉ុន្តែករណីបែបនេះមានតិចទេ បើធៀបនឹងការទិញ និងលក់បន្ត នូវដីធ្លីដើម្បីយកចំណេញ (ជួញដី) ។

**តារាង៣.១៣. អាសយដ្ឋានរបស់អ្នកទិញដីកសិកម្ម ធៀបនឹងទីតាំងដី**

| ឆ្នាំលក់ដីធ្លី | អាសយដ្ឋានរបស់អ្នកទិញ | | | | សរុប | |
|---|---|---|---|---|---|---|
| | នៅក្នុងស្រុកដែលដីតាំងនៅ | | នៅស្រុកផ្សេងពីស្រុកដែលដីតាំងនៅ | | | |
| | ចំនួន | % | ចំនួន % | % | ចំនួន | ភាគរយ |
| 1995 | 136 | 12% | 992 | 88% | 1,128 | 100% |
| 1996 | 114 | 6% | 1,859 | 94% | 1,973 | 100% |
| 1997 | 207 | 14% | 1,315 | 86% | 1,522 | 100% |
| 1998 | 89 | 12% | 646 | 88% | 735 | 100% |
| 1999 | 275 | 37% | 469 | 63% | 744 | 100% |
| 2000 | 89 | 28% | 227 | 72% | 316 | 100% |
| 2001 | 21 | 10% | 189 | 90% | 210 | 100% |
| *សរុប* | *931* | *14%* | *5,697* | *86%* | *6,628* | *100%* |

**តារាង៣.១៤. អាសយដ្ឋានរបស់អ្នកលក់ដីកសិកម្ម ធៀបនឹងទីតាំងដី**

| ឆ្នាំលក់ដី | អាសយដ្ឋានរបស់អ្នកលក់ | | | | សរុប | |
|---|---|---|---|---|---|---|
| | នៅក្នុងស្រុកដែលដីតាំងនៅ | | នៅស្រុកផ្សេងពីស្រុកដែលដីតាំងនៅ | | | |
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| 1995 | 634.0 | 56% | 502 | 44% | 1,136 | 100% |
| 1996 | 1,047.0 | 52% | 956 | 48% | 2,003 | 100% |
| 1997 | 885.0 | 54% | 752 | 46% | 1,637 | 100% |
| 1998 | 371.0 | 50% | 377 | 50% | 748 | 100% |
| 1999 | 302.0 | 40% | 459 | 60% | 761 | 100% |
| 2000 | 139.0 | 43% | 183 | 57% | 322 | 100% |
| 2001 | 148.0 | 71% | 60 | 29% | 208 | 100% |
| សរុប | 3,526.0 | 52% | 3,289 | 48% | 6,815 | 100% |

## ៣.៤. ការលក់ដីធ្លីគិតតាមទំហំដី

តារាង៣.១៥ បង្ហាញពី ប្រតិបត្តិការលក់ដីកសិកម្ម គិតតាមទំហំផ្សេងៗគ្នា ។ ពីឆ្នាំ១៩៩៥-២០០១ ៤០%នៃដីលក់ចេញ មានទំហំ ១ហិកតា ឬតិចជាង ហើយមានចំនួនសរុប ៨៧៤ហិកតា ឬ ៥%នៃផ្ទៃដីសរុបដែលគេបានលក់ទាំងអស់ ។ វាចំលែកបន្តិចដែរ ដែល ៦៨៣ប្រតិបត្តិការលក់ (ឬ ១០%) ទាក់ទិននឹងឡូង់ដីទំហំ ០.១ហិកតា ឬតិចជាង (ក្នុងទិន្នន័យនេះ គឺសុទ្ធតែដីមានប័ណ្ណឡូង់ដី និងបានចុះបញ្ជីនៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ។ ដីទាំងនេះត្រូវបានប្រើប្រាស់ភាគច្រើនសំរាប់ធ្វើលំនៅដ្ឋាន ឬរបរអាជីវកម្ម និងតាំងនៅតាមដងផ្លូវធំៗ ។ ការធ្វើចំណាត់ថ្នាក់ដីតូចៗទាំងនេះជាដីកសិកម្ម ប្រហែលដោយសារជាប់រឿងអ្វីផ្សេង ឬរឿងប្រវត្តិសាស្ត្រប៉ុណ្ណោះ ។ ជាក់ស្តែង ដីចំនួន ៥៤៣ឡូង់ ក្នុងចំណោមដី ៦៨៣ឡូង់តូចៗទាំងនេះ ស្ថិតនៅក្នុងខេត្តកណ្តាល និងក្រុងព្រះសីហនុ ដែលមានការរីកទីក្រុងយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ។

តារាងនេះក៏បង្ហាញដែរថា មានដីច្រើនគួរសមដែលធំជាង ៣ហិកតា ។ ដីទាំងនេះ តំណាងឱ្យ ៤៦%នៃប្រតិបត្តិការលក់សរុប និងត្រូវជា ៨៣%នៃផ្ទៃដីសរុប ១៧.១៤៦ហិកតាដែលគេបានលក់ជាផ្លូវការ ។ ដីធំៗទាំងនេះ ភាគច្រើនស្ថិតនៅ ក្រុងព្រះសីហនុ ខេត្តកណ្តាល កោះកុង កំពង់ឆ្នាំង និងកំពង់ចាម (តារាង៣.១៦) ។

ច្បាប់ដីបច្ចុប្បន្នចែងថា គ្មានបុគ្គលណាអាចកាន់កាប់ដីកសិកម្មលើសពី ៥ហិកតាបានឡើយ[១៦] ។ កំរងទិន្នន័យរបស់យើងនេះបង្ហាញថា មានប្រតិបត្តិការលក់ដីជាច្រើនដែលទាក់ទិននឹងប្លង់ដីធំជាង ៥ហិកតា ។ ទិន្នន័យបង្ហាញទៀតថា មានប្រតិបត្តិការជាច្រើនករណីដែលបានធ្វើឡើងក្នុងកាលបរិច្ឆេទតែមួយ ហើយអ្នកទិញដីដែលមានច្រើននាក់គឺសុទ្ធតែមានអាសយដ្ឋានដូចគ្នាទាំងអស់ ។ ក្នុងករណីមួយចំនួន អ្នកលក់ជាច្រើននាក់ក៏មានអាសយដ្ឋានដូចគ្នាដែរ ។ រឿងនេះមានន័យថា មនុស្សតែម្នាក់បានទិញឬលក់ដីជាច្រើនកន្លែង ។ ការសង្កេតឃើញដូច្នេះ បញ្ជាក់បន្ថែមលើការអធិប្បាយរបស់មន្ត្រីសុរិយោដី និងមន្ត្រីមន្ទីរកសិកម្មដែល ថា ដើម្បីទិញដីបានលើសពី៥ហិកតា អ្នកទិញត្រូវចុះបញ្ជីដីធ្លីក្នុងប្លង់ផ្សេងៗគ្នា ដោយប្លង់នីមួយៗមិនឱ្យលើសពី ៥ហិកតាទេ ។ ជួនកាលអ្នកលក់ ឬ អ្នកទិញ ប្រើឈ្មោះខុសៗគ្នា ដូចជាឈ្មោះរបស់បងប្អូនបង្កើត ឬឈ្មោះកូន ដើម្បីចៀសវាងកុំឱ្យឃើញខុស ច្បាប់ខ្លាំងពេក ។ តាមមធ្យោបាយនេះ បុគ្គលម្នាក់អាចមានកម្មសិទ្ធិលើក្បាលដីធំជាង ៥ហិកតា ។ អ្នកទិញមួយចំនួន មិនបារម្ភ ពីការរឹតត្បិតក្នុងច្បាប់នេះទេ ។ ឧទាហរណ៍ ក្នុងទិន្នន័យនេះ មានដីយ៉ាងតិច ៤៩ប្លង់ដែលធំជាង ៥ហិកតាក្នុងមួយប្លង់ៗ ។

## តារាង៣.១៥. ទំហំដីកសិកម្មដែលលក់ពីឆ្នាំ១៩៩៥ ដល់ ២០០១

| | ចំនួនប្រតិបត្តិការលក់ដី | | | | ផ្ទៃដីលក់ គិតជាហិកតា | | | |
|---|---|---|---|---|---|---|---|---|
| ទំហំដីលក់ គិតជាហិកតា | ទីក្រុង | ជនបទ | សរុប | សរុបជា% | ទីក្រុង | ជនបទ | សរុប | សរុបជា% |
| >0.0 - 0.1 ha | 463 | 220 | 683 | 10% | 25 | 13 | 38 | 0% |
| >0.1 - 0.5 ha | 656 | 780 | 1,436 | 21% | 167 | 215 | 382 | 2% |
| >0.5 - 1.0 ha | 273 | 332 | 605 | 9% | 210 | 244 | 454 | 3% |
| >1.0 - 3.0 ha | 352 | 635 | 987 | 14% | 666 | 1,228 | 1,895 | 11% |
| >3.0 - 5.0 ha | 1,103 | 2,018 | 3,121 | 45% | 5,000 | 8,950 | 13,949 | 81% |
| >5.0 – 32 ha | 11 | 38 | 49 | 1% | 160 | 268 | 428 | 2% |
| សរុប | *2,858* | *4,023* | *6,881* | *100%* | *6,228* | *10,918* | *17,146* | *100%* |

## តារាង៣.១៦. ប្រតិបត្តិការលក់ដីកសិកម្ម បែងចែកតាមទំហំដី

| ទីតាំងដីលក់ | ទំហំដីកសិកម្មដែលបានលក់ (ហិកតា) | | | | | |
|---|---|---|---|---|---|---|
| | >0-0.1 | >0.1-0.5 | >0.5-1.0 | >1.0-3.0 | >3.0-5.0 | >5.0 |
| | ចំនួនប្រតិបត្តិការលក់ដី | | | | | |
| ខេត្តក្រុង មានទីប្រជុំជនធំ | 569 | 929 | 398 | 640 | 1,959 | 21 |
| កណ្ដាល | 188 | 626 | 222 | 324 | 831 | 13 |
| សៀមរាប | 9 | 55 | 30 | 21 | 20 | .. |
| ក្រុងព្រះសីហនុ | 353 | 202 | 106 | 220 | 929 | 7 |
| បាត់ដំបង | 11 | 38 | 33 | 28 | 3 | 1 |
| កំពង់ចាម | 8 | 8 | 7 | 47 | 176 | .. |
| ខេត្តក្រុង មានទីប្រជុំជនតូច | 114 | 507 | 207 | 347 | 1,162 | 28 |
| បន្ទាយមានជ័យ | 1 | 17 | 17 | 15 | 54 | 2 |
| កំពង់ឆ្នាំង | 26 | 195 | 75 | 129 | 250 | 1 |
| កំពង់ស្ពឺ | 51 | 46 | 17 | 29 | 93 | 9 |
| កំពង់ធំ | .. | 4 | 4 | 9 | 53 | 3 |
| កំពត | 14 | 64 | 32 | 36 | 58 | 6 |
| ក្រុងកែប | 4 | 33 | 17 | 10 | 3 | .. |
| កោះកុង | 8 | 95 | 18 | 75 | 603 | 6 |
| ក្រចេះ | .. | .. | 1 | 1 | 3 | .. |
| ព្រៃវែង | .. | .. | 2 | 8 | .. | .. |
| ពោធិសាត់ | .. | 10 | 3 | 3 | .. | .. |
| រតនគិរី | .. | 1 | .. | 1 | 7 | .. |

[១៦] មានការបកស្រាយច្បាប់នេះខុសៗគ្នា។ មតិមួយនិយាយថា ប្រជាជនមិនអាចកាន់កាប់ដីលើសពី៥ហិកតា ចំពោះដីបានមកពីរដ្ឋ ឬតាមរយៈ ការកាប់ឆ្ការព្រៃ ប៉ុន្តែបើសិនគេទិញដីវិញ គឺគ្មានការកំណត់ទេ (So et al 2001) ។

| | | | | | | |
|---|---|---|---|---|---|---|
| ស្វាយរៀង | 4 | 12 | 4 | 6 | .. | .. |
| តាកែវ | 6 | 30 | 17 | 25 | 38 | 1 |
| *សរុប* | 683 | 1,436 | 605 | 987 | 3,121 | 49 |

តារាង៣.១៦ បង្ហាញថា នៅក្នុងខេត្ត-ក្រុងមានទីប្រជុំជនធំ មានការលក់ដីតូចៗ ច្រើនជាងនៅក្នុងខេត្ត-ក្រុងមានទីប្រជុំជនតូច ។ ក្នុងខេត្តមានទីប្រជុំជនធំ, ៤២%នៃប្រតិបត្តិការលក់ទាក់ទិននឹងប្លង់ដីទំហំ ១ហិកតា ឬតិចជាង ឯក្នុងខេត្តមានទីប្រជុំជនតូចវិញ តួលេខនេះមានត្រឹម ៣៥%ប៉ុណ្ណោះ ។ ការនេះបញ្ជាក់ឱ្យដឹងថា ដីនៅក្នុងខេត្តមានទីប្រជុំជនធំ វាមានតំលៃខ្ពស់រហូត ដល់ដីតូចៗក៏មានថ្លៃខ្ពស់គ្រប់គ្រាន់ធ្វើឱ្យម្ចាស់ដីចុះបញ្ជីវាជាផ្លូវការនៅពេលទិញ-លក់ ។ ក្នុងន័យនេះដែរ គេអាចនិយាយបានថា ការលក់ដីទំហំតូចៗជាច្រើននៅក្នុងខេត្តដាច់ស្រយាល មិនបានដើរតាមនិតិវិធីផ្លូវការទេ ដូច្នេះហើយទើបមិនឃើញមានកត់ត្រានៅក្នុងទិន្នន័យនេះ ។

ក្នុងខេត្តមានទីប្រជុំជនតូច, ៦៥%នៃប្រតិបត្តិការលក់សុទ្ធតែទាក់ទិននឹងប្លង់ដីធំជាង១ហិកតា រីឯក្នុងខេត្តមានទីប្រជុំជនធំវិញមានតែ ៥៨%ប៉ុណ្ណោះ ។ ដីធំៗ (ដែលគេលក់នៅក្នុងខេត្តតូចៗនិងមិនសូវអភិវឌ្ឍន៍) ភាគច្រើនស្ថិតនៅក្នុងខេត្តកោះកុង ដែលមានដីថ្មីជាច្រើនកន្លែងលក់ចេញក្នុងតំលៃថោក ។ បន្ទាប់ពីកោះកុង គឺមានកំពង់ឆ្នាំង កំពង់ស្ពឺ និងកំពត ។

តារាង៣.១៧ បង្ហាញអំពីអាសយដ្ឋានរបស់អ្នកទិញ គិតតាមទំហំប្លង់ដីកសិកម្ម ។ យោងតាមតារាងនេះ ពីឆ្នាំ១៩៩៥-២០០១ អ្នករស់ក្នុងខេត្តមានទីប្រជុំជនធំ មិនគ្រាន់បានតែទិញដីកសិកម្មភាគច្រើនប៉ុណ្ណោះទេ ប៉ុន្តែបានទិញដីធំៗ ច្រើនជាងអ្នកទិញដែលរស់នៅក្នុងខេត្តមានទីប្រជុំជនតូច ។ ៦០% នៃដីទាំងអស់ដែលត្រូវបានផ្ទេរទៅឱ្យអ្នករស់នៅក្នុងខេត្តមានទីប្រជុំជនធំ វាមានទំហំធំជាង ១ហិកតាក្នុងមួយប្លង់ៗ ឯអត្រាដូចគ្នាសំរាប់ខេត្តមានទីប្រជុំជនតូច គឺ ៥៣% ។ អ្នកភ្នំពេញបានទិញដល់ទៅ ៣.៣២៥ប្លង់ដែលធំជាង ១ហិកតា គឺត្រូវជា ៨៤%នៃប្រតិបត្តិការលក់ដីកសិកម្មទាំងអស់ក្នុងទំហំនេះ ។ ដោយសារដីធំៗជាច្រើននៅក្នុង ក្រុងព្រះសីហនុ ខេត្តកោះកុង និងកំពង់ឆ្នាំង ជាទូទៅគឺជាដីថ្មី (ដីជាច្រើនបានពីការកាប់ឆ្ការព្រៃយក) ដូច្នេះគេអាច សន្និដ្ឋានបានថា ដីថ្មីភាគច្រើនត្រូវបានទិញដោយអ្នកភ្នំពេញ បើយោងតាមទិន្នន័យនេះ ។

**តារាង៣.១៧. របាយប្រតិបត្តិការលក់ដីកសិកម្ម បែងចែកតាមទំហំដី និងអាសយដ្ឋានរបស់អ្នកលក់**

| ទីតាំងអ្នកទិញ | ទំហំដីកសិកម្មដែលបានលក់ (ហិកតា) | | | | | |
|---|---|---|---|---|---|---|
| | >0-0.1 | >0.1-0.5 | >0.5-1.0 | >1.0-3.0 | >3.0-5.0 | >5.0-32.0 |
| | ចំនួននៃប្រតិបត្តិការលក់ (១៩៩៥-២០០១) | | | | | |
| ខេត្តក្រុង មានទីប្រជុំជនធំ | 620 | 1,237 | 535 | 851 | 2,713 | 44 |
| ភ្នំពេញ | 488 | 981 | 445 | 749 | 2,536 | 40 |
| កណ្តាល | 28 | 114 | 30 | 18 | 15 | 1 |
| សៀមរាប | 2 | 23 | 9 | 4 | 4 | .. |
| ក្រុងព្រះសីហនុ | 57 | 39 | 19 | 25 | 114 | 2 |
| បាត់ដំបង | 18 | 43 | 21 | 34 | 7 | 1 |
| កំពង់ចាម | 27 | 37 | 11 | 21 | 37 | .. |
| ខេត្តក្រុង មានទីប្រជុំជនតូច | 61 | 182 | 59 | 111 | 224 | 2 |
| បន្ទាយមានជ័យ | 2 | 8 | 6 | 8 | 5 | 2 |
| កំពង់ឆ្នាំង | 5 | 12 | 13 | 7 | 3 | .. |
| កំពង់ស្ពឺ | 19 | 12 | 8 | 3 | 2 | .. |
| កំពង់ធំ | 2 | 2 | 3 | 8 | 15 | .. |
| កំពត | 11 | 22 | 6 | 8 | 13 | .. |
| ក្រុងកែប | .. | 1 | .. | .. | .. | .. |
| កោះកុង | 12 | 90 | 13 | 55 | 171 | .. |
| ក្រចេះ | .. | .. | .. | 1 | .. | .. |
| មណ្ឌលគីរី | .. | .. | 1 | .. | .. | .. |
| ឧត្តរមានជ័យ | .. | 1 | .. | .. | .. | .. |
| ព្រៃវែង | .. | 1 | 3 | 7 | .. | .. |
| ពោធិសាត់ | .. | 10 | 1 | 3 | .. | .. |
| រតនគីរី | .. | .. | .. | 2 | 2 | .. |

| | | | | | | |
|---|---|---|---|---|---|---|
| ស្វាយរៀង | 4 | 9 | 3 | 1 | .. | .. |
| តាកែវ | 6 | 14 | 2 | 8 | 13 | .. |
| *សរុប* | 681 | 1,419 | 594 | 962 | 2,937 | 46 |

# ជំពូក ៤

# និន្នាការនៃថ្លៃដី

ដីធ្លីមានលក្ខណៈខុសប្លែកពីទំនិញលក់ដូរផ្សេងទៀតទាំងអស់ ។ លក្ខណៈខុសប្លែកជាងគេ គឺ ថ្លៃដីអាចខុសគ្នាយ៉ាងខ្លាំងពីកន្លែងមួយទៅកន្លែងមួយ ដោយគ្មានចំណុចខុសគ្នាជាក់ស្ដែងណាមួយនៅក្នុងលទ្ធភាពផលិតកម្មរបស់វាឡើយ ។ សំរាប់ប្រទេសណាមួយ មិនអាចមានថ្លៃដីជាមធ្យម ឬថ្លៃស្តង់ដា ឡើយ ។ ថ្លៃជាមធ្យមអាចយកជាការបានសំរាប់តំបន់តូចមួយប៉ុណ្ណោះ ។ ដោយសន្មតថា កត្តាអ្វីៗទៀតវាដូចគ្នា កត្តាមួយដែលធ្វើឱ្យថ្លៃដីខុសគ្នា គឺការដែលដីនោះស្ថិតនៅក្នុងទីប្រជុំជន ឬទីផ្សារ ។ កាលណាវានៅកាន់តែជិតកន្លែងទាំងនេះ ថ្លៃរបស់វាកាន់តែខ្ពស់ ។ ដីដែលមានការតភ្ជាប់ល្អជាមួយប្រព័ន្ធគមនាគមន៍ ឬប្រព័ន្ធពាណិជ្ជកម្ម ច្រើនថ្លៃខ្ពស់ជាង ។ នៅកម្ពុជា មានគំរោងហេដ្ឋារចនាសម្ព័ន្ធថ្មីៗជាច្រើនបានដំណើរការក្នុងរយៈពេលកន្លងមក ហើយថ្លៃដីក៏កើនឡើងទៅតាមការអភិវឌ្ឍន៍ និងការស្តារផ្លូវនានា ។ មានកត្តា ៣ផ្សេងទៀតដែលធ្វើឱ្យមានការប្រែប្រួលខ្លាំងនៅក្នុងទីផ្សារដីធ្លីក្នុងប្រទេសកម្ពុជាក្នុងរយៈពេល ១៥ឆ្នាំកន្លងមក ។ កត្តាទាំងនេះត្រូវបានលើកយកមកពិភាក្សាដូចខាងក្រោម ។

ទី១ ថ្លៃដីចាប់ផ្តើមកើនឡើងពីកំរិតទាបខ្លាំងក្នុងទសវត្សរ៍១៩៨០ ដែលនៅពេលនោះដីទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋតាមផ្លូវច្បាប់ ។ នៅពេលនោះដែរ គ្មានទីផ្សារដីធ្លីប្រាកដប្រជាទេ ទោះបីការទិញដូរដីបានចាប់ផ្តើមតាំងពីឆ្នាំ១៩៨៥ មកក៏ដោយ ។ ចាប់ពីឆ្នាំ១៩៨៩ ឬនៅពេលរដ្ឋអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនជាថ្មី ការលក់ដូរដី និងថ្លៃដីចាប់ផ្តើមកើនឡើងយ៉ាងគំហុក បើធៀបនឹងទសវត្សរ៍មុន ជាពិសេសនៅពេលដែលមានអ្នកទិញដីជាច្រើនបានផុសឡើង ។ យោងតាមភស្តុតាងខ្លះៗ ដីលំនៅដ្ឋានមួយចំនួនក្នុងតំបន់ទីក្រុង ត្រូវបានគេទិញក្នុងតំលៃតែ ២០០-៣០០ដុល្លារតែប៉ុណ្ណោះនៅចុងទសវត្សរ៍១៩៨០ ហើយ២-៣ឆ្នាំក្រោយមក គេលក់វិញបានច្រើនពាន់ដុល្លារ ។ នៅពាក់កណ្តាលទសវត្សរ៍១៩៩០ ដីដដែលនោះលក់បានច្រើនម៉ឺនដុល្លារ ។ ដូចបានពិពណ៌នារួចហើយ ដំណើរការនេះកើតឡើងជាចំបង ដោយសារការហូរចូលយ៉ាងច្រើននូវប្រាក់បរទេស ក្នុងទំរង់ជាចំណាយរបស់ កងកំលាំងរក្សាសន្តិភាពអ៊ុនតាក់, វិនិយោគផ្ទាល់ពីបរទេស និងការផ្ញើប្រាក់មកក្នុងស្រុកដោយអនិកជនខ្មែរនៅបរទេស ។

ទី២ ដោយសារមានសង្គ្រាមខ្ទេចខ្ទាំ ការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចញឹកញាប់ ព្រមទាំងកង្វះខាតនៃទំនុកចិត្តក្នុងប្រព័ន្ធធនាគារ ប្រជាជនកម្ពុជានៅមិនទាន់វិនិយោគ ឬដាក់ប្រាក់នៅក្នុងធនាគារទេ ។ អ្នកមានប្រាក់សន្សំច្រើន និងបានមើលឃើញពីលទ្ធភាពបានចំណេញខ្ពស់ពីការទិញលក់ដីក្នុងដំហានដំបូង ទំនងជាបានទិញដីទុកដើម្បីវិនិយោគប្រាក់សន្សំរបស់ខ្លួន ។ ការធ្វើដូចនេះ ធ្វើឱ្យទីផ្សារដីធ្លីកាន់តែមមាញឹកថែមទៀត ។

ទី៣ ប្រជាជនបានកើនឡើងយ៉ាងលឿនក្នុងទសវត្សរ៍១៩៨០ និង១៩៩០ ។ ក្នុងបរិបទដែលពុំមានមុខរបរផ្សេងៗច្រើនមុខ កំនើនប្រជាជនបានបង្កើតតំរូវការដីយ៉ាងធំ ហើយដីក៏ឡើងថ្លៃ ពីព្រោះប្រជាជនភាគច្រើនណាស់នៅពឹងពាក់លើដីធ្លីនៅឡើយ ។ ការពិត កំនើនប្រជាជនលឿនបែបនេះគួរតែធ្វើឱ្យដីឡើងថ្លៃខ្ពស់ថែមទៀត បើសិនគ្មានការរានព្រៃយកដីធ្វើកសិកម្ម

និងលំនៅដ្ឋាននោះទេ ។ ដីព្រៃកាលពីទសវត្សរ៍១៩៧០ មាន ៧៣%នៃផ្ទៃប្រទេស ប៉ុន្តែបច្ចុប្បន្នមានតែ ៦០%ប៉ុណ្ណោះ ។

ការវិភាគពីថ្លៃដីរបស់យើង មិនមែនគ្រាន់តែផ្អែកលើថ្លៃដីចុះកត់ត្រាក្នុងឯកសារផ្ទេរកម្មសិទ្ធិដីចំនួន ១៥.៩៧៦ឯកសារ ដែលតំកល់នៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនោះទេ ។ អង្កេតទ្រង់ទ្រាយតូចមួយ និងការសំភាសន៍ជាមួយប្រធានសុរិយោដីស្រុកក្នុង១០ស្រុក និងប្រធានឃុំក្នុង១៨ឃុំ (នៃ ៥ខេត្ត) បានផ្តល់នូវមូលដ្ឋានសំរាប់ពន្យល់ពីនិន្នាការនៃថ្លៃដី បានជាក់លាក់ជាងទិន្នន័យផ្លូវការទៅទៀត ។ យោងតាមអង្កេត និងសំភាសន៍ទាំងនេះ ថ្លៃដីកត់ត្រាក្នុងឯកសារផ្ទេរជាផ្លូវការ ត្រូវបានបន្ថយចុះអស់ពី ៤០% ទៅ ៨០% ដើម្បីចៀសវាងការបង់ពន្ធប្រថាប់ត្រាខ្ពស់[១] ។ ការលាក់បាំងថ្លៃនៅក្នុងឯកសារសុរិយោដី គ្មានលំនាំអ្វីច្បាស់លាស់ទេ ហើយយើងក៏មិនអាចធ្វើការកែតំរូវអ្វីបានដែរសំរាប់ការវិភាគ ។ ប៉ុន្តែដោយសារកំរងទិន្នន័យផ្អែកលើគំរូតាងទំហំធំ ដូច្នេះនៅតែមានការទាញសេចក្តីសន្និដ្ឋានមួយចំនួន ពីនិន្នាការ និងភាពខុសគ្នាតាមតំបន់ នៃថ្លៃដីធ្លី ។

គួរនិយាយពីដំបូងថា ដោយសារថ្លៃដីប្រែប្រួលខុសគ្នាយ៉ាងខ្លាំង ទាំងចំពោះដីលំនៅដ្ឋាន និងដីកសិកម្ម (នោះគឺបំរែបំរួលស្តង់ដា មានកំរិតខ្ពស់ជាងតំលៃមធ្យម) ដូច្នេះថ្លៃដីគិតជាមធ្យម មិនសូវមានអត្ថន័យឡើយ ហើយការបកស្រាយផ្សេងៗពីភាពខុសគ្នានៃ ថ្លៃដីជាមធ្យម រវាងខេត្តនានា ក៏ត្រូវមានការប្រុងប្រយ័ត្នដែរ ។

## ៤.១ ថ្លៃដីលំនៅដ្ឋាន

តារាង៤.១ បង្ហាញនូវថ្លៃដីលំនៅដ្ឋានគិតជាមធ្យមសំរាប់តំបន់ទីប្រជុំជន ដោយបែងចែកតាមខេត្ត-ក្រុងនិងតាមលំដាប់នៃថ្លៃដី សំរាប់រយៈពេលពីឆ្នាំ ១៩៩៥-២០០១ ។ យើងបានសន្មតថា ថ្លៃទាំងអស់សុទ្ធតែបានកត់ត្រាតិចជាងថ្លៃពិតក្នុងកំរិតដូចគ្នានៅទូទាំងប្រទេស ទោះបីការសន្មតនេះមិនសូវសមហេតុផលក៏ដោយ ប៉ុន្តែយើងគ្មានលទ្ធភាពអ្វីផ្សេង ។ យោងតាមទិន្នន័យនេះ ក្រុងព្រះសីហនុ មានថ្លៃដីលំនៅដ្ឋានគិតជាមធ្យមកំរិតខ្ពស់ជាងគេ[២] ។ ក្នុងរយៈពេលជាច្រើនឆ្នាំ ថ្លៃជាមធ្យមប្រែប្រួលជុំវិញ ៨០.០០០រៀលក្នុងមួយម៉ែត្រការ៉េ ឬប្រហែល ២០ដុល្លារក្នុងមួយម៉ែត្រការ៉េ គិតតាមអត្រាប្តូរប្រាក់បច្ចុប្បន្ន ។ ថ្លៃរាយការណ៍ជាផ្លូវការ កើនឡើងខ្ពស់បំផុតក្នុងឆ្នាំ២០០១ នៅពេលដែលដីលំនៅដ្ឋានមួយចំនួនបានលក់ក្នុងតំលៃជិត ២០០.០០០រៀលក្នុងមួយម៉ែត្រការ៉េ ឬប្រហែល ៥០ដុល្លារក្នុងមួយម៉ែត្រការ៉េ គិតជាមធ្យម ។ យោងតាមអង្កេតផ្ទាល់នៅមូលដ្ឋាន ដីថ្លៃខ្ពស់ទាំងនេះស្ថិតនៅក្បែរឆ្នេរសមុទ្រ ។ ផ្ទុយទៅវិញ ទីក្រុងឆ្នេរសមុទ្រមួយទៀត គឺក្រុងកែប ជាកន្លែងមានដីលំនៅដ្ឋានថោកជាងគេបំផុត ទោះបីជាវាមានលក្ខណៈស្រដៀងគ្នានឹងទីក្រុងកំពង់សោមក៏ដោយ (ដូចជាមានបរិដ្ឋានមាត់សមុទ្រ) ពីព្រោះទីក្រុងនេះនៅឆ្ងាយ និងមានហេដ្ឋារចនាសម្ព័ន្ធអន់ ។

ថ្លៃដីលំនៅដ្ឋាននៅតំបន់ទីប្រជុំជនក្នុងទូទាំងប្រទេស បានកើនយ៉ាងខ្លាំងចាប់ពីឆ្នាំ១៩៩៥ ដល់ ២០០១ (តារាង៤.១) ។ រឿងនេះត្រូវបានបញ្ជាក់ថាពិត ដោយអង្កេតតាមមូលដ្ឋាននៅក្នុង ៥ខេត្ត (សូមអានផ្នែកបន្ទាប់) ។ ថ្លៃជាមធ្យមទូទៅ បានកើនពីប្រហែល ១០ដុល្លារក្នុងមួយម៉ែត្រការ៉េនៅឆ្នាំ១៩៩៥ ទៅដល់ជាង ២០ដុល្លារក្នុងមួយម៉ែត្រការ៉េនៅឆ្នាំ២០០០ ។ ទោះបីទិន្នន័យបង្ហាញថា ការទិញលក់ធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០០ និង២០០១ ប៉ុន្តែថ្លៃដីនៅតែមិនធ្លាក់ចុះគួរឱ្យកត់សំគាល់ឡើយ យោងតាមតួលេខក្នុងឯកសារផ្លូវការ និងតាមអង្កេតដល់មូលដ្ឋាន ។ អ្នកឆ្លើយសំភាសន៍ភាគច្រើននៅក្នុងអង្កេតតាមមូលដ្ឋាន បាននិយាយថា ការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច ជាពិសេសវិនិយោគផ្ទាល់ពីបរទេស គឺជាមូលហេតុចំបងនៃការធ្លាក់ចុះតំរូវការដី។ មូលហេតុមួយទៀតអាចមកពីការទិញទុកយកចំណេញបានថយចុះនៅពេលដីឡើងថ្លៃខ្ពស់ពេក ដូច្នេះហើយចំនួនទិញលក់ជាក់ស្តែងក៏បានធ្លាក់ចុះយ៉ាងខ្លាំង ។ មូលហេតុមួយដែលធ្វើឱ្យថ្លៃដីមិនធ្លាក់ចុះ គឺអាចមកពីម្ចាស់កម្មសិទ្ធិបច្ចុប្បន្នពុំមានតំរូវការ

[១] ផ្នែកទី៥ ពិភាក្សាចំនុចនេះលំអិតថែមទៀត ។

[២] ថ្លៃដីនៅក្រុងភ្នំពេញ ប្រាកដជាខ្ពស់ជាងគេ ក៏ប៉ុន្តែយើងគ្មានទិន្នន័យនៅទីនេះទេ ។

ចាំបាច់ត្រូវលក់ដីវិញនៅក្នុងពេលនេះ ។

**តារាង៤.១. ថ្លៃដីលំនៅដ្ឋានគិតជាមធ្យម នៅក្នុងតំបន់ទីប្រជុំជន**

| ទីតាំងដី | (ពាន់រៀល/ម៉ែត្រការ៉េ) | | | | | | | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | (95-01) |
| ក្រុងព្រះសីហនុ | 75 | 76 | 68 | 95 | 105 | 96 | 197 | 102 |
| កំពង់ចាម | 25 | 25 | 130 | 148 | 128 | 120 | 97 | 96 |
| បាត់ដំបង | 27 | 42 | 60 | 83 | 108 | 163 | 126 | 87 |
| ព្រៃវែង | .. | 134 | 27 | 90 | 63 | 58 | .. | 75 |
| បន្ទាយមានជ័យ | 30 | 27 | 28 | 52 | 71 | 127 | 154 | 70 |
| សៀមរាប | 19 | 47 | 34 | 46 | 69 | 96 | 84 | 57 |
| កណ្តាល | 24 | 31 | 77 | 55 | 68 | 71 | .. | 54 |
| ក្រចេះ | 17 | 36 | 40 | 58 | 42 | 98 | 89 | 54 |
| ពោធិសាត់ | .. | 73 | 11 | 8 | 136 | 19 | .. | 49 |
| ស្វាយរៀង | 20 | 23 | 22 | 60 | 46 | 51 | 80 | 43 |
| កំពត | 13 | 21 | 17 | 41 | 32 | 54 | 68 | 35 |
| កោះកុង | 23 | 15 | 64 | 29 | 29 | 31 | 27 | 31 |
| រតនគិរី | .. | .. | 44 | 23 | 11 | 8 | 14 | 20 |
| កំពង់ធំ | 29 | 13 | 18 | 33 | 9 | 24 | 10 | 20 |
| កំពង់ឆ្នាំង | 22 | 13 | 7 | 20 | 19 | 23 | 17 | 17 |
| តាកែវ | .. | 6 | 11 | 11 | 10 | 18 | 13 | 12 |
| កំពង់ស្ពឺ | 6 | 18 | 6 | 14 | 9 | 13 | 10 | 11 |
| ក្រុងកែប | 12 | 3 | 3 | 4 | 3 | 2 | 1 | 4 |

**តារាង៤.២. ថ្លៃដីលំនៅដ្ឋានគិតជាមធ្យម នៅក្នុងតំបន់ជនបទ**

| ទីតាំងដី | (ពាន់រៀល/ម៉ែត្រការ៉េ) | | | | | | | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | (95-01) |
| ព្រៃវែង | 10 | 58 | 4 | 90 | 19 | 97 | 59 | 48 |
| បន្ទាយមានជ័យ | 32 | 18 | 18 | 16 | 34 | 56 | 129 | 43 |
| កំពង់ចាម | 14 | 29 | 28 | 21 | 30 | 60 | 83 | 38 |
| សៀមរាប | 14 | 21 | 41 | 10 | 11 | 73 | 15 | 26 |
| បាត់ដំបង | 10 | 9 | 42 | 20 | 49 | .. | .. | 26 |
| ក្រចេះ | .. | 0 | 83 | 0 | 23 | 17 | 44 | 24 |
| ស្វាយរៀង | 2 | 8 | 6 | 15 | 26 | 84 | 14 | 22 |
| កំពត | 5 | 10 | 8 | 15 | 11 | 49 | 35 | 19 |
| កោះកុង | 65 | 15 | 4 | 15 | 8 | 3 | .. | 18 |
| កណ្តាល | 5 | 4 | 14 | 15 | 18 | .. | .. | 11 |
| តាកែវ | .. | 4 | 8 | 14 | 14 | 13 | 15 | 11 |
| កំពង់ធំ | .. | 3 | 1 | 18 | 8 | 7 | 3 | 7 |
| ពោធិសាត់ | .. | 1 | 3 | .. | 0 | .. | 15 | 5 |
| កំពង់ស្ពឺ | 6 | 8 | 4 | 5 | 4 | 1 | .. | 4 |
| កំពង់ឆ្នាំង | 10 | 2 | 2 | 2 | 7 | 7 | 0 | 4 |
| មធ្យមភាគ | 6 | 7 | 15 | 18 | 19 | 49 | 54 | 24 |

តារាង៤.២ បង្ហាញថា និន្នាការថ្លៃដីលំនៅដ្ឋាននៅតំបន់ជនបទ ស្រដៀងគ្នានឹងនិន្នាការនៅតំបន់ទីប្រជុំជន ប៉ុន្តែកំណើនថ្លៃដីនៅតំបន់ជនបទ មានកំរិតខ្ពស់ជាងនៅតំបន់ទីប្រជុំជន ។ ថ្លៃដីជាមធ្យមកើនពី ៦.០០០រៀលក្នុងមួយម៉ែត្រការ៉េ ឬប្រហែល ២ដុល្លារក្នុងមួយម៉ែត្រការ៉េក្នុងឆ្នាំ១៩៩៥ ទៅដល់ ៥៤.០០០រៀលក្នុងមួយម៉ែត្រការ៉េ ឬប្រហែល ១៤ដុល្លារក្នុងមួយម៉ែត្រការ៉េក្នុងឆ្នាំ២០០១ ។ មូលហេតុមួយនៃកំណើន ៧ដងនៅក្នុងតំបន់ជនបទនេះ (ធៀបនឹងកំណើន ២ដងនៅក្នុងតំបន់ទីប្រជុំជន) គឺមកពីថ្លៃដីនៅតំបន់ជនបទមានកំរិតទាបក្នុងឆ្នាំ១៩៩៥ ។ តាមពិត ការចាប់ផ្តើមសកម្មភាពពាណិជ្ជកម្មក្នុងតំបន់ជនបទគ្រប់កន្លែងមានការយឺតជាងនៅតំបន់ទីប្រជុំជន ។ ដូច្នេះថ្លៃជាមូលដ្ឋានពីដំបូងមានកំរិតទាប ។

បើគិតតាមខេត្តវិញ ថ្លៃដីលំនៅដ្ឋានក្នុងតំបន់ជនបទ វាមានកំរិតខ្ពស់បំផុតនៅខេត្តព្រៃវែង បន្ទាយមានជ័យ និង កំពង់ចាម ។ មូលហេតុដែលខេត្តទាំងនេះមានដីជនបទថ្លៃ អាចមកពីការរាប់បញ្ចូលទីប្រជុំជនមួយចំនួន ដូចជា អ្នកលឿង ប៉ោយប៉ែត និងស្គន់ ចូលទៅក្នុងចំណាត់ថ្នាក់ជនបទ ទោះបីជាកន្លែងទាំងនេះលក្ខណៈជាតំបន់ទីប្រជុំជនក៏ដោយ ។ ការប្រៀប ធៀបលំអិតរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ មានចុះក្នុង តារាង៤.៣ ខាងក្រោម ។

**តារាង៤.៣. ថ្លៃដីលំនៅដ្ឋាន តាមខេត្ត បែងចែកតាមតំបន់ទីប្រជុំជន និងតំបន់ជនបទ ពីឆ្នាំ១៩៩៥ - ២០០១**

| ទីតាំងដី | តំបន់ទីប្រជុំជន | | | តំបន់ជនបទ | | |
|---|---|---|---|---|---|---|
| | ថ្លៃជាមធ្យម | | ចំនួន | ថ្លៃជាមធ្យម | | ចំនួន |
| | ('000 Riels/m²) | ($'000/ha)* | | ('000 Riels/m²) | ($'000/ha)* | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | | | 3,064 | | | 2,474 |
| កណ្តាល | 52 | 148 | 963 | 8 | 23 | 2,072 |
| ក្រុងព្រះសីហនុ | 90 | 257 | 1,237 | .. | .. | .. |
| សៀមរាប | 55 | 158 | 225 | 34 | 96 | 79 |
| បាត់ដំបង | 86 | 246 | 372 | 26 | 74 | 72 |
| កំពង់ចាម | 108 | 309 | 152 | 34 | 98 | 251 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | | | *2,023* | | | *1,354* |
| បន្ទាយមានជ័យ | 74 | 210 | 189 | 35 | 100 | 491 |
| កំពង់ឆ្នាំង | 17 | 49 | 189 | 3 | 10 | 132 |
| កំពង់ស្ពឺ | 11 | 32 | 101 | 5 | 15 | 119 |
| កំពង់ធំ | 18 | 51 | 271 | 7 | 21 | 53 |
| កំពត | 34 | 97 | 283 | 19 | 56 | 96 |
| ក្រុងកែប | 3 | 8 | 114 | .. | .. | .. |
| កោះកុង | 28 | 81 | 118 | 16 | 46 | 20 |
| ក្រចេះ | 55 | 158 | 217 | 25 | 71 | 15 |
| ព្រៃវែង | 58 | 164 | 29 | 53 | 150 | 66 |
| ពោធិសាត់ | 93 | 264 | 31 | 3 | 9 | 8 |
| រតនគិរី | 17 | 50 | 44 | .. | .. | .. |
| ស្វាយរៀង | 42 | 120 | 340 | 30 | 86 | 128 |
| តាកែវ | 11 | 32 | 212 | 12 | 33 | 226 |
| សរុប | 52 | 148 | 5,087 | 16 | 46 | 7,656 |

* *គិតតាមអត្រាប្តូរប្រាក់ជាមធ្យម សំរាប់រយៈពេលពីឆ្នាំ១៩៩៥-២០០១ គឺ* 3,500 Riels/$

**តារាង៤.៤. ថ្លៃដីលំនៅដ្ឋានគិតជាមធ្យម គិតតាមទំហំ** (Riels/m²)

| ទំហំ (ម៉ែត្រការ៉េ) | (រៀល/ម៉ែត្រការ៉េ) | | | | |
|---|---|---|---|---|---|
| | មធ្យម | គំលាត | អប្បបរមា | អតិបរមា | ចំនួនប្រតិបត្តិការលក់ដី |
| | តំបន់ទីប្រជុំជន | | | | |
| >0 – 350 | 100,288 | 128,038 | 800 | 714,286 | 2,033 |
| >350 - 1,000 | 24,651 | 44,438 | 213 | 652,175 | 1,559 |
| >1,000 – 2,500 | 15,682 | 28,198 | 100 | 385,000 | 1,150 |
| >2,500 – 30,000 | 8,900 | 15,989 | 10 | 136,662 | 312 |
| >30,000 - | 1,438 | 6,188 | 17 | 35,575 | 33 |
| សរុប | | | | | 5,087 |
| | ថ្លៃដីជនបទ | | | | |
| >0 – 350 | 38,456 | 70,565 | 350 | 669,643 | 1,185 |
| >350 - 1,000 | 7,714 | 12,793 | 108 | 158,730 | 1,150 |
| >1,000 – 2,500 | 5,201 | 9,376 | 30 | 127,260 | 1,053 |
| >2,500 – 30,000 | 3,069 | 3,485 | 13 | 23,496 | 420 |
| >30,000 - | 80 | 90 | 10 | 392 | 20 |
| សរុប | | | | | 3,828 |

តើដីឡូត៍ធំៗ នឹងដីឡូត៍តូចៗ វាមានថ្លៃខុសគ្នាមែនទេ? ចំលើយគឺពិតដូច្នេះមែន ពីព្រោះដីឡូត៍តូចៗមានតំលៃសរុប តិចជាង ងាយស្រួលជាងសំរាប់ការសង់ផ្ទះ និងច្រើនស្ថិតក្នុងតំបន់មានពាណិជ្ជកម្មច្រើន ។ ឧទាហរណ៏ គេមិនគួររំពឹងថា មានដី

ទំនេរដ៏ធំមួយកន្លែងនៅក្នុងតំបន់មានសកម្មភាពពាណិជ្ជកម្មមមាញឹក ឬមានតំរូវការសង់ផ្ទះសំបែងខ្លាំងឡើយ ។ តាមធម្មតា ដីឡូត៍ធំៗច្រើននៅជាច់ឆ្ងាយបន្តិច ដូចមានបង្ហាញនៅក្នុង តារាង៤.៤ ។

## ៤.២ ថ្លៃដីកសិកម្ម

ថ្លៃដីកសិកម្មនៅក្នុងតំបន់ទីប្រជុំជនដែលមាននៅក្នុងទិន្នន័យទាំងនេះ មានបង្ហាញនៅក្នុង តារាង៤.៥ ។ តួលេខនៅក្នុងតារាងដូចតទៅនេះ គិតជារៀល មិនមែនជាពាន់រៀលដូចតារាងមុនៗទេ ពីព្រោះថ្លៃមានកំរិតទាបជាង ។ ថ្លៃមធ្យមសំរាប់រយៈពេលពីឆ្នាំ១៩៩៥-២០០១ មានកំរិតខ្ពស់បំផុតនៅក្រុងព្រះសីហនុ ។ លំដាប់ថ្លៃខ្ពស់ៗជាងគេ មាននៅតាមខេត្តដែលដីធ្លីមានទិន្នផលកសិកម្មខ្ពស់ និងមានសក្តានុពលខាងពាណិជ្ជកម្មប្រសើរជាង ។ មូលហេតុដែលដីនៅខេត្តកំពង់ស្ពឺមានថ្លៃខ្ពស់នៅក្នុងទិន្នន័យនេះ គឺដោយសារមានផ្លូវជាតិលេខ៤ ឆ្លងកាត់ ដែលធ្វើឱ្យដីកសិកម្មនៅតាមបណ្តោយផ្លូវនេះឡើងថ្លៃខ្ពស់ ។ វាប្រហែលត្រូវហើយដែលគិតថា ដីនៅក្នុងទិន្នន័យទាំងនេះ ភាគច្រើនគឺស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ។ ខេត្តសៀមរាប និង ខេត្តកណ្តាល គឺជាកន្លែងមានទីប្រជុំជនធំ និងមានសកម្មភាពពាណិជ្ជកម្មច្រើន រីឯខេត្តបាត់ដំបង គឺជាខេត្តកសិកម្មយ៉ាងសំខាន់ ។

**តារាង៤.៥. ថ្លៃដីកសិកម្ម គិតជាមធ្យម នៅក្នុងតំបន់ទីប្រជុំជន**

| ទីតាំងដី | (រៀល/ម²) | | | | | | | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | (95-01) |
| ក្រុងព្រះសីហនុ | 10,273 | 8,017 | 4,228 | 7,695 | 13,451 | 29,138 | 52,587 | 17,913 |
| កំពង់ស្ពឺ | 25,960 | 9,497 | 3,980 | 6,664 | 2,829 | 1,514 | 10,526 | 8,710 |
| សៀមរាប | 2,033 | 3,150 | 1,933 | 9,186 | 5,294 | 4,107 | 15,742 | 5,921 |
| កណ្តាល | 245 | 861 | 1,688 | 6,825 | 5,268 | 9,029 | .. | 3,986 |
| បាត់ដំបង | 1,124 | 9,103 | 628 | 3,184 | 100 | .. | .. | 2,828 |
| កោះកុង | 1,402 | 2,537 | .. | 19 | 22 | 2,906 | .. | 1,377 |
| ក្រុងកែប | .. | 2,064 | 1,112 | 1,699 | 1,502 | 982 | 325 | 1,281 |
| តាកែវ | .. | 78 | 729 | 1,495 | 2,874 | 911 | .. | 1,217 |
| កំពត | .. | 643 | .. | 853 | 2,113 | 1,184 | 1,173 | 1,193 |
| កំពង់ចាម | .. | .. | .. | 1,012 | .. | .. | .. | 1,012 |
| ស្វាយរៀង | 45 | .. | .. | 452 | 793 | 1,639 | 126 | 611 |
| បន្ទាយមានជ័យ | .. | .. | 27 | 1,333 | 637 | 420 | 448 | 573 |
| រតនគិរី | .. | .. | 1,497 | .. | 37 | 51 | .. | 528 |
| កំពង់ឆ្នាំង | 36 | 61 | 95 | 533 | .. | 1,643 | .. | 474 |
| ពោធិសាត់ | .. | 89 | 54 | .. | 142 | 817 | 295 | 279 |
| ក្រចេះ | .. | .. | .. | .. | .. | 128 | .. | 128 |
| ព្រៃវែង | 63 | | 47 | 93 | .. | .. | .. | 68 |
| មធ្យមភាគ | 6,074 | 6,351 | 3,828 | 6,814 | 4,933 | 15,705 | 23,425 | 9,590 |

ថ្លៃដីកសិកម្មនៅក្នុងតំបន់ជនបទ ពុំមានលំដាប់ដូចគ្នានឹងតំបន់ទីប្រជុំជនទេ ប៉ុន្តែក្រុមខេត្តនៅខាងលើតារាង និងក្រុមខេត្តនៅខាងក្រោមតារាង មិនខុសគ្នាពីតំបន់ទីប្រជុំជនប៉ុន្មានទេ (តារាង៤.៦) ។ ឧទាហរណ៍ ខេត្តសៀមរាប កណ្តាល និង កំពង់ស្ពឺ ស្ថិតក្នុងចំណោមខេត្តមានដីថ្លៃខ្ពស់ ឯខេត្តរតនគិរី ក្រចេះ ពោធិសាត់ និងកំពង់ឆ្នាំង ស្ថិតនៅលំដាប់ក្រោមគេទាំងចំពោះ ដីជនបទ និងដីទីប្រជុំជន ។ មូលហេតុនៃការខុសគ្នាក្នុងលំដាប់ថ្លៃ គឺមកពីការឱ្យនិយមន័យតំបន់ជនបទ និងតំបន់ទីប្រជុំជន ការបូកសរុបថ្លៃនៅថ្នាក់ខេត្ត និងគំរូតាងដែលតំណាងឱ្យដីធ្លីមួយប្រភេទតូចប៉ុណ្ណោះ ។

## តារាង៤.៦. ថ្លៃដីកសិកម្ម គិតជាមធ្យម នៅក្នុងតំបន់ជនបទ

| ទីតាំងដី | (រៀល/ម²) | | | | | | | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|
| | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 | (95-01) |
| សៀមរាប | 655 | 2,075 | 720 | 35,087 | 2,866 | 2,848 | 289 | 6,363 |
| កំពត | 525 | 224 | 301 | 2,641 | 673 | 1,169 | 1,593 | 1,018 |
| កណ្ដាល | 119 | 168 | 659 | 2,564 | 1,941 | 500 | .. | 992 |
| កំពង់ស្ពឺ | 386 | 470 | 3,396 | 686 | 501 | 35 | .. | 912 |
| តាកែវ | .. | 323 | 227 | 148 | 297 | 4,100 | 242 | 890 |
| បន្ទាយមានជ័យ | .. | 252 | 679 | 503 | 1,971 | 1,536 | 346 | 881 |
| កោះកុង | 262 | 192 | 898 | 1,442 | 1,380 | 976 | 977 | 875 |
| ស្វាយរៀង | .. | .. | 316 | .. | 609 | 650 | 750 | 581 |
| កំពង់ចាម | 185 | 51 | 195 | 154 | 1,751 | 533 | .. | 478 |
| បាត់ដំបង | 57 | 73 | 196 | 601 | 617 | .. | 65 | 268 |
| ពោធិសាត់ | .. | 318 | .. | | 98 | .. | .. | 208 |
| ក្រចេះ | .. | 34 | .. | 34 | .. | .. | 434 | 167 |
| កំពង់ឆ្នាំង | 372 | 137 | 65 | 115 | 48 | 166 | 81 | 141 |
| ព្រៃវែង | .. | .. | .. | 118 | .. | .. | .. | 118 |
| កំពង់ធំ | .. | 116 | .. | 27 | 44 | 41 | 8 | 47 |
| រតនគិរី | .. | .. | .. | 27 | .. | .. | .. | 27 |
| មធ្យមភាគ | 170 | 224 | 607 | 1,251 | 1172 | 743 | 239 | 629 |

## តារាង៤.៧. ថ្លៃដីកសិកម្ម គិតតាមខេត្ត និងបែងចែកជាតំបន់ទីប្រជុំជន និងតំបន់ជនបទ

| ទីតាំងដី | តំបន់ទីប្រជុំជន | | | តំបន់ជនបទ | | |
|---|---|---|---|---|---|---|
| | ថ្លៃមធ្យម | | ចំនួន | ថ្លៃមធ្យម | | ចំនួន |
| | រៀល/ម | ដុល្លារ/ហិកតា* | | រៀល/ម | ដុល្លារ/ហិកតា* | |
| ខេត្ត-ក្រុង មានទីប្រជុំជនធំ | | | *2,476* | | | *2,040* |
| កណ្ដាល | 1,424 | 4,069 | 500 | 559 | 1,597 | 1,704 |
| សៀមរាប | 4,209 | 12,026 | 78 | 3,508 | 10,023 | 57 |
| ក្រុងព្រះសីហនុ | 8,744 | 24,983 | 1,817 | .. | .. | .. |
| បាត់ដំបង | 3,618 | 10,337 | 80 | 333 | 951 | 34 |
| កំពង់ចាម | 1,012 | 2,891 | 1 | 250 | 714 | 245 |
| ខេត្ត-ក្រុង មានទីប្រជុំជនតូច | | | *382* | | | *1,983* |
| បន្ទាយមានជ័យ | 502 | 1,434 | 13 | 809 | 2,311 | 93 |
| កំពង់ឆ្នាំង | 415 | 1,186 | 12 | 105 | 300 | 664 |
| កំពង់ស្ពឺ | 8,247 | 23,563 | 43 | 1,193 | 3,409 | 202 |
| កំពង់ធំ | .. | .. | .. | 28 | 80 | 73 |
| កំពត | 1,153 | 3,294 | 24 | 782 | 2,234 | 186 |
| ក្រុងកែប | 1,372 | 3,920 | 67 | .. | .. | .. |
| កោះកុង | 193 | 551 | 170 | 661 | 1,889 | 635 |
| ក្រចេះ | 128 | 366 | 1 | 134 | 383 | 4 |
| ព្រៃវែង | 65 | 186 | 9 | 118 | 337 | 1 |
| ពោធិសាត់ | 261 | 746 | 11 | 142 | 406 | 5 |
| រតនគិរី | 770 | 2,200 | 4 | 27 | 77 | 5 |
| ស្វាយរៀង | 409 | 1,169 | 12 | 569 | 1,626 | 14 |
| តាកែវ | 893 | 2,551 | 16 | 304 | 869 | 101 |
| **សរុប** | | | 2,858 | | | 4,023 |

* *គិតតាមអត្រាប្ដូរប្រាក់ជាមធ្យម សំរាប់រយៈពេលឆ្នាំ១៩៩៥-២០០១ គឺ3,500 Riels/$*

ដូចក្នុងករណីដីលំនៅដ្ឋានដែរ តារាង៤.៧ ត្រូវបានបង្កើតឡើងសំរាប់ការប្រៀបធៀបងាយស្រួល រវាងថ្លៃដីនៅជនបទ

និងនៅតំបន់ទីប្រជុំជន តាមខេត-ក្រុង ។

វាជាការមួយគួរឱ្យឆ្ងល់ដែរដែល ថ្លៃដីកសិកម្មប្រែប្រួលទៅតាមទំហំដី ជាពិសេសចំពោះដីធ្លីនៅក្នុងប្រភេទតូច ដែលមានទំហំខុសគ្នាតែបន្តិចបន្តួច (តារាង៤.៨) ។ មូលហេតុមួយអាចមកពីដីតូចៗជាច្រើន (តូចជាង ឬស្មើ ២.៥០០ម៉ែត្រការ៉េ) គឺជាដីកសិកម្មតែឈ្មោះទេ ។ ក្នុងការប្រើប្រាស់ជាក់ស្តែង ដីទាំងនេះអាចជាដីលំនៅដ្ឋាន ឬដីពាណិជ្ជកម្ម ដែលតាំងនៅក្បែរទីប្រជុំជន ឬមណ្ឌលពាណិជ្ជកម្ម ។ ការដែលដីទាំងនេះត្រូវបានចុះបញ្ជី និងផ្ទេរជាផ្លូវការ បានបង្ហាញថា មានការចាយវាយប្រាក់យ៉ាងច្រើនទៅលើវា ដូច្នេះវាមិនមែនជាដីកសិកម្មដែលកសិករប្រើប្រាស់សំរាប់ផលិតដំណាំតាមធម្មតាទេ ពីព្រោះដីតូចៗបែបនេះមិនអាចផ្តល់ចំណូលបានច្រើនសមស្របនឹងចំណាយប៉ុណ្ណោះឡើយ ។

**តារាង៤.៨. ថ្លៃដីកសិកម្ម គិតតាមទំហំដី (រៀល/ម$^{២}$)**

| ទំហំ (ម$^{២}$) | រៀល/ម$^{២}$ | | | | |
|---|---|---|---|---|---|
| | មធ្យម | គំលាត | អប្បបរមា | អតិបរមា | ចំនួនប្រតិបត្តិការលក់ដី |
| | តំបន់ទីប្រជុំជន | | | | |
| >0 – 350 | 40,510 | 56,988 | 150 | 335,294 | 72 |
| >350 – 1,000 | 26,297 | 40,427 | 60 | 540,000 | 391 |
| >1,000 - 2,500 | 7,059 | 11,363 | 60 | 90,000 | 379 |
| >2,500 - 30,000 | 1,807 | 4,031 | 16 | 51,722 | 902 |
| >30,000 - | 233 | 697 | 6 | 17,827 | 1,114 |
| សរុប | | | | | 2,858 |
| | តំបន់ជនបទ | | | | |
| >0 – 350 | 7,642 | 10,184 | 118 | 38,000 | 45 |
| >350 – 1,000 | 1,378 | 2,494 | 60 | 16,200 | 175 |
| >1,000 - 2,500 | 1,237 | 3,186 | 25 | 39,500 | 389 |
| >2,500 - 30,000 | 630 | 3,112 | 9 | 104,593 | 1,358 |
| >30,000 - | 144 | 320 | 6 | 3,962 | 2,056 |
| សរុប | | | | | 4,023 |

## ជំពូក ៥

# លទ្ធផលអង្កេតខ្នាតតូច ដែលប្រើប្រាស់វិធីសិក្សាបែបគុណភាព

ដើម្បីស្វែងយល់ពីស្ថានភាពទីផ្សារដីធ្លីនៅកម្ពុជា អង្កេតបែបគុណភាពមួយត្រូវបានធ្វើនៅក្នុង ៥ខេត្ត គឺ កណ្ដាល កំពង់ចាម កំពង់ស្ពឺ បាត់ដំបង និងក្រុងព្រះសីហនុ ។ ក្នុងខេត្តនីមួយៗ យើងបានជ្រើសរើសយកពីរស្រុក នៅក្នុងស្រុកនីមួយៗ យើងបានជ្រើសរើសយកពីរឃុំ ដើម្បីធ្វើសំភាសន៍ ។ អ្នកឆ្លើយសំភាសន៍គឺមាន ប្រធានសុរិយោដីស្រុក និងប្រធានឃុំ ជួនកាលមានទាំងមន្ត្រីខ្លះទៀតដែលដឹងរឿងដីធ្លីផងដែរ ។ គោលបំណងចំបងនៃការស្រាវជ្រាវនេះគឺប្រមូលពតិមានស្ដីពី លក្ខណៈ និងនិន្នាការនៃការលក់ដីក្រៅផ្លូវការ ។ គោលបំណងមួយទៀត គឺដើម្បីស្វែងយល់ថា តើពន្ធលើការលក់ដី បានរារាំងដល់ប្រជាជនក្នុងការចុះបញ្ជីការលក់ដី យ៉ាងដូចម្ដេចខ្លះ ។

### ៥.១. ការទិញ-លក់ដី (land transactions)

កិច្ចសំភាសន៍បានបង្ហាញថា ការទិញលក់ដីបានកើតឡើងនៅពាក់កណ្ដាលទសវត្សរ៍១៩៨០ ទោះបីកម្មសិទ្ធិដីធ្លីឯកជនត្រូវបានអនុញ្ញាតចាប់ពីឆ្នាំ១៩៨៩ មកក៏ដោយ ។ ទីផ្សារដីធ្លីបានផុសឡើងច្បាស់លាស់ នៅដើមទសវត្សរ៍១៩៨០ នៅពេលដែលសកម្មភាពទិញដីដើម្បីទុកលក់យកចំណេញ បានស្ទុះឡើងយ៉ាងខ្លាំង ទន្ទឹមគ្នានឹងការហូរចូលយ៉ាងច្រើននូវ បុគ្គលិកអង្គការសហប្រជាជាតិ និងបុគ្គលិកសហគមន៍ផ្ដល់ជំនួយអន្តរជាតិ ។ ក្នុងវិស័យលំនៅដ្ឋាន គឺមានតំរូវការផ្ទាល់ពីបុគ្គលិកទាំងនេះ ព្រមទាំងតំរូវការទាក់ទិនជាប្រយោលនឹងវត្តមានជនទាំងនេះ ។ នៅក្នុងវិស័យកសិកម្ម មានតំរូវការកើនឡើងពីក្រុមអ្នកជំនួញ និងពីអ្នកដែលចាប់ផ្ដើមស្វែងរកទ្រព្យសម្បត្តិថ្មីបន្ថែមទៀត ។

ដូចបានបញ្ជាក់រួចហើយ បច្ចុប្បន្នគ្មានអង្កេតគោលណាមួយស្ដីពីដីធ្លីនៅកម្ពុជាទេ ។ ជាលទ្ធផល ការសិក្សាអំពីទីផ្សារដីធ្លីត្រូវជួបឧបសគ្គមួយចំនួន ។ ម្យ៉ាងវិញទៀត មានឯកសារតិចតួចណាស់ស្ដីពីការអភិវឌ្ឍន៍ទីផ្សារដីធ្លីនៅកម្ពុជា លើកលែងតែការសិក្សាគំរូតាងតូចៗមួយចំនួនដែលបានសន្និដ្ឋានថា ការលក់ដូរដីធ្លីបានកើនខ្លាំង ក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ។ ក្នុងការសំភាសន៍ យើងបានរកឃើញថា អ្នកឆ្លើយសំភាសន៍មានឯកសារចំពោះតែដីដែលបានលក់-ទិញដោយឆ្លងកាត់ការិយាល័យពួកគេប៉ុណ្ណោះ ។ ដោយការលក់ដូរជាច្រើនទាំងផ្លូវការ និងក្រៅផ្លូវការ បានរំលងពួកគេ ដូច្នេះគ្មានអ្នកណាមួយដែលមានឯកសារលើការទិញ-លក់ដីធ្លីទាំងអស់ឡើយ ។ ដើម្បីស្វែងយល់ពីនិន្នាការនៃការលក់ដូរដីទាំងអស់ចាប់តាំងពីឆ្នាំ១៩៨៩ មក យើងត្រូវពឹងផ្អែកលើស្មារតីចងចាំអំពីការទិញ-លក់ដីធ្លីដែលបានកើតឡើងនៅក្នុងឃុំ/ស្រុករបស់ពួកគេ ក្នុងរយៈ ១២ឆ្នាំកន្លងមក ។ ដើម្បីជួយសំរួលដល់ការនឹកឃើញឡើងវិញ សំនួរដូចខាងក្រោមត្រូវបានសួរទៅដល់ប្រធានឃុំ និង ប្រធានសុរិយោដីស្រុក គឺ "តើអ្នកចងចាំកំរិតណាពីចំនួននៃការទិញ-លក់ដីទាំងអស់ពីឆ្នាំ១៩៩០-១៩៩៥ នៅក្នុងឃុំ ឬស្រុករបស់អ្នក?" ។ ក្នុងចំណោមអ្នកឆ្លើយសំភាសន៍ ទាំង

២៨នាក់ ( ប្រធានឃុំ១៨នាក់ និងប្រធានសុរិយោដីស្រុក១០នាក់) គ្មានអ្នកណាម្នាក់ឆ្លើយថា បានចងចាំការលក់ដីទាំងអស់ឡើយ គឺ ១១នាក់ឆ្លើយថាអាចចងចាំបានប្រហែល៧៥%, ១៥នាក់ឆ្លើយថាចងចាំប្រហែល៥០%, និង ២នាក់ឆ្លើយថាចងចាំបានប្រហែល២៥% នៃប្រតិបត្តិការការទិញ-លក់ដីទាំងអស់ ។

ពួកគេនិយាយថា ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការលក់ដូរដីធ្លីបានកើនខ្ពស់បំផុតនៅឆ្នាំ១៩៩៦ នៅក្នុងឃុំ និងស្រុកភាគច្រើន ។ ពត៌មាននេះដូចគ្នានឹងទិន្នន័យនៃការផ្ទេរកម្មសិទ្ធិដីធ្លីជាផ្លូវការ ដែលរក្សាទុកនៅ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដូចបានពិភាក្សារួចហើយ ។ និន្នាការដែលអ្នកឆ្លើយសំភាសន៏បានបញ្ជាក់ វាមិនខុសគ្នាពីនិន្នាការដែលទិន្នន័យជាផ្លូវការបានបង្ហាញឡើយ គឺការលក់ដីជាផ្លូវការ និងក្រៅផ្លូវការបានកើនយ៉ាងខ្លាំងនៅដើមទសវត្សរ៍១៩៩០ ដោយមានអ្នកក្រៅបានចាប់ផ្តើមទិញដីធ្លីនៅមូលដ្ឋានក្នុងឆ្នាំ១៩៩៣-៩៤ ។ គេបានរាយការណ៍ថា ការទិញដីដោយអ្នកក្រៅក្នុងឆ្នាំ១៩៩៥ ( ជាចំបងអ្នកភ្នំពេញ និងអ្នកជំនួញបរទេស) បានបង្កឱ្យមាន "ឥទ្ធិពលមេគុណ (multiplier effect)" គួរឱ្យកត់សំគាល់នៅក្នុងទីផ្សារដីធ្លី គឺអ្នកលក់ដីបានយកប្រាក់ទៅទិញដីរបស់អ្នកផ្សេងជាបន្តទៀត ហើយដំណើរការនេះឡើងដល់កំពូលក្នុងឆ្នាំ១៩៩៦ ។ គួររំលឹកឡើងវិញថា សេដ្ឋកិច្ចមានសន្ទុះខ្លាំងរវាងឆ្នាំ១៩៩៥ និងខែកក្កដា ១៩៩៧ ។ មានមូលធនជាច្រើនបានមកពីប្រភពផ្សេងៗ រួមទាំង វិនិយោគផ្ទាល់ពីបរទេស និងការកាប់ឈើខុសច្បាប់ផង បានហូរចូលទៅក្នុងសេដ្ឋកិច្ចនៅក្នុងពេលនោះ ។ អស្ថិរភាពនយោបាយនៅឆ្នាំ១៩៩៧ និងការធ្លាក់ចុះសេដ្ឋកិច្ចក្នុងពេលបន្ទាប់មក គឺជាមូលហេតុធ្វើឱ្យការលក់ដូរដីធ្លីថយចុះនៅក្នុងឆ្នាំបន្តបន្ទាប់មក ។ នៅក្នុងន័យនេះ ទីផ្សារដីធ្លីនៅកម្ពុជា ហាក់ដូចជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅ នឹងដំណើរការសេដ្ឋកិច្ច និងស្ថានការណ៍នយោបាយ ។

## ៥.២. ប្រភេទនៃការទិញ-លក់ដីធ្លី

មូលហេតុដ៏សាមញ្ញមួយដែលបញ្ជាក់ឱ្យដឹងថា ការលក់ដីត្រូវបានអនុវត្តតាមច្បាប់ ឬមិនតាមច្បាប់ គឺការដែលដីនោះបានចុះបញ្ជីជាផ្លូវការ ឬមិនបានចុះ ។ ជាទូទៅ មានក្រដាសស្នាមផ្លូវការពីរប្រភេទដែលគេប្រើប្រាស់សំរាប់បញ្ជាក់កម្មសិទ្ធិដីគឺ បង្កាន់ដៃ និងប័ណ្ណប្លង់ដី ។ ដូចបានពិពណ៌នាក្នុងផ្នែកទី២ រដ្ឋបានចេញប័ណ្ណប្លង់ដីប្រហែល ៥១៨.000ប័ណ្ណ ឬជាង ១0%បន្តិច នៃចំនួនពាក្យសុំដែលបានដាក់តាំងពីឆ្នាំ១៩៨៩ មក ។ ដូច្នេះ ប្រតិបត្តិការលក់ដីដែលមានប័ណ្ណប្លង់ដីត្រឹមត្រូវ អាចតំណាងឱ្យតែមួយភាគតូចនៃការលក់ដីទាំងអស់នៅកម្ពុជា ។ សំភាសន៏នៅតាមមូលដ្ឋានបានបង្ហាញថា គ្រួសារមួយជាច្រើននៅក្នុងតំបន់ខ្លះគ្មានទាំងបង្កាន់ដៃទទួលពាក្យសុំកម្មសិទ្ធិសំរាប់ដីធ្លីរបស់ខ្លួនផង ។ គ្រួសារខ្លះបានធ្វើបាត់ឯកសារ រីឯគ្រួសារខ្លះទៀតមិនបានដាក់ពាក្យសុំទៅដោយមិនបានដឹង ឬមានការភ័ន្តច្រឡំ ឬដោយអាជ្ញាធរមិនបានរំលឹកប្រាប់ពួកគេឱ្យដាក់ពាក្យសុំ ។ ក្នុងករណីខ្លះ អាជ្ញាធរមូលដ្ឋានមិនបានយកបង្កាន់ដៃទៅឱ្យប្រជាជន ។ មួយចំណែកទៀត មានដីជាច្រើនត្រូវបានពុះចែកបន្ត ដូច្នេះហើយ បង្កាន់ដៃដើមក៏លែងមានប្រយោជន៏ទៀត ។

នៅក្នុងឯកសារនេះ ប្រតិបត្តិការទិញ-លក់ដីត្រូវបានបែងចែកជាពីរប្រភេទគឺ គឺការទិញ-លក់តាមផ្លូវការ និងការទិញ-លក់ក្រៅផ្លូវការ ដូចមានមានពិភាក្សានៅខាងក្រោម ។

## ៥.៣. ការទិញ-លក់ដីតាមផ្លូវការ

"ការទិញ-លក់ដីតាមផ្លូវការ" សំដៅដល់ប្រតិបត្តិការទិញ-លក់ ដែលអនុវត្តទៅតាមនីតិវិធីដែលរដ្ឋាភិបាលបានបង្កើតជាផ្លូវការ ។ ការទិញ-លក់ប្រភេទនេះ អាចកើតមានតែចំពោះដីមានប័ណ្ណប្លង់ដីត្រឹមត្រូវប៉ុណ្ណោះ ។ ការផ្ទេរកម្មសិទ្ធិ ដីជាផ្លូវការត្រូវចាប់ផ្តើមពីការិយាល័យសុរិយោដីស្រុក ដែលស្ថិតក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ នីតិវិធីនេះ រំលងអាជ្ញាធរភូមិ និងឃុំ ប៉ុន្តែអាជ្ញាធរទាំងនេះអាចត្រូវបានអញ្ជើញឱ្យជួយបញ្ជាក់លើបញ្ហាព្រំប្រទល់ ឬបញ្ហាផ្សេងទៀត បើសិនមានការចាំបាច់ ។ ពត៌មានដែលត្រូវយកមកបំពេញនៅក្នុងសំណុំឯកសារផ្ទេរកម្មសិទ្ធិ ដែលមានឈ្មោះថា លិខិតលក់ផ្តាច់

( ភាសាបារាំង Vente Definitive) រួមមាន អាសយដ្ឋានរបស់អ្នកទិញ និងអ្នកលក់ ទំហំដី និងថ្លៃរបស់វា ។ លិខិតនេះត្រូវមានការបញ្ជាក់យល់ព្រមពីអភិបាលស្រុក ។ បន្ទាប់មក ពន្ធលើការលក់ដី ឬពន្ធប្រថាប់ត្រា ដែលមានអត្រា ៤%នៃថ្លៃលក់ដី ត្រូវបង់ឱ្យមន្ទីរពន្ធដារខេត្ត ។ ដោយមានការបញ្ជាក់ថាត្រឹមត្រូវពី មន្ទីរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ថ្នាក់ខេត្ត សំណុំឯកសារផ្ទេរកម្មសិទ្ធិ ដែលមានភ្ជាប់នូវប័ណ្ណប្លង់ដី ត្រូវដាក់ជូនទៅអគ្គនាយកដ្ឋានសុរិយោដី និងសំណង់ (GDCG) ដើម្បីទទួលបានការអនុម័តជាស្ថាពរ ។ លិខិតមួយច្បាប់ត្រូវរក្សាទុកនៅអគ្គនាយកដ្ឋាន និងមួយច្បាប់ទៀតប្រគល់ទៅឱ្យអ្នកទិញ ។ ដូចមានពិភាក្សាខាងក្រោម អ្នកឆ្លើយសំភាសន៍យល់ថា ដំណើរការនេះស្មុគស្មាញ និងអស់សោហ៊ុយច្រើន ដែលធ្វើឱ្យប្រជាជនជាច្រើនមិនអនុវត្តតាមនីតិវិធីផ្លូវការ ។ ការផ្ទេរតាមផ្លូវការនូវកម្មសិទ្ធិដីធ្លីក្នុងគ្រប់ខេត្ត-ក្រុង ត្រូវតែអនុម័តដោយអគ្គនាយកដ្ឋានសុរិយោដីដែលមានទីតាំងនៅភ្នំពេញ លើកលែងតែចំពោះរាជធានីភ្នំពេញ និងខេត្តកណ្តាលដែលមានស្វ័យភាពចាប់តាំងពីខែមករា ឆ្នាំ២០០១ មក ។ ដោយដកចេញនូវខេត្ត-ក្រុងទាំងពីរនេះ គឺមានប្រហែល ១៦.០០០ប្រតិបត្តិការទិញ-លក់ដីប៉ុណ្ណោះក្នុងទូទាំងប្រទេស ដែលបានឆ្លងកាត់ដំណើរការជាផ្លូវការ ចាប់ពីឆ្នាំ១៩៩៥ ដល់ពាក់កណ្តាលឆ្នាំ២០០១ ដូចបានពិភាក្សានៅក្នុងផ្នែកទី៣ និងទី៤ រួចហើយ ។

យោងតាមការចុះសិក្សាដល់មូលដ្ឋានរបស់យើង, អ្នកភ្នំពេញដែលទិញដី គឺជាអ្នកគោរពតាមនីតិវិធីផ្លូវការច្រើនជាងគេបំផុត[១] ។ មូលហេតុអាចងាយយល់បាន ពីព្រោះអ្នកភ្នំពេញនៅឆ្ងាយពីដីដែលគេទិញ ដូច្នេះគេត្រូវការរបៀបរបបដែលផ្តល់សុវត្ថិភាពកម្មសិទ្ធិខ្ពស់ ដោយសុខចិត្តអស់សោហ៊ុយច្រើន ។ នេះហើយជាមូលហេតុដែលភាគច្រើននៃអ្នកទិញដីតាមវិធីផ្លូវការនៅក្នុងទិន្នន័យដែលយើងបានពិភាក្សាកន្លងមក គឺអ្នកភ្នំពេញ ។ ការនេះធ្វើឱ្យមានលំអៀងនៅក្នុងគំរូតាងខាងលើ ។

## ៥.៤. ការទិញ-លក់ដីក្រៅផ្លូវការ

ការទិញ-លក់ណាដែលមិនអនុវត្តតាមនីតិវិធីដូចរៀបរាប់ខាងលើ ត្រូវបានចាត់ទុកថាជា "ការទិញ-លក់ក្រៅផ្លូវការ" ។ ការទិញ-លក់ដីក្រៅផ្លូវការរួមមាន:

១. ការទិញ-លក់ដោយមាន ឬគ្មានកិច្ចសន្យា រវាងភាគីអ្នកទិញ និងអ្នកលក់ ប៉ុន្តែប្រតិបត្តិការនេះត្រូវបានធ្វើឡើងដោយមិនបានជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានទាល់តែសោះ ។

២. ការទិញ-លក់ដោយមានការព្រមព្រៀងពីអាជ្ញាធរត្រឹមថ្នាក់ភូមិ ។

៣. ការទិញ-លក់ដោយមានការព្រមព្រៀងពីអាជ្ញាធរត្រឹមថ្នាក់ឃុំ ។

៤. ការទិញ-លក់ដោយមានការព្រមព្រៀងពីអាជ្ញាធរដល់ថ្នាក់ស្រុក ឬខេត្ត (នេះជាករណីដែលកំរកើតមាន ពីព្រោះការទិញ-លក់ដែលឡើងដល់ថ្នាក់នេះ ច្រើនតែពាក់ព័ន្ធនឹងដីមានប័ណ្ណប្លង់ដី ហើយច្រើនតែអនុវត្តជាផ្លូវការទៅដល់ថ្នាក់ អគ្គនាយកដ្ឋានសុរិយោដីនៅភ្នំពេញ) ។

អង្កេតនៅមូលដ្ឋានបានបង្ហាញថា ការទិញ-លក់ដីភាគច្រើន ជាពិសេសដីតូចៗ ច្រើនអនុវត្តតាមវិធីទី១ ឬទី២ ខាងលើ។ ករណីទាំងនេះច្រើនកើតមាននៅតំបន់ជនបទដែលដីមានថ្លៃទាប ហើយការផ្ទេរកម្មសិទ្ធិត្រឹមត្រូវអស់សោហ៊ុយច្រើនពេកលើសពីលទ្ធភាពរបស់ប្រជាជនភាគច្រើន ។ មួយចំណែកទៀត ប្រជាជនអាចមានអារម្មណ៍ថា មិនចាំបាច់មានប័ណ្ណប្លង់ដី ឬការចុះបញ្ជីអ្វីទេ ពីព្រោះទីផ្សារដីធ្លីនៅតំបន់ទាំងនោះមិនទាន់លូតលាស់ ។ ឧទាហរណ៍ នៅក្នុងឃុំមួយ ប្រធានឃុំបានប៉ាន់ស្មានថា មានដីស្រែប្រហែល ២០០កន្លែង ត្រូវបានទិញ-លក់ដោយគ្មានឯកសារផ្ទេរកម្មសិទ្ធិត្រឹមត្រូវអ្វីមួយឡើយ ។ ម្យ៉ាងវិញទៀត ការទិញ-លក់ទាំងនេះត្រូវបានធ្វើឡើងដោយគ្មានការជូនដំណឹងដល់អាជ្ញាធរឃុំទៀតផង ។

---

[១] ការណ៍នេះត្រូវបានបញ្ជាក់ច្បាស់នៅក្នុងការសិក្សារបស់យើងកាលពីមុនដែលមានឈ្មោះថា "ការវាយតំលៃបញ្ហាសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា" ។ សូមអាន ឯកសារ So et al ឆ្នាំ២០០១ ។

ក្នុងចំណោមការផ្ទេរកម្មសិទ្ធិដីធ្លីក្រៅផ្លូវការច្រើនបែបយ៉ាង ការផ្ទេរដោយមានការព្រមព្រៀងពីប្រធានឃុំ គឺជាវិធីដែលឃើញមានជាទូទៅជាងគេ ។ នៅក្នុងឃុំមួយចំនួន ការលក់ដីប្រហែល ៩០%បានអនុវត្តតាមវិធីនេះ ។ អាជ្ញាធរសុរិយោដីស្រុកបានទទួចឱ្យឃុំរាយការណ៍ឡើងពីការទិញ-លក់ដីធ្លីទាំងអស់ទៅឱ្យខ្លួន ទោះបីមានតែដីធ្លីមានប័ណ្ណប្លង់ដីប៉ុណ្ណោះដែលត្រូវបានទិញ-លក់តាមផ្លូវការ ។ ប៉ុន្តែរបាយការណ៍បែបនេះមិនសូវមានធ្វើញឹកញាប់ទេ ។ ផ្ទុយទៅវិញប្រធានឃុំច្រើនតែចុះហត្ថលេខា និងបោះត្រា លើលិខិតព្រមព្រៀងលក់ ដែលប្រជាជនជាច្រើនយល់ថា វាមានលក្ខណៈផ្លូវការគ្រប់គ្រាន់ហើយ សំរាប់បញ្ជាក់ការផ្ទេរកម្មសិទ្ធិ ។ ប្រជាជន ឬមួយមិនយល់អំពីនីតិវិធីផ្លូវការ ឬមួយសុខចិត្តទទួលយកត្រានិងហត្ថលេខារបស់ប្រធានឃុំថាជាការគ្រប់គ្រាន់ពីព្រោះពួកគេយល់ថាគ្មានវិធីអ្វីផ្សេង ទោះបីការអនុវត្តន៍បែបនេះមិនសូវត្រឹមត្រូវក៏ដោយ ។ ជួនកាលការទិញ-លក់ដីមានប័ណ្ណប្លង់ដីត្រឹមត្រូវ ក៏មិនបានធ្វើការផ្ទេររហូតដល់ថ្នាក់អគ្គនាយកដ្ឋានសុរិយោដីដែរ ។ ការលក់ដីមានប័ណ្ណប្លង់ដីត្រឹមត្រូវមួយចំនួនច្រើនគួរសម ត្រូវបានផ្ទេរត្រឹមថ្នាក់ឃុំ ដោយសារអ្នកទិញចង់ចៀសវាងការបង់ពន្ធ និងចៀសវាងនីតិវិធីសាំញ៉ាំ ។

មន្ត្រីសុរិយោដីស្រុកអ្នកឆ្លើយសំភាសន៍ បានបន្ទោសប្រធានឃុំចំពោះការផ្តល់ការអនុម័តមិនត្រឹមត្រូវ និងការអនុញ្ញាតឱ្យរបៀបរបបខុសបែបនេះកើតមានជាបន្តទៀត ។ ប៉ុន្តែប្រធានឃុំបាននិយាយថា ពួកគេមិនបានផ្តល់ការអនុម័តទេ គឺគ្រាន់តែចុះហត្ថលេខាទទួលដឹងឮ ហើយរាយការណ៍បន្តទៅថ្នាក់ស្រុកប៉ុណ្ណោះ ។ ពួកគាត់និយាយថា វាអាស្រ័យលើភាគីអ្នកលក់ និងអ្នកទិញ ក្នុងការសំរេចឡើងទៅដល់ថ្នាក់ស្រុក ឬដល់មន្ត្រីថ្នាក់ខ្ពស់ជាងនេះទៀត ។

## ៥.៥. មូលហេតុដែលធ្វើឱ្យគេមិនចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឹមត្រូវ

គេត្រូវមានប័ណ្ណប្លង់ដី ដើម្បីធ្វើការផ្ទេរដីធ្លីតាមផ្លូវការនៅពេលលក់ ។ ដូចបានពិភាក្សាខាងលើ ម្ចាស់ដីភាគច្រើនមិនអាចផ្ទេរកម្មសិទ្ធិដីរបស់ខ្លួនតាមផ្លូវការទៅដល់ អគ្គនាយកដ្ឋានសុរិយោដីឡើយ ហើយពួកគេត្រូវស្វែងរកវិធីផ្សេងទៀត ។ តាមអង្កេតរបស់យើង ប្រជាជនមួយចំនួនដែលមានប័ណ្ណប្លង់ដីត្រឹមត្រូវហើយ ក៏មិនបានផ្ទេរកម្មសិទ្ធិតាមផ្លូវការដែរនៅពេលលក់ ។ ម្យ៉ាងវិញទៀតម្ចាស់ដីភាគច្រើន ជាពិសេសអ្នកគ្មានប័ណ្ណប្លង់ដី គឺមិនបានដឹង ឬមិនបានខ្វល់ខ្វាយអំពីនីតិវិធីផ្លូវការទេ ។ ពួកគេស្វែងរកភាពស្របច្បាប់ តាមរយៈការបោះត្រា និងចុះហត្ថលេខាដោយប្រធានឃុំ ហើយជឿជាក់ថា ក្រោយបានធ្វើដូច្នេះ គឺអាចបំពេញបានតាមការតំរូវនានាហើយ ។ អ្នកខ្លះទៀតធ្វើកិច្ចសន្យារវាងអ្នកលក់ និងអ្នកទិញ ។ សំរាប់ពួកគេ ការធ្វើដូច្នេះគឺគ្រប់គ្រាន់ហើយ ឱ្យតែភាគីទាំងសងខាងសុខចិត្តទាំងអស់គ្នា ។

ប្រធានឃុំ និងប្រធានសុរិយោដីស្រុក បានផ្តល់នូវមូលហេតុខាងក្រោម ដែលធ្វើឱ្យប្រជាជនចៀសវាង ឬមិនដើរតាមនីតិវិធីផ្លូវការក្នុងការផ្ទេរកម្មសិទ្ធិដីធ្លី:

- ប្រជាជនមិនដឹងអំពីចំនួនប្រាក់ដែលពួកគេត្រូវបង់សំរាប់ការផ្ទេរកម្មសិទ្ធិដីធ្លីជាផ្លូវការ ។ អ្នកខ្លះគិតថាវាថ្លៃពេកទើបចៀសវាង ។ អ្នកខ្លះទៀតខ្លាចមានការទាមទារឱ្យបង់ប្រាក់ច្រើនហួសហេតុពេកទៅឱ្យរដ្ឋអំណាច ។
- ចំពោះអ្នកមានប័ណ្ណប្លង់ដីហើយ ប៉ុន្តែមិនផ្ទេរត្រឹមត្រូវ មកពីពួកគេគិតថា នីតិវិធីសាំញ៉ាំពេក ហើយពន្ធខ្ពស់ពេក ។
- ប្រជាជនខ្លះគិតថា មិនចាំបាច់ចុះបញ្ជីការផ្ទេរកម្មសិទ្ធិត្រឹមត្រូវទេ ពីព្រោះពួកគេមានទំនុកចិត្តថា គ្មានអ្នកណាមកដណ្តើមកម្មសិទ្ធិដីទេ ពីព្រោះពួកគេកាន់កាប់ដីនោះជាក់ស្តែង ហើយជាពិសេសបើសិនដីនោះតូច ឬមានតំលៃទាប ។
- ប្រជាជនគ្មានជំនឿថា រដ្ឋអំណាចអាចដាក់អនុវត្តច្បាប់បានឡើយ ជាពិសេសក្នុងករណីមានវិវាទ ដូច្នេះពួកគេយល់ថា វាជាការចំណាយប្រាក់ឥតប្រយោជន៍ក្នុងការអនុវត្តតាមផ្លូវការ ។
- ក្នុងករណីខ្លះ អ្នកទិញគឺជាមន្ត្រីរដ្ឋាភិបាល ហើយពួកគេពឹងផ្អែកលើឋានៈរបស់ខ្លួនជាជាងលើក្រដាសស្នាមផ្លូវការដើម្បីបញ្ជាក់អះអាងកម្មសិទ្ធិ ។

## ៥.៦. ពន្ធប្រថាប់ត្រា ៤% និងឥទ្ធិពលនៅលើថ្លៃដីដែលចុះរាយការណ៍ជាផ្លូវការ

តាមច្បាប់ ការទិញ-លក់ដីត្រូវជាប់ពន្ធ ៤% ដែលហៅថាពន្ធប្រថាប់ត្រា ។ គោលដៅមួយនៃការសិក្សានេះ គឺដើម្បីស្វែងយល់ថា តើបន្ទុកពន្ធបានរារាំងប្រជាជនមិនឱ្យរាយការណ៍ពីថ្លៃដីពិត និងមិនឱ្យប្រើប្រាស់វិធីផ្ទេរកម្មសិទ្ធិជាផ្លូវការ ក្នុងកំរិតណា ។

ការិយាល័យសុរិយោដីស្រុកទទួលបន្ទុកកំណត់ថ្លៃដី ហើយមន្ទីរពន្ធដារខេត្តជាអ្នកគណនាប្រាក់ពន្ធ ដែលត្រូវបង់ចូលរតនាគារខេត្ត សំរាប់ការប្រើប្រាស់ក្នុងរដ្ឋបាលខេត្ត ។ ក្នុងការអនុវត្តន៍ជាក់ស្តែង មានការគេចពន្ធច្រើនណាស់ ។

នៅក្នុងឃុំទាំង១៨ ដែលបានធ្វើអង្កេត, ការទិញ-លក់ដីតាមផ្លូវការទាំងអស់ សុទ្ធតែបានបង់ពន្ធ ។ ក៏ប៉ុន្តែថ្លៃដីត្រូវបានរាយការន៏បញ្ចុះទាបជាងថ្លៃពិត ដើម្បីបង់ពន្ធតិច ។ ការបញ្ចុះថ្លៃដីមានកំរិតខុសៗគ្នាពីខេត្តមួយទៅខេត្តមួយ ប៉ុន្តែជាមធ្យមគេចុះរាយការណ៍តែត្រឹម ៤០%នៃថ្លៃពិតប៉ុណ្ណោះនៅក្នុងឯកសារផ្លូវការ ។ ដូច្នេះប្រាក់ពន្ធត្រូវបាត់អស់ ៦០% ។ ឧទាហរណ៍ នៅខេត្តកំពង់ចាម និងបាត់ដំបង គេចុះរាយការណ៍លើឯកសារផ្ទេរកម្មសិទ្ធិប្រហែល ២០-៣០%នៃថ្លៃពិត រីឯនៅខេត្តកណ្តាល និងក្រុងព្រះសីហនុ តួលេខនេះមានទំហំ ៥០-៨០% ។ នៅខេត្តកំពង់ស្ពឺ ប្រាក់ពន្ធត្រូវបាត់អស់ពី ៤០-៦០% ។

ថ្លៃដីត្រូវបានលាក់បាំង តាមការឃុបឃិតគ្នាយ៉ាងសកម្មពីភាគីជាច្រើនដែលពាក់ព័ន្ធ ។ ទី១ គ្មានភាគីទិញ-លក់ណាមួយដែលចង់បង់ពន្ធច្រើនទេ ដូច្នេះពួកគេត្រូវលាក់បាំងថ្លៃពិត ។ មន្ត្រីសុរិយោដីក៏បានប្រយោជន៍ពីការកត់ត្រាថ្លៃដីឱ្យទាបដែរ ពីព្រោះបានទទួលមួយចំណែកនៃប្រាក់កំរៃបង់ក្រៅផ្លូវការ ហើយមន្ត្រីពន្ធដារក៏បានទទួលមួយចំណែកដែរ ។ នៅក្នុងស្រុកមួយចំនួន ការចរចាអំពីចំនួនប្រាក់ពន្ធ រវាងអ្នកទិញ និងមន្ត្រីពន្ធដារ ត្រូវបានធ្វើឡើងនៅក្នុងភោជនីយដ្ឋាន ឬនៅមន្ទីរពន្ធដារខេត្តតែម្តង ។ នៅ ពេលមានការព្រមព្រៀងហើយ មន្ត្រីពន្ធដារទទួលប្រាក់ ហើយបង់មួយចំនួនចូលក្នុងរតនាគារខេត្ត រីឯមន្ត្រីសុរិយោដីត្រូវគណនា ថ្លៃដីបញ្ច្រាសមកវិញ ដើម្បីឱ្យត្រូវតាមប្រាក់ពន្ធ (៤%) ដែលបានបង់ចូលរតនាគាររួចហើយ ។ ធ្វើដូច្នេះអ្នកជាប់ពន្ធបង់តែមួយ ចំណែកប៉ុណ្ណោះនៃប្រាក់ពន្ធដែលគេត្រូវបង់តាមថ្លៃលក់ដីពិតប្រាកដ ។ យោងតាមភស្តុតាងទាំងនេះ ថ្លៃដីដែលចុះរាយការណ៍ នៅលើក្រដាសផ្ទេរកម្មសិទ្ធិផ្លូវការ វាខុសយ៉ាងឆ្ងាយពីការពិត ។

ប្រធានសុរិយោដីមួយចំនួន បានបង្ហាញនូវការមិនសប្បាយចិត្តចំពោះអំណាចដែលមន្ត្រីពន្ធដារមាន ហើយបានអះអាងថាពួកគេអាចផ្តល់ចំណូលឱ្យរដ្ឋាភិបាលច្រើនជាងនេះ ១០ដង បើសិនពួកគេត្រូវបានផ្តល់អំណាចឱ្យប្រមូលពន្ធលើការទិញ-លក់ដី ។ ពួកគេនិយាយថា កាលពីមុនឆ្នាំ១៩៧៥ គឺនៅពេលដែលពន្ធលើការទិញ-លក់ដី ត្រូវបានប្រមូលផ្ទាល់ដោយការិយាល័យសុរិយោដីស្រុក ប្រព័ន្ធប្រមូលពន្ធមានដំណើរការល្អជាងនេះឆ្ងាយណាស់ ទោះបីអត្រាពន្ធកាលពេលនោះខ្ពស់ដល់ ៦%ក៏ដោយ ។ ពួកគេលើកហេតុផលថា មន្ត្រីថ្នាក់ស្រុកនៅជាប់នឹងមូលដ្ឋាន ហើយដឹងអំពីថ្លៃដី និងទីផ្សារដីធ្លី ច្បាស់ជាងមន្ត្រីនៅមន្ទីរពន្ធដារខេត្ត ។ ម្យ៉ាងវិញទៀត មន្ត្រីសុរិយោដី និងមន្ត្រីថ្នាក់ស្រុកដទៃទៀត មានការលើកទឹកចិត្តក្នុងការប្រមូលពន្ធឱ្យបានច្រើន ពីព្រោះពួកគេទទួលបាន ១%នៃថ្លៃដីដែលបានលក់ ។

ទោះបីប្រជាជនជាច្រើនមិនបង់ពន្ធច្រើនដូចការកំណត់ក្នុងច្បាប់ក៏ដោយ ក៏អ្នកឆ្លើយសំភាសន៍ជាច្រើនបានរាយការណ៍ថាពន្ធលើការលក់ដីបានជំរុញប្រជាជនមិនឱ្យធ្វើតាមវិធីផ្លូវការក្នុងការផ្ទេរកម្មសិទ្ធិដីធ្លី ។ គេបានទទួលស្គាល់ជាទូទៅថា ប្រជាជនជាច្រើនមិនចង់បានប័ណ្ណប្លង់ដីសំរាប់ដីរបស់ខ្លួនឡើយ ពីព្រោះការលក់ដីដែលបានចុះបញ្ជីរួច វាពិបាកជាង និងត្រូវជាប់ពន្ធ ។

## ជំពូក ៦

# សេចក្តីសន្និដ្ឋាន

ទោះបីជាមានចំណុចខ្វះខាតមួយចំនួននៅក្នុងទិន្នន័យ និងពត៌មានដែលបានយកមកវិភាគនៅក្នុងឯកសារនេះក៏ដោយ ក៏យើងអាចធ្វើការសន្និដ្ឋានមួយចំនួនបានដែរ ។ ទី១ អភិបាលកិច្ចដីធ្លីនៅទន់ខ្សោយ ដូច្នេះហើយដីធ្លីដែលត្រូវបានចុះបញ្ជី និងផ្ទេរកម្មសិទ្ធិជាផ្លូវការ គ្រាន់តែជាមួយចំណែកយ៉ាងតូចនៃដីធ្លីសរុបនៅក្នុងប្រទេសតែប៉ុណ្ណោះ ។ រឿងនេះកើតឡើងមួយចំណែកដោយសារកង្វះបទប្បញ្ញត្តិច្បាប់គ្រប់គ្រងទីផ្សារដីធ្លី ដែលជាលក្ខខ័ណ្ឌចាំបាច់សំរាប់ឱ្យទីផ្សារដំណើរការបានយ៉ាងសក្តិសិទ្ធិនៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី ។ ទី២ ទីផ្សារដីធ្លី មានការីតលូតលាស់ខុសៗគ្នា និងមានរបៀបរបបគ្រប់គ្រងនិងទិញ-លក់ដីធ្លីខុសៗគ្នា ដែលកំពុងអនុវត្តក្នុងពេលជាមួយគ្នា ។ កង្វះការអនុវត្តន៏ឯកភាពគ្នានៅក្នុងទីផ្សារដីធ្លី បានបណ្តាលឱ្យមាន ការអនុវត្តន៏ច្បាប់លើសពីមួយរបៀប និងមានកង្វះភាពច្បាស់លាស់អំពី នីតិវិធី វិធាន និងដែនសមត្ថកិច្ច ដែលត្រឹមត្រូវ។ ទី៣ នីតិវិធីផ្លូវការសំរាប់ការចុះបញ្ជីប្រតិបត្តិការទិញ-លក់ដី វាមានលក្ខណៈសាំញ៉ាំ និងមានថ្លៃខ្ពស់ជាងនីតិវិធីក្រៅផ្លូវការ ដែលធ្វើឱ្យប្រជាជនក្រីក្រ និងអ្នកគ្មានអំណាច គ្មានលទ្ធភាពអនុវត្តតាមបាន ។ នេះហើយជាចំណុចដែលគួរព្រួយបារម្ភ ។

ការទិញ-លក់ដីធ្លីតាមផ្លូវការ ជាប់ទាក់ទិនដីធ្លីមួយភាគតូចប៉ុណ្ណោះ។ ដោយហេតុថា ទិន្នន័យស្តីពីប្រតិបត្តិការទិញ-លក់ដីធ្លី មិនអាចតំណាងឱ្យការទិញ-លក់ទាំងអស់បាន ដូច្នេះគេអាចធ្វើសេចក្តីសន្និដ្ឋានបានតែតិចតួចប៉ុណ្ណោះ ។ ទិន្នន័យបញ្ជាក់ថា ដីដែលមានតំលៃពាណិជ្ជកម្មខ្ពស់ត្រូវបានគេចុះបញ្ជី និងធ្វើការទិញ-លក់តាមផ្លូវការ ។ ដីទាំងនេះរួមមាន ដីឡូត៍ធំៗ ដីនៅក្នុងឬនៅជិតកន្លែងល្អៗ (ដូចជា នៅជិតទីផ្សារ នៅក្នុងទីប្រជុំជន នៅតាមផ្លូវជាតិសំខាន់ៗ) និងដីដែលកាន់កាប់ដោយអ្នកមានលទ្ធភាពបង់ថ្លៃចុះបញ្ជី និងថ្លៃផ្ទេរកម្មសិទ្ធិតាមផ្លូវការ ។ ការទិញ-លក់ដីធ្លី ក៏ដូចជាការចុះបញ្ជីដែរ ច្រើនកើតនៅក្នុងខេត្តណាដែលមានពាណិជ្ជកម្មច្រើន ។ អ្នកទិញភាគច្រើនមកពីក្រុងភ្នំពេញ និងបានទិញដីនៅក្រុងព្រះសីហនុ ខេត្តកណ្តាល សៀមរាប និងកំពង់ចាម ព្រមទាំងខេត្តផ្សេងៗទៀតផងដែរ ។ ក្នុងករណីជាច្រើន អ្នកលក់ និងអ្នកទិញមកពីខេត្ត និងស្រុកផ្សេងពីគ្នា ដែលឆ្លុះបញ្ចាំងនូវសកម្មភាពយ៉ាងច្រើនគួរឱ្យកត់សំគាល់នៃទិញដីទុកលក់យកចំណេញ ។ ការទិញ-លក់បានកើនយ៉ាងលឿននៅដើមទសវត្សរ៍១៩៩០ និងកើនខ្ពស់បំផុតនៅឆ្នាំ១៩៩៦ ប៉ុន្តែក្រោយមកបានធ្លាក់ចុះវិញ ។ មូលហេតុមួយនៃការប្រែប្រួលនេះ គឺការធ្លាក់ចុះសេដ្ឋកិច្ចដែលបានចាប់ផ្តើមនៅឆ្នាំ១៩៩៧ ក្រោយពីមានអស្ថិរភាពនយោបាយ ។

មូលហេតុចំបងដែលធ្វើឱ្យការទិញ-លក់ដីធ្លីមិនឆ្លងកាត់អាជ្ញាធរសុរិយោដីគឺ ដីភាគច្រើនមិនទាន់បានចុះបញ្ជីនៅឡើយ។ មានមូលហេតុផ្សេងទៀតខ្លះដែរ ដែលធ្វើឱ្យការទិញ-លក់ដីបានប្រព្រឹត្តទៅដោយរំលងខ្សែរយៈខាងអាជ្ញាធរ ។ ការតំរូវឱ្យប្រតិបត្តិការទិញ-លក់ដីទាំងអស់ត្រូវជាប់ពន្ធ គឺជាកត្តាចំបងមួយដែលធ្វើឱ្យប្រជាជនមិនឆ្លងកាត់អាជ្ញាធរ ។ ឧទាហរណ៍ អ្នកខ្លះចៀសវាងប្រព័ន្ធផ្លូវការ ដោយសារពួកគេគ្មានថវិកាគ្រប់គ្រាន់ សំរាប់បង់សោហ៊ុយពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិដីធ្លីជាផ្លូវការ ។

ចំណុចមួយទៀត គឺថ្លៃដែលចុះរាយការណ៍នៅក្នុងឯកសារជាផ្លូវការ មានការីតទាបជាងថ្លៃពិតយ៉ាងច្រើន ដើម្បីចៀស

រវាងការបង់ពន្ធច្រើន ។ ការឃុបឃិតគ្នារវាងមន្ត្រីសុរិយោដី នឹងមន្ត្រីពន្ធដារ, និងរវាងអ្នកលក់ នឹងអ្នកទិញ, ក្នុងការរាយការណ៍ថ្លៃដីមិនពិត ដើម្បីទទួលបានកំរៃក្រៅផ្លូវការ និងបង់ពន្ធតិច គឺជាចំណុចមួយដែលគួរយកចិត្តទុកដាក់ ។

# ឯកសារយោង


Biddulph, R., (2000), Making the Poor Visible, Phnom Penh: Cambodia Land Study Project, (Phnom Penh: Oxfam GB)

Chan S., S. Tep, and S. Acharya (2001), *Land Tenure in Cambodia: a Data Update,* Working Paper No. 19, (Phnom Penh: Cambodia Development Resource Institute)

Chandler, D. (1993) *A History of Cambodia,* Chaing Mai: Silkworm

Ghose A 1983, 'Agrarian Reform in Developing Countries: Issues of Theory and Problems of Practice', in, A Ghose (Ed.) *Agrarian Reform in Contemporary Developing Countries*, London and Canberra: Croom Helm.

Godfrey, M., S. So, S. Tep, C. Katz, D. Pon, S. Acharya, S. Chanto, and H. Thoraxy (2001), 'A Study of the Cambodian Labour Market: Reference to Poverty Reduction, Growth and Adjustment to Crisis', in, Development Analysis Network (Ed.), *Labour Markets in Transitional Economies of Southeast Asia and Thailand* (Phnom Penh)

Helmers K and E Kenefick 1999, *The World Food Programme Protracted Emergency Target Survey of Households in Cambodian Communes Affected by Civil Conflict since 1989,* Phnom Penh: World Food Programme

Kato E 1999, *Where Has All the Land Gone? Land Rights and Access in Cambodia*, Phnom Penh: Cambodia Land Project, Oxfam (GB)

RGC (1998) *Cambodia: National Environment and Action Plan*, Phnom Penh: Ministry of Environment, Phnom Penh.

Sik Boreak (2000), *Land Ownership, Sales and Concentration in Cambodia*, Working Paper No. 16, (Phnom Penh: Cambodia Development Resource Institute)

So, S., S. Real, U. Uch, R. Sy, B. Ballard and S. Acharya (2001), *Social Assessment of Land in Cambodia*, Working Paper No. 20, (Phnom Penh: Cambodia Development Resource Institute)

Thion (1993) *Watching Cambodia*, Bangkok: White Lotus

Williams, S. (1999), *Where has all the land gone? Review of Secondary Sources Relating to Land Tenure and Access Issues in Cambodia,* (Phnom Penh: Oxfam GB)

Williams S 2000, *A Study of the Capacity of five Provinces to Resolve Conflicts Over Land,* Phnom Penh: Cambodia Land Project, Oxfam (GB)

# ឧបសម្ព័ន្ធ

ទិន្នន័យដែលស្រង់បានមកពីឯកសារផ្ទេរដីជាផ្លូវការ តម្កល់នៅអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

| ពត៌មានអំពីដី | | | | | | | | ពត៌មានអំពីអ្នកទិញ | | | ពត៌មានអំពីអ្នកលក់ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខេត្ត ឬក្រុង | ស្រុក | ឃុំ-សង្កាត់ | កាលបរិច្ឆេទពេលលក់ | ទំហំដី | ប្រភេទដី | ថ្លៃដី | ប្រភេទនៃការផ្ទេរ | ខេត្ត ឬក្រុង | ស្រុក | ឃុំ-សង្កាត់ | ខេត្ត ឬក្រុង | ស្រុក | ឃុំ-សង្កាត់ |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជាៈ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផុតពីផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រេចស្រពិលៈ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ខ្មែរ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផុតពីផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផុតពីផ្សាយអស់ ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិច្ចូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនត្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិជឺលរី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.០០០រៀល ។

៥. Toshiyasu Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ីៈ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin Godfrey, Toshiyasu Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina Orlova, Per Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជាៈ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ។

៩. តេង-យូតី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនត្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជាៈ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គីមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក ប៊ូរ៉ាក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល, សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ, ទេព-សារ៉ាវី, ប៊ុន-ដូរីណា, Claude Katz, Sarthi Acharya, ស៊ីសុវត្ថិ ឌូង ចាន់តូ, និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាព ក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី រត្នមុនី Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) *ការវាយតំលៃសង្គមពាក់ពន្ធ័នឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-ប៊ូរ៉ាក្ស Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២០០២) *ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។